ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ
# ប្រព័ន្ធស្ថិតិជាតិកម្ពុជាឆ្នាំ២០២២

**រៀបចំដោយ**
**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

**រាជធានីភ្នំពេញ ខែ ធ្នូ ឆ្នាំ ២០២៤**

# បុព្វកថា

ប្រព័ន្ធស្ថិតិជាតិកម្ពុជា គឺជាប្រព័ន្ធបែបវិមជ្ឈការ ដែលមានវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាស្ថាប័នកណ្តាលនៃប្រព័ន្ធស្ថិតិជាតិនេះ។ អនុលោមតាមច្បាប់ស្តីពីស្ថិតិ អនុក្រឹត្យលេខ១៨១ អនក្រ.បក ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងអនុក្រឹត្យលេខ១៨២ អនក្រ.បក ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានកាតព្វកិច្ច និងទទួលខុសត្រូវគ្រប់អង្កេតនៅតាមអង្គភាពស្ថិតិ ហើយរាល់ការប្រមូលទិន្នន័យរបស់អង្គភាពស្ថិតិទាំងអស់ត្រូវតែចុះឈ្មោះនៅវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងរាល់ព័ត៌មាន និងទិន្នន័យស្ថិតិដែលបានផលិតត្រូវតែដាក់ជូនវិទ្យាស្ថានជាតិស្ថិតិ។ របាយការណ៍ប្រចាំឆ្នាំប្រព័ន្ធស្ថិតិជាតិកម្ពុជាឆ្នាំ២០២២នេះ ជាលើកទី៩ បន្ទាប់ពីខកខានរៀបចំចងក្រង និងផ្សព្វផ្សាយអស់រយៈពេល៣ឆ្នាំជាប់ៗគ្នាដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ របាយការណ៍នេះបានបង្ហាញពីទិដ្ឋភាពទូទៅមួយនៃសកម្មភាពដែលបានអនុវត្តនៅឆ្នាំ២០២២។

របាយការណ៍ប្រចាំឆ្នាំប្រព័ន្ធស្ថិតិជាតិកម្ពុជានេះ ជាលក្ខខណ្ឌចាំបាច់របស់វិទ្យាស្ថានជាតិស្ថិតិ ដែលត្រូវចងក្រង និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា អំពីសកម្មភាពក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិកម្ពុជា ដែលបានផលិតទិន្នន័យស្ថិតិពីក្រសួង ស្ថាប័នចំនួន៣០ និងពីធនាគារជាតិនៃកម្ពុជា ដែលជាអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។ តាមរយៈរបាយការណ៍នេះ បានផ្តល់នូវទស្សនៈ ចក្ខុវិស័យ និងជាធាតុចូលដ៏សំខាន់សម្រាប់អ្នករៀបចំគោលនយោបាយ ស្ថាប័នរដ្ឋ បណ្តាអង្គការជាតិ អន្តរជាតិ វិស័យឯកជនអ្នកសិក្សាស្រាវជ្រាវ និងសកម្មភាពស្ថិតិដែលត្រូវការនាពេលអនាគត។

តាងនាមឱ្យក្រសួងផែនការ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រយ៉ាងពេញទំហឹង ជំរុញ និងលើកទឹកចិត្តចំពោះការបំពេញការងារនេះប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គភាពស្ថិតិទាំងអស់ ដែលតែងតែបានផ្តល់ការសហការយ៉ាងយកចិត្តទុកដាក់ និងជំរុញការងារនេះឱ្យសម្រេចបានជោគជ័យ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ប្រចាំឆ្នាំប្រព័ន្ធស្ថិតិជាតិកម្ពុជានេះ នឹងបម្រើជាប្រយោជន៍ដល់ក្រសួង ស្ថាប័ន បណ្តាអង្គការជាតិ អន្តរជាតិនានា វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវ។

**រដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាស្ថិតិ**

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែធ្នូ ឆ្នាំ២០២៤

**ប៊ិន ត្រាឈៃ**

Scanned with CamScanner

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានភារកិច្ចទទួលខុសត្រូវលើ ការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ។ យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិនិង អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ការងារមួយក្នុងចំណោមការងារនានារបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ គឺបង្ហាញរបាយការណ៍ប្រចាំឆ្នាំជូនទីស្តីការគណៈរដ្ឋមន្ត្រី។

របាយការណ៍ទីប្រាំបួនដែលបានសរសេរនិងរៀបចំចងក្រង ដោយនាយកដ្ឋានស្តង់ដារនិងវិភាគស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ គឺជាព័ត៌មានដែលបានប្រមូលពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន៣០ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល ក្រុមប្រឹក្សា រដ្ឋលេខាធិការដ្ឋាន ធនាគារជាតិនៃកម្ពុជា ដែលទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង។

ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងមន្ត្រីនៅផ្នែកស្ថិតិផ្លូវការដែលបានចាត់តាំងនៅតាមបណ្តាក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានជួយដល់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិកម្ពុជា និងយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើនគុណភាពស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានស្តង់ដារ និងវិភាគស្ថិតិ រួមមាន៖ លោក **លឹម ពេញ** ប្រធាននាយកដ្ឋាន លោកស្រី **យិត ទីរីយ៉ា** និងលោកស្រី **ស៊ុយ សុធារ៉ា** អនុប្រធាននាយកដ្ឋាន និងលោកស្រី **នន សុគន្ធាទី** ប្រធានការិយាល័យ ដែលបានខិតខំសរសេរ និងចងក្រងរបាយការណ៍នេះឡើង។

**អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ និងជា**
**ប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ**

**ទ្រី ឫទ្ធា**

វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ
ខែ ធ្នូ ឆ្នាំ២០២៤



CS Scanned with CamScanner

# មាតិកា

**បុព្វកថា** ............ i
**អារម្ភកថា** ............ ii
**សង្ខេប** ............ v
**១ ប្រព័ន្ធស្ថិតិ** ............ ១
១.១ សាវតា ............ ១
១.២ រចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ ............ ១
១.២.១ ការងារ និងសមាសភាពក្រុមប្រឹក្សា ............ ២
១.២.២ ការងារ និងសមាសភាពគណៈកម្មាធិការសម្របសម្រួលស្ថិតិ ............ ៣
១.៣ ច្បាប់ និងអនុក្រឹត្យស្ថិតិ ............ ៤
១.៣.១ ច្បាប់ស្តីពីស្ថិតិ ............ ៤
១.៣.២ អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ............ ៥
១.៣.៣ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ............ ៦
**២ សកម្មភាពប្រចាំឆ្នាំ២០២២** ............ ៧
២.១ ក្រុមប្រឹក្សាស្ថិតិ ............ ៨
២.១.១កិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ ............ ៧
២.២ គណៈកម្មាធិការសម្របសម្រួលស្ថិតិ ............ ៧
២.២.១ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិឆ្នាំ២០២២ ............ ៨
២.៣ សកម្មភាពគណៈកម្មាធិការសម្របសម្រួលស្ថិតិឆ្នាំ២០២២ ............ ៨
២.៣.១ របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០២១/២០២២ ............ ៨
២.៣.២ របាយការណ៍ការចុះបញ្ជីអង្គភាពសេដ្ឋកិច្ចឆ្នាំ២០២១ ............ ១២
២.៣.៣ របាយការណ៍ការបឋមជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ............ ១៣
**៣ ប្រព័ន្ធស្ថិតិជាតិឆ្នាំ២០២២** ............ ១៤
៣.១ ការចំណាយ និងមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិឆ្នាំ២០២២ ............ ១៥
៣.២ ស្ថិតិដែលបានផលិត ............ ១៦
៣.៣ ការបែងចែកតាមតំបន់ ............ ១៧
**៤ ស្ថិតិផ្លូវការដែលបានចាត់តាំងឆ្នាំ២០២២** ............ ១៨
៤.១ វិទ្យាស្ថានជាតិស្ថិតិ ............ ១៩
៤.២ ទីស្តីការគណៈរដ្ឋមន្ត្រី ............ ២១
៤.៣ ក្រសួងមហាផ្ទៃ ............ ២២
៤.៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ............ ២៣
៤.៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ............ ២៤

៤.៦ ក្រសួងអភិវឌ្ឍន៍ជនបទ ..... ២៥
៤.៧ ក្រសួងពាណិជ្ជកម្ម ..... ២៧
៤.៨ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ..... ២៩
៤.៩ ក្រសួងរ៉ែនិងថាមពល ..... ៣០
៤.១០ ក្រសួងអប់រំ យុវជន និងកីឡា ..... ៣០
៤.១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ..... ៣១
៤.១២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... ៣២
៤.១៣ ក្រសួងបរិស្ថាន ..... ៣៣
៤.១៤ ក្រសួងធនធានទឹក និងឧតុនិយម ..... ៣៤
៤.១៥ ក្រសួងព័ត៌មាន ..... ៣៥
៤.១៦ ក្រសួងយុត្តិធម៌ ..... ៣៦
៤.១៧ ក្រសួងអធិការកិច្ច ..... ៣៧
៤.១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ..... ៣៨
៤.១៩ ក្រសួងសុខាភិបាល ..... ៣៩
៤.២០ ក្រសួងសាធារណការ និងដឹកជញ្ជូន ..... ៤០
៤.២១ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ..... ៤១
៤.២២ ក្រសួងទេសចរណ៍ ..... ៤៣
៤.២៣ ក្រសួងធម្មការ និងសាសនា ..... ៤៤
៤.២៤ ក្រសួងកិច្ចការនារី ..... ៤៥
៤.២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ..... ៤៦
៤.២៦ ក្រសួងមុខងារសាធារណៈ ..... ៤៧
៤.២៧ រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល ..... ៤៧
៤.២៨ ធនាគារជាតិនៃកម្ពុជា ..... ៤៨
៤.២៩ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ..... ៤៩
៤.៣០ ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល ..... ៥០
**ឧបសម្ព័ន្ធ១៖** ស្ថានភាពបច្ចុប្បន្ន និងចំណាយសរុបនៃការអង្កេតក្នុងប្រព័ន្ធស្ថិតិជាតិ ..... ៥២
**ឧបសម្ព័ន្ធ២៖** ប្រភេទប្រភពទិន្នន័យ ឯកតារាយការណ៍កម្រិតតំបន់ និងពេលចេញផ្សាយ ..... ៥៩
**ឧបសម្ព័ន្ធ៣៖** ច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិ ..... ៦៧
**ឧបសម្ព័ន្ធ៤៖** បញ្ជីសំណួរម៉េតាទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំង ..... ១០៩

# សង្ខេប


របាយការណ៍លើកទីប្រាំបួនស្តីពីប្រព័ន្ធស្ថិតិជាតិកម្ពុជាដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិបានផ្តល់នូវទិដ្ឋភាពទូទៅមួយនៃប្រព័ន្ធសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា និងសកម្មភាពដែលបានអនុវត្តនៅឆ្នាំ២០២២។ ប្រព័ន្ធស្ថិតិជាតិគឺជាប្រព័ន្ធវិមជ្ឈការ ដែលមានអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំងចំនួន៣០។ ច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធចំនួនពីរបានគ្រប់គ្រងការងារទាំងអស់ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ។ម្យ៉ាងទៀតច្បាប់ស្ថិតិថ្មីក៏បានធ្វើវិសោធនកម្មចូលជាធរមាន កាលពីថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៥។

នៅឆ្នាំនេះ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិចំនួនពីរលើក ដោយបានធ្វើឡើងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០២២ និងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០២២។ ចំណុចសំខាន់ៗនៃរបៀបវារៈក្នុងកិច្ចប្រជុំនេះគឺ -ការអានសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាស្ថិតិ -របាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពការងារស្ថិតិ -របាយការណ៍លទ្ធផលចុងក្រោយស្តីពីការវិភាគសន្តិសុខស្បៀងដោយប្រើទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ច-របាយការណ៍លទ្ធផលបឋមនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០២១ -របាយករណ៍ចុងក្រោយស្តីពីលទ្ធផលស្រង់បញ្ជីអង្គភាពសេដ្ឋកិច្ចនៃជំរឿនសេដ្ឋកិច្ចឆ្នាំ ២០២១ -របាយការណ៍លទ្ធផលបឋមស្តីពីជំរឿនសេដ្ឋកិច្ចឆ្នាំ ២០២២។

ដោយឡែកកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតក៏បានធ្វើឡើងចំនួនពីរលើកដែរ ដោយការប្រជុំលើកទីមួយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ និងលើកទីពីរនៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២២។ កម្មវត្ថុចម្បងនៃកិច្ចប្រជុំនេះគឺ ក្រសួងផែនការ បានរៀបចំដាក់បញ្ចូលរបាយការណ៍ជំរឿន អង្កេត និងទិន្នន័យផ្សេងៗទៀតចូលក្នុងរបៀបវារៈនៃ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល ស្ថិតិ និងដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់មតិយោបល់មុននឹងធ្វើការផ្សព្វផ្សាយជាផ្លូវការ។

# ១.ប្រព័ន្ធស្ថិតិជាតិកម្ពុជា

## ១.១ សាវតា

ប្រព័ន្ធស្ថិតិជាតិត្រូវបានឱ្យនិយមន័យនៅក្នុងច្បាប់ស្តីពីស្ថិតិថ្មី(មាត្រា៤) ដែលបានចូលជរមាននៅខែធ្នូ ឆ្នាំ២០១៥ បានចែងថា៖ ប្រព័ន្ធស្ថិតិជាតិជាសមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិរួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិរចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។

វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់រាល់ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិ។

វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចទទួលខុសត្រូវលើការសម្របសម្រួលប្រព័ន្ធដើម្បីរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថិតិផ្លូវការ ដើម្បីចងក្រងផែនការបោះពុម្ពប្រចាំឆ្នាំ និងរក្សាការចុះបញ្ជីរបស់អង្គភាពស្ថិតិ និងផលិតផលរបស់ពួកគេ ដោយផលិតផលស្ថិតិទាំងនេះមានលក្ខណៈវិមជ្ឈការ។

លក្ខណៈនៃប្រព័ន្ធតាមបែបវិមជ្ឈការរួមមានដូចខាងក្រោម៖

- អង្កេតដែលត្រូវធ្វើនិងអថេរដែលត្រូវប្រើប្រាស់ត្រូវបានសម្រេចនៅតាមស្ថាប័នផ្សេងគ្នា
- ប្រព័ន្ធចំណាត់ថ្នាក់វិធីសាស្ត្រនិងស្តង់ដារអាចខុសគ្នានៅក្នុងប្រព័ន្ធ
- លក្ខខណ្ឌនិងទស្សនទានត្រូវបានសម្រេចនៅតាមស្ថាប័នខុសគ្នា
- គោលការណ៍នៃបទបង្ហាញផ្សេងគ្នានៅតាមស្ថាប័នខុសគ្នា
- ស្ថិតិត្រូវបានចេញផ្សាយនៅលើវេបសាយខុសគ្នា។

របាយការណ៍ប្រចាំឆ្នាំស្តីពីប្រព័ន្ធស្ថិតិជាតិ ជាតម្រូវការចាំបាច់ដែលបានចែងក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០៧។ យោងតាមអនុក្រឹត្យក្រៅពីវិទ្យាស្ថានជាតិស្ថិតិប្រព័ន្ធស្ថិតិជាតិរួមមាន៣០ក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា។

របាយការណ៍ប្រចាំឆ្នាំនេះគឺជារបាយការណ៍ទីប្រាំបួនដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិហើយនឹងផ្តល់នូវទិដ្ឋភាពទូទៅមួយនៃប្រព័ន្ធសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា និងសកម្មភាពទាំងឡាយដែលបានអនុវត្តនៅឆ្នាំ២០២២ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិ។

## ១.២ រចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ

អ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់មានចំនួន៣០ក្រសួងស្ថាប័ន។ ក្នុងនោះមានក្រសួង ស្ថាប័ន ចំនួន៣០ និងវិទ្យាស្ថានជាតិស្ថិតិដែលកំណត់ដោយអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។

យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការជាស្ថាប័នកណ្តាលនៅក្នុងប្រព័ន្ធស្ថិតិជាតិ ។ វិទ្យាស្ថានជាតិស្ថិតិ គឺ

ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ជាមួយការទទួលខុសត្រូវក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់រាល់ស្ថិតិផ្លូវការដែលបានចាត់តាំង និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ បន្ថែមពីលើវិទ្យាស្ថានជាតិស្ថិតិ ក្រសួងនីមួយៗ និងស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ដែលផលិតស្ថិតិផ្លូវការដែលបានចាត់តាំង គួរតែមានអង្គភាពស្ថិតិមួយរបស់ខ្លួនសម្រាប់ផលិតស្ថិតិ។ ទោះជាយ៉ាងណាក៏ដោយ ក៏ស្ថាប័នទាំងអស់នេះមិនសុទ្ធតែបានប្រតិបត្តិតាមច្បាប់ស្ថិតិឡើយ។ ជំនួសមកវិញក្រសួង និងស្ថាប័នមួយចំនួនបានជ្រើសយកការប្រមូល និងការផលិតស្ថិតិតាមផ្នែកទៅជាការរួមបញ្ចូលគ្នាមួយនៃការងារទៀងទាត់របស់ខ្លួន។

វិទ្យាស្ថានជាតិស្ថិតិ ក៏ទទួលខុសត្រូវក្នុងរក្សាការធ្វើបច្ចុប្បន្នកម្ម និងការអនុវត្តកម្មវិធីស្ថិតិ សម្រាប់រាជរដ្ឋាភិបាលនិងការផ្តត់ផ្គង់ទិន្នន័យសម្រាប់អ្នកប្រើប្រាស់នានានៅក្នុងប្រទេសក៏ដូចជាអង្គការអន្តរជាតិផងដែរ។

ក្រុមប្រឹក្សាស្ថិតិនិងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងនៅខែមករាឆ្នាំ២០០៧ ដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសនៃស្ថិតិផ្លូវការ និងដំណើរការអនុវត្តអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

### ១.២.១ តួនាទី និងសមាសភាពក្រុមប្រឹក្សាស្ថិតិ

ក្រុមប្រឹក្សាស្ថិតិមានសមាជិកចំនួន៣៨នាក់ ដែលប្រធានជារដ្ឋមន្ត្រីក្រសួងផែនការ និងសមាជិកជារដ្ឋលេខាធិការនិងថ្នាក់ដឹកនាំជាន់ខ្ពស់មកពីក្រសួង/ស្ថាប័នពាក់ព័ន្ធសំខាន់ៗ។ តួនាទីរបស់ក្រុមប្រឹក្សាស្ថិតិ គឺផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងផែនការ ដែលទាក់ទងនឹងការកំណត់គោលនយោបាយស្ថិតិផ្លូវការ និងតម្រូវការផ្សេងៗដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង។ ជាលម្អិតក្រុមប្រឹក្សាស្ថិតិ ត្រូវផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងផែនការទាក់ទងទៅនឹង៖

- យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍
- ការធ្វើវិសោធនកម្មណាមួយទៅលើច្បាប់ស្តីពីស្ថិតិ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធការងារស្ថិតិ
- ការកំណត់គោលនយោបាយស្ថិតិផ្លូវការ
- តម្រូវការស្ថិតិផ្លូវការ និងការផ្តល់អាទិភាពដល់គម្រោងការងារស្ថិតិ ដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលចាត់តាំង
- ការធ្វើឱ្យប្រសើរឡើងការពង្រីក និងការសម្របសម្រួលនូវប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការដែលបានចាត់តាំង សម្រាប់គោលបំណងសាធារណៈ
- កម្មវិធីការងារស្ថិតិអាទិភាពរយៈពេល១ឆ្នាំរយៈពេលមធ្យមរយៈពេលវែងរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងដែលទាក់ទងក្នុងការផលិតស្ថិតិផ្លូវការផែនការមេស្ថិតិ
- ការកំណត់កាលបរិច្ឆេទនៃការធ្វើជំរឿនប្រជាពលរដ្ឋ ជំរឿនកសិកម្ម និងជំរឿនសហគ្រាស ការងារផ្សេងៗដែលទាក់ទងជាទូទៅនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

- ការស្វែងរកជំនួយ និងការគាំទ្រធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលត្រូវការដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីធ្វើជំរឿន អង្កេតផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការសម្រាប់គោលបំណងសាធារណៈ។

ក្រុមប្រឹក្សាស្ថិតិត្រូវបានបង្កើតឡើងយោងតាមមាត្រា១៦ នៃច្បាប់ស្តីពីស្ថិតិនិងសមាសភាពដែលបានកំណត់ក្នុងមាត្រា១៥នៃអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

## ១.២.២ ភារកិច្ច និងសមាសភាពគណៈកម្មាធិការសម្របសម្រួលស្ថិតិ

គណៈកម្មាធិការសម្របសម្រួលស្ថិតិមានសមាជិកចំនួន៣៦នាក់ដែលមានប្រធានគណៈកម្មាធិការជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងសមាជិកជាប្រធាន ឬអនុប្រធានអង្គភាពស្ថិតិទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង។ មុខងាររបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ គឺជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការងារពាក់ព័ន្ធទៅនឹងការរៀបចំគោលនយោបាយស្ថិតិ នីតិវិធី និងច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការ។ គណៈកម្មាធិការសម្របសម្រួលស្ថិតិ អាចបង្កើតក្រុមការងារបច្ចេកទេសស្ថិតិដើម្បីដោះស្រាយការងារបច្ចេកទេសស្ថិតិណាមួយ ដែលទាមទារការសិក្សានិងការពិភាក្សាលម្អិតបន្ថែម។ ជាលម្អិតគណៈកម្មាធិការសម្របសម្រួលស្ថិតិមានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការងារពាក់ព័ន្ធទៅនឹង៖

- ការរៀបចំនិងធ្វើបច្ចុប្បន្នកម្មសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ
- ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិនិងស្ថិតិផ្លូវការ
- ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពលើសកម្មភាពស្ថិតិ និងការអភិវឌ្ឍស្ថិតិរវាងអង្គភាពស្ថិតិដែលបានចាត់តាំងរួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវ ក្នុងការផលិត និងការផ្សព្វផ្សាយស្ថិតិផ្លូវការ
- ការធ្វើអោយប្រសើរឡើង និងការពង្រឹកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលផ្តល់សម្រាប់គោលដៅសាធារណៈ
- ការលើកអាទិភាពនៃកម្មវិធីការងារប្រចាំឆ្នាំរយៈពេលមធ្យម និងរយៈពេលវែងដែលគួរត្រូវបានជ្រើសរើសទាក់ទងនឹងទិដ្ឋភាពសំខាន់ៗ នៃការផ្តល់ស្ថិតិផ្លូវការដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង
- ការរៀបចំ និងធ្វើបច្ចុប្បន្នកម្មផែនការមេស្ថិតិ
- ការរៀបចំផែនការធ្វើជំរឿនប្រជារាស្ត្រជំរឿន កសិកម្ម និងជំរឿនសហគ្រាស
- ការបង្កើតនូវបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសុរបបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាព និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ
- កិច្ចព្រមព្រៀងសហប្រតិបត្តិការ កិច្ចសម្របសម្រួល រវាងបណ្តាក្រសួងស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូរទិន្នន័យនិងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឱ្យបានទៀងទាត់និងគួរជឿទុកចិត្តបាន
- ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិរយៈពេលកំណត់ ឬអចិន្ត្រៃយ៍សម្រាប់ស្ថិតិណាមួយ

ឬការងារស្ថិតិផ្សេងទៀតដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

- ការប្រកាសប្រើ និងការអនុវត្តនូវចំណាត់ថ្នាក់និងបទដ្ឋានស្ថិតិដែលទាក់ទងនឹងស្ថិតិផ្លូវការ
- ការលើកផែនការថវិកា និងធនធានមនុស្សសម្រាប់អង្គភាពស្ថិតិ ដែលបានចាត់តាំងរួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿននិងអង្កេតផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការសម្រាប់គោលដៅសាធារណៈ។

គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានបង្កើតឡើងយោងតាម មាត្រា១៦ នៃច្បាប់ស្តីពីស្ថិតិ និងសមាសភាពដែលបានកំណត់ក្នុងមាត្រា១៧នៃអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

## ១.៣ ច្បាប់ និងអនុក្រឹត្យស្ថិតិ

ច្បាប់ស្តីពីស្ថិតិបានចូលជាធរមាននៅថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៥។ ច្បាប់នេះមានគោលបំណងគ្រប់គ្រងរាល់ការងារទាំងឡាយដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ ហើយមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ នៅក្រោមច្បាប់មានអនុក្រឹត្យចំនួនពីរដែលកំណត់ការងារសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វិទ្យាស្ថានជាតិស្ថិតិ ក៏មានអនុក្រឹត្យស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិដែលមិនបានពិពណ៌នាក្នុងរបាយការណ៍នេះ។

វាក្យស័ព្ទបច្ចេកទេសដែលត្រូវបានប្រើក្នុងច្បាប់ត្រូវបានបង្ហាញក្នុងមាត្រា៤ នៃច្បាប់ស្តីពីស្ថិតិនិងមាត្រា៣ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។ វាក្យស័ព្ទមួយចំនួនត្រូវបានបង្ហាញក្នុងឯកសារទាំងពីរ។

### ១.៣.១ ច្បាប់ស្តីពីស្ថិតិ

ក្រៅពីកំណត់ក្របខ័ណ្ឌសម្រាប់ការងារដែលច្បាប់ស្តីពីស្ថិតិគ្រប់គ្រង និងប្រភពធនធានហិរញ្ញវត្ថុ ច្បាប់ក៏ពិពណ៌នានូវវាក្យស័ព្ទបច្ចេកទេស គោលការណ៍ និងទិសដៅសម្រាប់អ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំងផងដែរ។

ចំពោះការងារសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដែលបានចែងក្នុងច្បាប់ស្តីពីស្ថិតិ កំណត់ថា វិទ្យាស្ថាជាតិស្ថិតិក្រោមឱវាទក្រសួងផែនការ មានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួងស្ថាប័ន។ រាល់កិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំងត្រូវបានកំណត់ដោយអនុក្រឹត្យ។

ច្បាប់ស្តីពីស្ថិតិកំណត់ថា ក្រុមប្រឹក្សាស្ថិតិត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ (មាត្រា១៦) និងគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានបង្កើតឡើង ដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល(មាត្រា១៩)។ ម្យ៉ាងវិញទៀតសមាសភាពតួនាទីភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានកំណត់ដោយអនុក្រឹត្យនៃ(មាត្រា២២)ផងដែរ។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការត្រូវរៀបចំថវិកាចំណាយប្រចាំឆ្នាំសម្រាប់ដំណើរការផលិតនិងការផ្សព្វផ្សាយទិន្នន័យស្ថិតិ ដោយដាក់សុំការសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សាស្ថិតិមុននឹងបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួងផែនការ។

ទិន្នន័យស្ថិតិផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ទាំងអស់ និងត្រូវរក្សាឃ្លាំងទិន្នន័យទាំងឡាយដែលមានទិន្នន័យផ្ដុំអាចសាធារណជនទូទៅរកបានតាមប្រព័ន្ធអ៊ីនធឺណិត (មាត្រា២៣) រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិគឺជាស្ថិតិផ្លូវការដែលបានចាត់តាំង(មាត្រា២៤)។

ការសម្ងាត់របស់ទិន្នន័យត្រូវបានកំណត់ក្នុងមាត្រា៣០(ក្នុងច្បាប់ស្ថិតិ)បានចែងថាវិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយដែលបានមកពីអ្នកឆ្លើយតប។ ព័ត៌មានដែលប្រមូលបានស្ថិតក្រោមច្បាប់នេះត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិតែប៉ុណ្ណោះ។

### ១.៣.២ អនុក្រឹត្យស្ដីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

អនុក្រឹត្យស្ដីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិគ្រប់គ្រង រាល់ការងាររៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិកាតព្វកិច្ចស្ថិតិ និងការងារទាំងឡាយ ដើម្បីអនុវត្តច្បាប់ស្ដីពីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវលើការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្ដប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់របស់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិខេត្តក្រុងស្រុកខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំសង្កាត់។

រចនាសម្ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិរួមមាន វិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលបានចាត់តាំងនិងមន្ត្រីធ្វើការក្នុងអង្គភាពទាំងនោះ។

ការបង្កើត និងទិសដៅរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យជាឧទាហរណ៍ៈ សមាសភាពនិងភាពទៀងទាត់នៃការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ។ ក្នុងនោះគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានកំណត់តាមលក្ខខណ្ឌដូចគ្នាផងដែរ។ ម្យ៉ាងទៀតសមាជិកក្រុមប្រឹក្សាស្ថិតិ និងសមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

អនុក្រឹត្យក៏បានចែងពីការរក្សាការសម្ងាត់នៃលទ្ធផលផងដែរ។ គ្មានលទ្ធផលឬសម្រង់សង្ខេបត្រូវបានបោះពុម្ព ឬផ្សព្វផ្សាយតាមរបៀបដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពឡើយ។

### ១.៣.៣ អនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំង

អនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំង បានកំណត់ឱ្យក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលប្រមូលនិងចងក្រងស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ខ្លួន និងគ្រប់គ្រងរាល់ស្ថិតិផ្លូវការដែលបានចាត់តាំង និងអង្គភាពស្ថិតិផ្លូវការដែលបានចាត់តាំងដូចមានចែងក្នុងច្បាប់ស្ដីពីស្ថិតិ។

អនុក្រឹត្យមានគោលបំណងបម្រើសំណូមពររបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំ និងវាយតម្លៃគោលនយោបាយព្រមទាំងលើវិស័យសេដ្ឋកិច្ច សង្គម ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសក៏ដូចជាព័ត៌មានផ្សេងៗ ដើម្បីបម្រើសេចក្តីត្រូវការរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិឱ្យមានលក្ខណៈទូលំទូលាយ។

យោងតាមមាត្រាទី៤នៃអនុក្រឹត្យ គ្រប់ទិន្នន័យស្ថិតិទាំងអស់ដែលបានប្រកាសផ្សព្វផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិមានកាតព្វកិច្ចផ្សព្វផ្សាយដល់សាធារណជននូវស្ថិតិគ្រឹះនិងស្ថិតិតាមវិស័យទោះបីផលិតដោយខ្លួនឯងឬដោយការសហការជាមួយអង្គភាពស្ថិតិផ្សេងទៀតរបស់រាជរដ្ឋាភិបាលដែលមានដូចជា៖

- ស្ថិតិជំរឿន
- ស្ថិតិអង្កេត
- ស្ថិតិសេដ្ឋកិច្ច
- ស្ថិតិបរិស្ថាននិងធនធានធម្មជាតិ
- ស្ថិតិសង្គមកិច្ចប្រជាសាស្ត្រ
- កម្រងស្ថិតិ
- ប្រព័ន្ធទិន្នន័យស្ថិតិក្រុមសង្កេតភពផែនដី
- ប្រព័ន្ធទិន្នន័យសូចនាករអភិវឌ្ឍន៍

តាមអនុក្រឹត្យបានកំណត់ថា អង្គភាពស្ថិតិដែលត្រូវទទួលខុសត្រូវលើការផលិតស្ថិតិ មានចំនួនទាំងអស់៣០ក្រសួងស្ថាប័នរាជរដ្ឋាភិបាលដោយរាប់បញ្ចូលទាំងធនាគារជាតិនៃកម្ពុជាមានភារកិច្ចទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំងក្រៅពីស្ថិតិដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ។

ការគ្រប់គ្រងទិន្នន័យ និងប្រភពប្រមូលទិន្នន័យត្រូវបានកំណត់ក្នុងជំពូកទី៤នៃអនុក្រឹត្យ។ រាល់ការប្រមូលទិន្នន័យដែលមានស្រាប់ត្រូវចុះបញ្ជីនៅវិទ្យាស្ថានជាតិស្ថិតិ។ ការប្រមូលទិន្នន័យ ដែលបានគ្រោងទុកនិងថ្មីក៏ត្រូវចុះបញ្ជីផងដែរមុននឹងចាប់ផ្តើមអនុវត្តការងារ។ បញ្ជីរាល់ការប្រមូលទិន្នន័យ ដែលមានស្រាប់ការចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យនីមួយៗត្រូវបញ្ជូនទៅដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីជារៀងរាល់ឆ្នាំ។

អង្គភាពស្ថិតិដែលបានចាត់តាំង នៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវដាក់ជូននូវរាល់ព័ត៌មាន និងទិន្នន័យស្ថិតិ ដែលផលិតបានជាទម្រង់អេឡិចត្រូនិក និងជាសៀវភៅក្តី ដល់វិទ្យាស្ថានជាតិស្ថិតិ និងទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

វិទ្យាស្ថានជាតិស្ថិតិ ត្រូវបង្កើត និងថែរក្សាទុកនូវបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាលនិងស្ថិតិដោយផ្អែកលើការប្រមូលព័ត៌មានម៉េតាទិន្នន័យតាមរយៈដំណើរការចុះបញ្ជី។ បញ្ជីឈ្មោះម៉េតាទិន្នន័យ ត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ និងប្រកាសផ្សាយតាមគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

# ២. សកម្មភាពឆ្នាំ ២០២២

## ២.១ ក្រុមប្រឹក្សាស្ថិតិ

ក្រុមប្រឹក្សាស្ថិតិត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៧ ដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ។ សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

### ២.១.១ កិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ ឆ្នាំ២០២២

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ បានធ្វើឡើងចំនួន០២លើក នៅក្នុងឆ្នាំ២០២២ ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

កិច្ចប្រជុំលើកទី៩នៅថ្ងៃទី១២ខែកញ្ញាឆ្នាំ២០២២បានផ្តោតលើចំណុចសំខាន់នៃរបៀបវារៈដូចខាងក្រោម៖

- ការអានសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាស្ថិតិ
- របាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពការងារស្ថិតិ
- របាយការណ៍លទ្ធផលចុងក្រោយស្តីពីការវិភាគសន្តិសុខស្បៀងដោយប្រើទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច។

កិច្ចប្រជុំលើកទី១០ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ បានផ្តោតលើចំណុចសំខាន់នៃរបៀបវារៈដូចខាងក្រោម៖

- របាយការណ៍លទ្ធផលបឋមនៃអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២១
- របាយការណ៍ចុងក្រោយស្តីពីលទ្ធផលស្រង់បញ្ជីអង្គភាពសេដ្ឋកិច្ចនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២១
- របាយការណ៍លទ្ធផលបឋមស្តីពីជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២

ការងារស្ថិតិគឺជាការងារដ៏សំខាន់មិនអាចខ្វះបាន មានស្ថិតិទើបមានផែនការមានគោលនយោបាយមានមូលដ្ឋានផ្តល់ឱ្យការគណនាអត្រាភាពក្រីក្រ កំណើនសេដ្ឋកិច្ច អតិផរណា និងវាស់វែងការសម្រេចបាននៃការអនុវត្តផែនការជាតិ និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ជារួម គឺមានស្ថិតិទើបមានការអភិវឌ្ឍ ដើម្បីធ្វើឱ្យកិច្ចអភិវឌ្ឍន៍ស្ថិតិបានរឹងមាំ និងឈានឡើងដល់កម្រិតអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ទាំងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ច្បាប់ស្តីពីស្ថិតិ និងបទប្បញ្ញត្តិស្ថិតិនានា គឺជាឧបករណ៍ដ៏សំខាន់ ។ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មានភារកិច្ចធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិរួមបញ្ចូលគ្នាតែមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិតាមបណ្តាក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល។

## ២.២ គណៈកម្មាធិការសម្របសម្រួលស្ថិតិ

គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧ដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការសម្របសម្រួលបច្ចេកទេសនៃស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល។ សមាសភាពតួនាទី និងភារកិច្ច

របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

### ២.២.១ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ ឆ្នាំ២០២២

កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិមានចំនួនពីរលើក នៅក្នុងឆ្នាំ ២០២២។ កិច្ចប្រជុំលើកទី២៨ របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ និងកិច្ចប្រជុំលើកទី២៩ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។ កិច្ចប្រជុំទាំងពីរលើកនេះ អនុលោមតាមមាត្រា២០នៃអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ដែលបានកំណត់អំពីចំនួនសមាជិកសម្រាប់បើកកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសមាជិកសមាជិកាចូលរួមលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់ដែលមានសរុប៣៨រូប ទើបអង្គប្រជុំអាចដំណើរការទៅបាន។

## ២.៣ សកម្មភាពរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ឆ្នាំ២០២២

នៅក្នុងដំណាក់កាលរីករាលដាលនៃជំងឺកូវីដ១៩ទូទាំងសកលលោកហើយប្រទេសកម្ពុជាក៏មិនខុសពីប្រទេសផ្សេងៗផងដែរដោយត្រូវប្រឈមមុខក្នុងកាលៈទេសៈលំបាកនាពេលខណៈនោះ អាស្រ័យហេតុនេះហើយ ទើបវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សម្រេចបាននូវការងារតិចជាងឆ្នាំមុនៗ មានដូចជា ការចុះបញ្ជីអង្គភាពសេដ្ឋកិច្ច និងការគូរផែនទីសម្រាប់ជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ និងអង្កេតកសិកម្មប្រចាំឆ្នាំ២០២១ ដែលសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្មីៗនេះ គឺបានបញ្ចប់ការប្រមូលទិន្នន័យជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ ព្រមទាំងការងារចងក្រងទិន្នន័យផ្សេងៗទៀត។

វិទ្យាស្ថានជាតិស្ថិតិបានសហការជាមួយក្រសួងមហាផ្ទៃរៀបចំច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដោយមានការបែងចែកតួនាទីភារកិច្ចរវាងក្រសួងសុខាភិបាល និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ច្បាស់លាស់ក្នុងការប្រមូល ចងក្រងទិន្នន័យ និងផលិតចេញជា ស្ថិតិអត្រានុកូលដ្ឋានរបស់ខេត្តកែបដែលជាការសាកល្បង។ វិទ្យាស្ថានជាតិស្ថិតិក៏បាន នឹងកំពុងអនុវត្ត កិច្ចការធំៗបម្រើឱ្យអ្នកប្រើប្រាស់ទិន្នន័យអ្នករៀបចំផែនការ អ្នកវិនិយោគ អ្នកតាក់តែងគោលនយោបាយនិងជាពិសេស បម្រើឱ្យការវាស់វែងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ដែលបណ្តាក្រសួងភាគច្រើនត្រូវការ។ ជាមួយគ្នានេះដែរ គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនឹងរៀបចំដាក់បញ្ចូលរបាយការណ៍ជំរឿន អង្កេត និងទិន្នន័យផ្សេងៗទៀតចូលរបៀបវារៈនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ ដើម្បីពិនិត្យពិភាក្សា និងផ្តល់មតិយោបល់មុននឹងធ្វើការប្រកាសផ្សព្វផ្សាយជាផ្លូវការ។

### ២.៣.១ របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២១/២០២២

ជាលទ្ធផលសង្ខេបនៃអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២១/២០២២ រួមមាន៖

**១. ចរិតលក្ខណៈប្រជាសាស្ត្រ**

ក.ចំនួនប្រជាជនចែកតាមភេទគឺមានចំនួនសរុប១៦,៥៩២,០០០(ស្ត្រី៨,៤៩៩,០០០និងបុរស៨,០៩៣,០០០) និងអនុបាតភេទ ៩៥,២។

ខ.ចំនួនគ្រួសារចែកតាមតំបន់គឺកម្ពុជាមាន៣,៨៧០,០០០(ទីប្រជុំជន១,៤៧២,០០០និងជនបទ ២,៣៩៨,០០០)

គ.គ្រួសារដែលមានស្ត្រីជាមេគ្រួសារនៃគ្រួសារសរុបគិតជាភាគរយនិងចែកតាមតំបន់គឺកម្ពុជាមាន ២១,០០០(រាជធានីភ្នំពេញ២៧,០០០ទីប្រជុំជនផ្សេងៗ ២៣,០០០ និងជនបទផ្សេងៗ ១៩,៦០០)

## ២. លំនៅដ្ឋាន

- ដំបូលលំនៅដ្ឋានធ្វើពីសម្ភារៈរឹង/អចិន្ត្រៃយ៍ ៩៩ភាគរយ
- ការកាន់កាប់លំនៅដ្ឋានតាមប្រភេទសម្ភារៈជញ្ជាំង និងបែងចែកតាមតំបន់ភូមិសាស្ត្រ ៩៦ភាគរយ
- កម្រាលលំនៅដ្ឋានធ្វើពីសម្ភារៈរឹង/អចិន្ត្រៃយ៍ ៤១ភាគរយ
- លំនៅដ្ឋាន ដែលបានកាន់កាប់បែងចែកតាមស្ថានភាពកម្មសិទ្ធិ និងតាមតំបន់ភូមិសាស្ត្រ លំនៅដ្ឋានកម្មសិទ្ធិផ្ទាល់ខ្លួន៩១,៧ភាគរយ(ភ្នំពេញ៧២,៣%ទីប្រជុំជនផ្សេងៗ៩១,៧% និងទីជនបទ ៩៦,២%) លំនៅដ្ឋានមិនមែនកម្មសិទ្ធិ តែរស់នៅមិនគិតថ្លៃ៣,៩ភាគរយ(ភ្នំពេញ៦,១%ទីប្រជុំជនផ្សេងៗ៤,២% និងទីជនបទ៣,៣%)លំនៅដ្ឋានជួលគេ៤,៣ភាគរយ(ភ្នំពេញ២១,៤%ទីប្រជុំជនផ្សេងៗ៤,១% និងទីជនបទ ០,៤%) ផ្សេងទៀត០,១ភាគរយ(ភ្នំពេញ០,២% ទីប្រជុំជនផ្សេងៗ០,០% និងទីជនបទ ០,១%)។
-ប្រភពទឹកសំខាន់ៗសម្រាប់បរិភោគ បែងចែកតាមតំបន់ភូមិសាស្ត្រ ប្រភពទឹកបានកែលម្អ ៨៧,០ភាគរយ (ភ្នំពេញ៩៧,៩% ទីប្រជុំជនផ្សេងៗ ៩១,៦% និងទីជនបទ ៨២,៧%)ប្រភពទឹកមិនបានកែលម្អ ១៣,០ ភាគរយ (ភ្នំពេញ ២,១% ទីប្រជុំជនផ្សេងៗ ៨,៤% និងទីជនបទ ១៣,៣%)។
- បង្គន់អនាម័យបែងចែកតាមតំបន់ភូមិសាស្ត្របង្គន់អនាម័យបានកែលម្អ ៨៨,០ភាគរយ(ភ្នំពេញ ៩៧,៨% ទីប្រជុំជនផ្សេងៗ ៩៣,៣% និងទីជនបទ ៨៣,៧%)បង្គន់គ្មានអនាម័យ មិនបានកែលម្អ ១២,០ភាគរយ (ភ្នំពេញ ២,២% ទីប្រជុំជនផ្សេងៗ ៦,៧% និងទីជនបទ ១២,៣%)។

ការប្រើប្រាស់ទឹកសម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះ បែងចែកតាមតំបន់ភូមិសាស្ត មានទឹកនៅកន្លែងលាងដៃ៩៨,៤ភាគរយ(ភ្នំពេញ៩៥,៥% ទីប្រជុំជនផ្សេងៗ៩៩,៣% និងទីជនបទ៩៨,៧%)គ្មានទឹកនៅកន្លែងលាងដៃ ១,៦ភាគរយ (ភ្នំពេញ ៤,៥% ទីប្រជុំជនផ្សេងៗ ០,៧% និងទីជនបទ ១,៣%) មានសាប៊ូនៅកន្លែងលាងដៃ ៩៣,៦ភាគរយ(ភ្នំពេញ ៩៤,៩%, ទីប្រជុំជនផ្សេងៗ ៩៣,៥% និងទីជនបទ៩៣,៤%) គ្មានសាប៊ូនៅកន្លែងលាងដៃ ៦,៤ភាគរយ (ភ្នំពេញ ៥,១%, ទីប្រជុំជនផ្សេងៗ ៦,៥% និងទីជនបទ ៦,៦%) មានទឹកនិងសាប៊ូនៅកន្លែងលាងដៃ ៨៧,២ភាគរយ(ភ្នំពេញ៩០,០% ទីប្រជុំជនផ្សេងៗ៩០,១% និងទីជនបទ ៨៥,៤%)គ្មានទឹកនិងសាប៊ូនៅកន្លែងលាងដៃ១២,៨ភាគរយ(ភ្នំពេញ១០,០%ទីប្រជុំជនផ្សេងៗ ៩,៩% និងទីជនបទ ១៤,៦%)។

-ប្រភពថាមពលអគ្គិសនីផ្គត់ផ្គង់សាធារណៈ/អគ្គិសនីរដ្ឋសម្រាប់បំភ្លឺគឺមាន ៩១ភាគរយ
- ប្រភេទឥន្ធនៈសំខាន់ៗសម្រាប់ចម្អិនអាហារគឺមាន៖ អុស ៥០ភាគរយ និងឧស្ម័ន ៤៣ភាគរយ

## ៣. ផ្នែកកសិកម្ម

-ផ្ទៃដីកសិកម្មសរុបចំនួន៤,០៦៩ពាន់ហិកតាហើយមានប្រមាណ១០ភាគរយ(៤២៣ពាន់ហិកតា)កាន់កាប់ដោយមេគ្រួសារជាស្ត្រី។

-ផ្ទៃដីកសិកម្មបែងចែកតាមប្រភេទដី និងតំបន់ រួមមាន៖ ផ្ទៃដីរដូវវស្សា ៥០,២ភាគរយ ដីសួនដំណាំ ១៥,៩ភាគរយ ដីចម្ការ ១១,៣ភាគរយ ផ្ទៃដីរដូវវស្សា និងប្រាំង ៩,៦ភាគរយ ផ្ទៃដីរដូវប្រាំង ៩,១ភាគរយ ដីទំនេរ (មិនប្រើការ) ៣,៧ភាគរយ ដីដំណាំអចិន្ត្រៃយ៍ ០,១ភាគរយ ដីព្រៃឈើឯកជន ០,០ភាគរយ និងដីដទៃទៀត ០,០ភាគរយ។

-ផ្ទៃដីកសិកម្មបែងចែកតាមការស្រោចស្រព និងតាមតំបន់ រួមមាន៖ ការស្រោចស្រពនៅរដូវវស្សា ២៦,៥ ភាគរយ ការស្រោចស្រពនៅរដូវប្រាំង ៧,៤ភាគរយ ការស្រោចស្រពទាំងពីររដូវ ១២,៤ភាគរយ និងមិនមានការស្រោចស្រព ឬបូម ៥៣,៦ភាគរយ។

-ចំនួនសកម្មភាពគ្រួសារបែងចែកតាមក្រុមផលិតផលដំណាំសំខាន់ៗ រួមមាន៖ ដំណាំធញ្ញជាតិ៦១,២ ភាគរយ ផ្លែឈើនិងដំណាំគ្រាប់១៩,៦ភាគរយ ដំណាំមើម៩,៣ភាគរយ និងដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ ៤,៥ភាគរយ។

-ថ្លៃដើមផលិតផលដំណាំដែលចំណាយដាំដុះ រួមមាន៖ វត្ថុធាតុដើមសម្រាប់ដាំដុះ ១៣,៤ភាគរយ ដីគីមី ថ្នាំសម្លាប់សត្វល្អិត ស្មៅ និងសម្លាប់ផ្សិត២៩,២ភាគរយ ថ្លៃឈ្នួលកម្លាំងអូសទាញ៨,៧ភាគរយ ថ្លៃឈ្នួលពលកម្មផ្សេងៗ ២៨,៧ភាគរយ និងតម្លៃផ្សេងៗ ១៩,៩ភាគរយ។

-ចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សី បែងចែកតាមតំបន់គឺ កម្ពុជា៥១,២ភាគរយ (រាជធានីភ្នំពេញ ១,៦% តំបន់វាលទំនាប៥៧,៥% តំបន់ទន្លេសាប៥៨,៣% តំបន់ឆ្នេរសមុទ្រ៦០,២% និងតំបន់ភ្នំ និងខ្ពង់រាប ៦៥,៨%)។

- ចំនួនបសុសត្វ និងបសុបក្សីបែងចែកតាមតំបន់ រួមមាន៖ មាន់មានជាង ៦០ភាគរយ ទាមានជិត២០ ភាគរយ សត្វផ្សេងៗមានជាង១០ភាគរយ និងសត្វគោប្រហែល៥ភាគរយ។

- ចំនួនគ្រួសារចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី និងនេសាទបែងចែកតាមភេទនៃមេគ្រួសារ និងតាមតំបន់ កម្ពុជា(បុរស៣៨,២% និងស្ត្រី២៣,៤%) រាជធានីភ្នំពេញ(បុរស០,៣% និងស្ត្រី០,២% )តំបន់វាលទំនាប(បុរស៣២,៧% និងស្ត្រី ២១,៣%) តំបន់ទន្លេសាប(បុរស៥២,២% និងស្ត្រី៣៤,០%)តំបន់ឆ្នេរសមុទ្រ(បុរស ៤៨,៨% និងស្ត្រី ៣៧,២%) តំបន់ភ្នំ និងខ្ពង់រាប(បុរស ៥១,៤% និងស្ត្រី ៣៤,៩%)។

- ចំនួនសកម្មភាពនៃការរកផលិតផលព្រៃឈើ និងការបរបាញ់សត្វ បែងចែកតាមប្រភេទសកម្មភាព និងតាមតំបន់ រួមមាន៖ អុស៣៩,៥ភាគរយ វល្លិផ្តៅ ឫស្សីស្លឹកត្នោត រុក្ខជាតិសរសៃ ៤,០ភាគរយ ដំណាំមើម ផ្លែឈើ និងបន្លែ ៤៥,៩ភាគរយ រុក្ខជាតិក្លិនក្រអូបប្រើជាគ្រឿងសម្ល ធ្វើថ្នាំ ឬគ្រឿង ៥,៣ភាគរយ និងផលិតផលផ្សេងៗ ៥,៣ភាគរយ។

## ៤. ការសិក្សាអប់រំ

-អត្រាអក្ខរកម្មសម្រាប់ប្រជាជនពេញវ័យ(អាយុចាប់ពី១៥ឆ្នាំឡើង)បែងចែកតាមតំបន់ភូមិសាស្ត្រ និងតាមភេទកម្ពុជា(បុរស៨៩,៥% និងស្ត្រី៨០,៣%) រាជធានីភ្នំពេញ(បុរស៩៣,៩% និងស្ត្រី៩១,០%) ទីប្រជុំជនផ្សេងៗ(បុរស៩៣,០% និងស្ត្រី៨៤,៩% ទីជនបទ(បុរស៨៦,៧% និងស្ត្រី៧៥,៣% )។

## ៥. កម្លាំងពលកម្ម

- អត្រាចូលរួមកម្លាំងពលកម្ម ៨៣,៧ភាគរយ

- អត្រាកម្មភាព ៨២,៨ភាគរយ

- អត្រានិកម្មភាព ១,០ភាគរយ
-ស្ថានភាពការងារ មុខរបរចម្បងរបស់ប្រជាជនដែលមានអាយុ(១៥-៦៨ឆ្នាំ) និយោជិកទទួលប្រាក់ឈ្នួល ៤៨,៧ភាគរយ និយោជក០,១ភាគរយ អ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន៣៦,០ភាគរយ អ្នកធ្វើការឱ្យគ្រួសារគ្មានប្រាក់ឈ្នួល១៥,១ភាគរយ ផ្សេងៗ ០,១ភាគរយ។
-អ្នកមានការងារធ្វើ ក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ចរួមមាន៖ វិស័យកសិកម្ម៣៥,៧ភាគរយ ឧស្សាហកម្ម២៧,៣ភាគរយ និងសេវាកម្ម ៣៧,០ភាគរយ។

## ៦. សុខភាព និងជនមានពិការភាព

-មានជំងឺ របួសស្នាម ឬបញ្ហាសុខភាពផ្សេងៗក្នុងរយៈពេល៣០ថ្ងៃកន្លងមកបែងចែកតាមតំបន់ ភូមិសាស្ត្រ និងតាមភេទកម្ពុជា(បុរស១២% និងស្ត្រី១៧%) រាជធានីភ្នំពេញ(បុរស៦% និងស្ត្រី៧%) ទីប្រជុំជនផ្សេងៗ (បុរស១៣% និងស្ត្រី១៧% ទីជនបទ(បុរស១៤% និងស្ត្រី ១៩%)។
- ជំងឺរបួសក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមតំបន់ភូមិសាស្ត្រគឺ កម្ពុជា១៤,៧ភាគរយ (ទីប្រជុំជនផ្សេងៗ ១១,៨% និងទីជនបទ១៦,៦%)។

## ៧. ការទទួលរងគ្រោះ

-គ្រួសារដែលទទួលរងគ្រោះរួមមាន៖ ចោរកម្ម(លួច ឆក់ ប្លន់)១,៣៨ភាគរយ និងឧបទ្ទវហេតុនានា៣,០២ភាគរយ។
-ព្រឹត្តិការណ៍អំពើហិង្សាបែងចែកតាមប្រភេទនៃអំពើហិង្សារួមមាន៖ ដាល់ ទាត់ វាយនឹងវត្ថុ ៤៧ភាគរយ ទះ ឬរុញច្រាន ៣៦ភាគរយ ប្រើ ឬគំរាមនឹងកាំបិត ឬដោយអាវុធផ្សេងទៀត១៣ភាគរយ ធ្វើឱ្យថប់ដង្ហើម យកវត្ថុគ្របមុខ ព្យាយាមចាប់ជ្រមុជទឹក ឬដុតដោយចេតនា២ភាគរយ ផ្សេងៗ១ភាគរយ ដាក់សម្ពាធ (ដោយមិនប្រើកម្លាំងបាយ) ដើម្បីឱ្យអ្នករួមរ័កតាមវិធីណាមួយនៅពេលដែលអ្នកមិនចង់ ហើយការរួមរ័ក ០,៥ភាគរយ និងព្យាយាមធ្វើឱ្យអ្នករួមរ័កតាមវិធីណាមួយដោយគ្មានការអនុញ្ញាតពីអ្នក០,៥ភាគរយ។

## ៨. ប្រាក់ចំណូល និងបំណុលគ្រួសារ

-សមាសធាតុនៃប្រភពចំណូលគ្រួសារប្រចាំខែគិតជាមធ្យមរួមមាន៖ ប្រាក់ចំណូលបង្វែរចរន្ត៩ភាគរយ ចំណូលពីការវិនិយោគមូលធន០,៥ភាគរយ ការងារប្រើទុនផ្ទាល់ខ្លួន៤០,៥ភាគរយ និងប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល ៥០ភាគរយ។
-ប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃមធ្យមមេដ្យានក្នុងមួយខែ(គិតជាពាន់រៀល)កម្ពុជា ៤៣១ រាជានីភ្នំពេញ៦៤៨ ទីប្រជុំជនផ្សេងៗ៥១៤ ទីជនបទផ្សេងៗ៣៥៨ ចំនួនគ្រួសារបានជំពាក់បំណុលបែងចែកតាមតំបន់ភូមិសាស្ត្រកម្ពុជា ៣៣,២ភាគរយ រាជានីភ្នំពេញ២១,៥ភាគរយ ទីប្រជុំជនផ្សេងៗ៥១៤ ៣៦,១ភាគរយ ទីជនបទផ្សេងៗ៣៤,៧ភាគរយ។
-ប្រភពប្រាក់កម្ចីនៃគ្រួសារកម្ពុជាផ្អែកតាមសមតុល្យប្រាក់កម្ចីបំណុលគិតជាមធ្យម រួមមាន៖ សាច់ញាតិក្នុងប្រទេស៤,៧ភាគរយ សាច់ញាតិនៅបរទេស០,៤ភាគរយ មិត្តភ័ក្ត្រ០,៧ភាគរយ អ្នកចងការប្រាក់ ៣,៦ភាគរយ អាជីវករ០,៣ភាគរយ ម្ចាស់ដី/ម្ចាស់ផ្ទះ០,១ភាគរយ និយោជក០,១ភាគរយ ធនាគារ ៣៤,៩ភាគរយ អង្គការក្រៅរដ្ឋាភិបាល២,៤ភាគរយ និងគ្រឹះស្ថាន(ស្ថាប័ន)មីក្រូហិរញ្ញវត្ថុ/ប្រតិបត្តិករឥណទាន ៥២,២ភាគរយ។

-គោលបំណងនៃការខ្ចីប្រាក់របស់គ្រួសារកម្ពុជា ផ្អែកតាមសមតុល្យប្រាក់កម្ចីបំណុលជាមធ្យម រួមមាន៖ សកម្មភាពកសិកម្ម១៥,៣ភាគរយ សកម្មភាពមិនមែនកសិកម្ម១៥,២ភាគរយ តម្រូវការប្រើប្រាស់ក្នុងគ្រួសារ២០,០ភាគរយ ជំងឺ/របួស/គ្រោះថ្នាក់៣,២ភាគរយ ហេតុការណ៍បន្ទាន់ផ្សេងៗ(ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម)០,១ភាគរយ ពិធីតាមទំនៀមទំលាប់ប្រពៃណី(អាពាហ៍ពិពាហ៍...)១,៦ភាគរយ ទិញ/កែលំអរលំនៅដ្ឋាន១៨,៩ភាគរយ ទិញសម្ភារៈប្រើប្រាស់បានយូរ១៥,៩ភាគរយ សេវាកម្មនិងការជាប់បំណុល ៥,៧ភាគរយ និងផ្សេងៗ ៤,០ភាគរយ។

-អត្រាការប្រាក់គិតជាមធ្យមប្រចាំខែ(ប្រភពនៃប្រាក់កម្ចី)៖ ១,៥ភាគរយ(អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០២១)

-រយៈពេលសំណងគិតជាមធ្យមមកដល់ថ្ងៃត្រូវសងបំណុលអស់៖ ២៨ថ្ងៃ(អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០២១)។

### ៩. ការចំណាយប្រើប្រាស់របស់គ្រួសារ

-សមាសភាពការចំណាយប្រើប្រាស់សម្រាប់មនុស្សម្នាក់ៗគិតជាមធ្យមប្រចាំខែ ឆ្នាំ២០២១ ចំណែកជាភាគរយរួមមាន៖ ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រវឹង៤៦,៧ភាគរយ សំលៀកបំពាក់ និងស្បែកជើង២,៨ភាគរយ សង្ហារិមតុបតែងផ្ទះ...។ល។មាន០,៧ភាគរយ គមនាគមន៍៨,៧ភាគរយ ការកម្សាន្ត និងវប្បធម៌០,៩ភាគរយ ទំនិញផ្សេងៗទៀត៦,២ភាគរយ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់១,៦ភាគរយ ផ្ទះសម្បែង ទឹក អគ្គិសនី២៣,៧ភាគរយ ការថែទាំសុខភាព៤,៧ភាគរយ ទូរគមនាគមន៍២,៦ភាគរយ និងការសិក្សាអប់រំ១,៤ភាគរយ។

-ចំណែកភាគរយនៃសមាសភាពចំណាយប្រើប្រាស់របស់គ្រួសារ រួមមានការចំណាយលើម្ហូបអាហារ៥១,៧ ភាគរយ និងការចំណាយមិនមែនម្ហូបអាហារ៤៨.៣ភាគរយ។

### ១០.ការប្រើប្រាស់ស្បៀងអាហាររបស់គ្រួសារ (សន្តិសុខស្បៀងអាហារ)

-ចំនួនថ្ងៃនៃការប្រើប្រាស់ម្ហូបអាហារក្នុងគ្រួសារក្នុងរយៈពេល៧ថ្ងៃកន្លងមកពីការបរិភោគធញ្ញជាតិអង្ករ៖ បាយ បបរ នំបញ្ចុក គុយទាវ (អាហារធ្វើពីអង្ករ) មានភាគរយច្រើនជាងគេ និងអត្រាបរិភោគទាបជាងគេគឺ សត្វល្អិត៖ ចង្រិត ពីងពាង...... ។ល។

ការប្រើប្រាស់យុទ្ធសាស្រ្តកាត់បន្ថយម្ហូបអាហារក្នុងគ្រួសារនៅទូទាំងប្រទេស គឺការកាត់បន្ថយបរិមាណញ៉ាំអាហារដោយមនុស្សពេញវ័យឬម្ដាយដើម្បីទុកឱ្យក្មេងតូចៗ០,៣ភាគរយ កាត់បន្ថយបរិមាណអាហារក្នុងមួយពេលៗ០,៤ភាគរយ កាត់បន្ថយចំនួនដងឬចំនួនពេលនៃការហូបអាហារក្នុងមួយថ្ងៃ០,៣ភាគរយ ខ្ចីម្ហូបអាហារគេឬពឹងផ្អែកទៅលើជំនួយពីមិត្តភ័ក្តឬបងប្អូន០,៦ភាគរយ ពឹងផ្អែកលើញ៉ាំម្ហូបអាហារមិនសូវចូលចិត្ត/អាហារដែលមានតម្លៃថោក១,៧ភាគរយ។

## ២.៣.២ របាយការណ៍ការចុះបញ្ជីអង្គភាពសេដ្ឋកិច្ច ឆ្នាំ២០២១

ជាលទ្ធផលសង្ខេបសរុបនៃបញ្ជីអង្គភាពសេដ្ឋកិច្ច ឆ្នាំ២០២១ រួមមាន៖

- ចំនួនអង្គភាពសេដ្ឋកិច្ចសរុបមាន៧៤២,៩៤០អង្គភាពសេដ្ឋកិច្ចនៅទូទាំង២៥រាជធានី ខេត្ត
- មានប្រមាណ១២,១ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលផ្តល់ចម្លើយថា "បានចុះបញ្ជី»
- ចំនួនអ្នកចូលរួមការងារសរុប២, ៩៦៩ ពាន់នាក់ (ស្រី១, ៧៦១ ពាន់នាក់ ប្រហែល ៥៩%)
- ប្រមាណ៦៣ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលមានស្ត្រីជាអ្នកតំណាង ឬគ្រប់គ្រង
- ប្រមាណ៩៧ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលមានអ្នកចូលរួមការងារ ក្រោម១០នាក់

- ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារចាប់ពី១០០នាក់ឡើងមាន១,៨៦៨(០,៣%)
- ប្រមាណ៦៦ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប គឺស្ថិតក្នុងវិស័យអាជីវកម្មលក់ដុំ និងរាយ
- ប្រមាណ៧ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប គឺស្ថិតក្នុងវិស័យកម្មន្តសាល(ឧស្សាហកម្មផលិត)។

### ២.៣.៣ របាយការណ៍បឋមជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២

ជាលទ្ធផលសង្ខេបសរុបនៃជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ រួមមាន៖

- ចំនួនអង្គភាពសេដ្ឋកិច្ចសរុបមាន ៧៥៣ ៦៧០ អង្គភាពសេដ្ឋកិច្ចនៅទូទាំង២៥រាជធានី ខេត្ត
- មានប្រមាណ១,៤ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលផ្តល់ចម្លើយថា "បានចុះបញ្ជី"
- ចំនួនអ្នកចូលរួមការងារសរុប ២, ៧៤១ ពាន់នាក់ (ស្រី ១, ៦៧៧ ពាន់នាក់ ប្រហែល ៦១%)
- ប្រមាណ៦៩ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលមានស្ត្រីជាអ្នកតំណាង ឬគ្រប់គ្រង
- ប្រមាណ៩៧ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប ដែលមានអ្នកចូលរួមការងារ ក្រោម១០នាក់
- ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារចាប់ពី១០០នាក់ឡើងមាន១,៨៧០ (០,៣%)
- ប្រមាណ៦៦ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប គឺស្ថិតក្នុងវិស័យអាជីវកម្មលក់ដុំ និងរាយ
- ប្រមាណ៧ភាគរយ នៃអង្គភាពសេដ្ឋកិច្ចសរុប គឺស្ថិតក្នុងវិស័យកម្មន្តសាល (ឧស្សាហកម្មផលិត)។

# ៣.ប្រព័ន្ធស្ថិតិជាតិឆ្នាំ២០២២

## ៣.១ ការចំណាយ និងមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិឆ្នាំ២០២២

យោងតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង រាល់ស្ថិតិទាំងអស់ត្រូវរាយការណ៍មកវិទ្យាស្ថានជាតិស្ថិតិ រួមទាំងការចំណាយនៃការប្រមូលទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំង។ នៅឆ្នាំនេះ អង្គភាពស្ថិតិដែលបានចាត់តាំងមួយចំនួនមានការយល់ច្បាស់អំពីការគណនាចំណាយសរុប ការចំណាយលើប្រាក់បៀវត្សរ៍របស់មន្ត្រីការិយាល័យកណ្តាល និងទព្វសម្ភារៈ និងការប្រមូលទិន្នន័យតាមរយៈរបាយការណ៍រដ្ឋបាល។ សេចក្តីសង្ខេបដែលបានរាយការណ៍សម្រាប់អង្គេតនីមួយៗតាមការចំណាយប៉ាន់ស្មាន ឬការចំណាយជាក់ស្តែងត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ១ ។ ជាការកត់សម្គាល់ គុណភាពនៃការចំណាយដែលបានរាយការណ៍នៅមានកម្រិតទាបខ្លាំងនិងស្ទើតែមិនបានចំណាយដោយសកម្មភាពខ្លះមិនបានធ្វើ ព្រោះស្ថិតក្នុងកាលៈទេសៈលំបាកដោយសារពេគរាតត្បាតជាសាកលជំងឺកូវីដ-១៩ ដែលធ្វើឱ្យមានការពិបាកធ្វើការប្រៀបធៀបរវាងអ្នកផលិតស្ថិតិ ។

ចំនួនសរុបមន្ត្រីផលិតស្ថិតិផ្លូវការដែលបានចាត់តាំងនៅឆ្នាំ ២០២២ មាន៨៨០នាក់ ក្នុងនោះស្ត្រីមាន២៦៩នាក់ស្មើនឹង៣០.៦ភាគរយ។ របាយការណ៍ឆ្នាំ២០២២នេះមានក្រសួងមួយចំនួនមិនបានផ្តល់ព័ត៌មានដល់វិទ្យាស្ថានជាតិស្ថិតិនៅឡើយទេក្នុងនោះមានដូចជា៖ ក្រសួងយុត្តិធម៌ ក្រសួងធម្មការ និងសាសនា និងក្រសួងធនធានទឹកនិងឧតុនិយម ។

**តារាង១ ចំនួនមន្ត្រីសរុប**

| ល.រ | ក្រសួង | ចំនួនមន្ត្រី ឆ្នាំ ២០២២ | |
|---|---|---|---|
| | | សរុប | ស្ត្រី |
| ១ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | ៤៨៩ | ១៦៥ |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ៤ | ១ |
| ៣ | ក្រសួងមហាផ្ទៃ | ៥៦ | ៧ |
| ៤ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៦ | ៧ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៣ | ៣ |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៥ | ២ |
| ៧ | ក្រសួងពាណិជ្ជកម្ម | ៤ | ១ |
| ៨ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១៥ | ៥ |
| ៩ | ក្រសួងរ៉ែ និងថាមពល | ៤ | ២ |
| ១០ | ក្រសួងអប់រំ យុវជន និងកីឡា | ៣២ | ៧ |
| ១១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ២ | ០ |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១២ | ៣ |
| ១៣ | ក្រសួងបរិស្ថាន | ២២ | ៩ |
| ១៤ | ក្រសួងធនធានទឹក និងឧតុនិយម | - | - |
| ១៥ | ក្រសួងព័ត៌មាន | ៧ | ៤ |
| ១៦ | ក្រសួងយុត្តិធម៌ | - | - |
| ១៧ | ក្រសួងអធិការកិច្ច | ៧ | ២ |
| ១៨ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៣ | ០ |

| | | | |
|---|---|---|---|
| ១៩ | ក្រសួងសុខាភិបាល | ៩ | ២ |
| ២០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ២០ | ៤ |
| ២១ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ២ | ១ |
| ២២ | ក្រសួងទេសចរណ៍ | ២១ | ៤ |
| ២៣ | ក្រសួងធម្មការ និងសាសនា | - | - |
| ២៤ | ក្រសួងកិច្ចការនារី | ៦ | ៥ |
| ២៥ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៧៦ | ១៦ |
| ២៦ | ក្រសួងមុខងារសាធារណៈ | ៦ | ១ |
| ២៧ | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | ៥ | ៤ |
| ២៨ | ធនាគារជាតិនៃកម្ពុជា | ២៨ | ១២ |
| ២៩ | ក្រុមប្រឹក្សាសម្រាប់អភិវឌ្ឍន៍កម្ពុជា | ៣ | ១ |
| ៣០ | ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល | ៣ | ១ |
| | **សរុប** | **៨៨០** | **២៦៩** |

នៅឆ្នាំ២០២២នេះ អ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំងមានស្ទើរតែទាំងអស់ដែលមិន ទទួលបានការឧបត្ថម្ភពីម្ចាស់ជំនួយ។ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការក៏មានការថយចុះផងដែរទាំងផ្នែកថវិកានិងបច្ចេកទេស ដោយកន្លងមកធ្លាប់ទទួលបានការគាំទ្រ និងមានទីប្រឹក្សារយៈពេលវែងតាមរយៈម្ចាស់ជំនួយ ការផ្គត់ផ្គង់សម្ភារៈ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យការសរសេររបាយការណ៍ និងការបណ្តុះបណ្តាលផ្សេងៗ ។ ដោយឡែកមានក្រសួងចំនួន៥ដែលនៅមានការគ្រាំទ្រពីដៃគូអភិវឌ្ឍន៍ ទាំងផ្នែកបច្ចេកទេសទីប្រឹក្សានិងថវិកាតិចតួច ក្នុងនោះមានក្រសួងទេសចរណ៍ ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៣.២ ស្ថិតិដែលបានផលិត

វិទ្យាស្ថានជាតិស្ថិតិក៏ដូចជាក្រសួងស្ថាប័នដែលជាអ្នកផលិតស្ថិតិដទៃទៀត មានការខកខានមិនបានផលិតទិន្នន័យខ្លះស្រមតាមស្ថិតិផ្លូវការដែលបានចាត់តាំងនៅក្នុងឆ្នាំ២០២២ដោយសារជំងឺរាតត្បាតកូវីដ-១៩ និងខ្វះខាតធនធានថវិការក្នុងការអនុវត្តការអង្កេតសំខាន់ៗដូចមានចែងក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងជារួមមានសន្ទស្សន៍មួយចំនួននិងកម្រងស្ថិតិ។ ទន្ទឹមនឹងនេះ វិទ្យាស្ថានជាតិស្ថិតិព្យាយាមនិងបានផលិតស្ថិតិបានសរុបចំនួន៧តាមរយៈការធ្វើអង្កេតនិងបានប្រមូលទិន្នន័យដែលបានអនុវត្តដោយអង្គភាពស្ថិតិក្នុងក្រសួងស្ថាប័នដែលជាទិន្នន័យរដ្ឋបាលចំនួន២។ យោងតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ឆ្នាំនេះស្ថិតិភាគច្រើនត្រូវបានខកខានមិនបានផលិត និងធ្វើការផ្សព្វផ្សាយទៅកាន់សាធារណជន។ យោងតាមព័ត៌មានដែលប្រមូលបានសម្រាប់របាយការណ៍ប្រចាំឆ្នាំ ចំនួនសរុបនៃស្ថិតិដែលបានផលិតបានសុរបមាន ចំនួន៩ នៅឆ្នាំ២០២២។ ស្ថិតិមួយចំនួនតូចមិនបានប្រមូលនៅពេលខ្លះ ឬមិនយោងតាមពេលវេលាដូចចែងក្នុងអនុក្រឹត្យ។ សម្រាប់ព័ត៌មានបន្ថែមសូមពិនិត្យមើលឧបសម្ព័ន្ធ ១និង២។

វិទ្យាស្ថានជាតិស្ថិតិបានផលិតស្ថិតិដែលជាទិន្នន័យបានពីកំណត់ត្រារដ្ឋបាលមួយចំនួនត្រូវបានប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ ជាចម្បងគឺពីការប្រមូលទិន្នន័យតាមរយៈអង្កេតឬជំរឿន។ ភាគច្រើននៃឯកតាស្ថិតិគឺគ្រួសារ។

អ្នកផលិតស្ថិតិដទៃទៀតពីក្រសួង ស្ថាប័ន និងធនាគារជាតិនៃកម្ពុជាជាចម្បងគឺការប្រមូលទិន្នន័យតាមរយៈកំណត់ត្រារដ្ឋបាល។ អ្នកផលិតស្ថិតិមួយចំនួនបានរួមបញ្ចូលគ្នាទាំងការប្រមូលទិន្នន័យរដ្ឋបាលជាមួយការអង្កេតតូចៗ ឬធ្វើការចងក្រង។

**តារាងទី២ប្រភពទិន្នន័យសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំង**

| ល.រ | ក្រសួង | ប្រភពទិន្នន័យសម្រាប់ស្ថិតិ | | | |
|---|---|---|---|---|---|
| | | កំណត់ត្រារដ្ឋបាល | អង្កេត | ជំរឿន | ផ្សេងៗ |
| ១ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | ២ | ៧ | ០ | ០ |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១ | ០ | ០ | ១ |
| ៣ | ក្រសួងមហាផ្ទៃ | ៩ | ០ | ០ | ០ |
| ៤ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥ | ០ | ០ | ៥ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤ | ៤ | ៤ | ០ |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | ០ | ០ | ១ |
| ៧ | ក្រសួងពាណិជ្ជកម្ម | ៥ | ០ | ០ | ៣ |
| ៨ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៤ | ០ | ០ | ០ |
| ៩ | ក្រសួងរ៉ែ និងថាមពល | ៤ | ០ | ០ | ០ |
| ១០ | ក្រសួងអប់រំ យុវជន និងកីឡា | ១ | ១ | ២ | ០ |
| ១១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤ | ០ | ០ | ០ |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៣ | ០ | ០ | ០ |
| ១៣ | ក្រសួងបរិស្ថាន | ១ | ០ | ០ | ០ |
| ១៤ | ក្រសួងធនធានទឹក និងឧតុនិយម | - | - | - | - |
| ១៥ | ក្រសួងព័ត៌មាន | ១ | ០ | ០ | ០ |
| ១៦ | ក្រសួងយុត្តិធម៌ | - | - | - | - |
| ១៧ | ក្រសួងអធិការកិច្ច | ៧ | ០ | ០ | ០ |
| ១៨ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤ | ០ | ០ | ០ |
| ១៩ | ក្រសួងសុខាភិបាល | ៣ | ០ | ០ | ០ |
| ២០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | ០ | ០ | ០ |
| ២១ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៦ | ០ | ០ | ០ |
| ២២ | ក្រសួងទេសចរណ៍ | ២ | ១ | ០ | ១ |
| ២៣ | ក្រសួងធម្មការ និងសាសនា | - | - | - | - |
| ២៤ | ក្រសួងកិច្ចការនារី | ១ | ១ | ១ | ១ |
| ២៥ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២ | ០ | ០ | ១ |
| ២៦ | ក្រសួងមុខងារសាធារណៈ | - | - | - | - |
| ២៧ | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | ៤ | ០ | ០ | ០ |
| ២៨ | ធនាគារជាតិនៃកម្ពុជា | ៤ | ០ | ០ | ១ |
| ២៩ | ក្រុមប្រឹក្សាសម្រាប់អភិវឌ្ឍន៍កម្ពុជា | ១ | ០ | ០ | ០ |
| ៣០ | ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល | ៣ | ៣ | ០ | ០ |
| | សរុប | ៨៣ | ១៧ | ៧ | ១៣ |

## ៣.៣ ការបែងចែកតាមតំបន់

ស្ថិតិភាគច្រើនដែលបានផលិតអាចបង្ហាញសម្រាប់តែប្រទេសទាំងមូលប៉ុណ្ណោះ។ ចំពោះជំរឿនដែលដំណើរការដោយវិទ្យាស្ថានជាតិស្ថិតិអាចបែងចែកលទ្ធផលតាមកម្រិតភូមិ។មានកំណត់ត្រារដ្ឋបាលមួយចំនួន ដែលក្រសួងពាក់ព័ន្ធប្រើប្រាស់សម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំង បានបង្ហាញតាមកម្រិតថ្នាក់ខេត្ត។ មានតែក្រសួងមួយចំនួនតូចប៉ុណ្ណោះដែលអាចបង្ហាញស្ថិតិតាមកម្រិតក្រោមកម្រិតខេត្តដូចជាកម្រិតស្រុកនិងឃុំ។ សម្រាប់ការអង្កេតនីមួយៗការបែងចែកតាមតំបន់ សូមមើលឧបសម្ព័ន្ធ២ ។

**តារាងទី៣ស្ថិតិផ្លូវការដែលបានចាត់តាំងបែងចែកតាមតំបន់**

| ល.រ | ក្រសួង | កម្រិតតំបន់ | | | | |
|---|---|---|---|---|---|---|
| | | កម្ពុជា | ខេត្ត | ស្រុក | ឃុំ | ភូមិ |
| ១ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | ៩ | ៩ | ១ | ១ | ១ |
| ២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ១ | ០ | ០ | ០ | ០ |
| ៣ | ក្រសួងមហាផ្ទៃ | ៩ | ៩ | ៩ | ៩ | ០ |
| ៤ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥ | ០ | ០ | ០ | ០ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧ | ៧ | ០ | ០ | ០ |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | ១ | ០ | ០ | ០ |
| ៧ | ក្រសួងពាណិជ្ជកម្ម | ២ | ០ | ០ | ០ | ០ |
| ៨ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៣ | ១ | ០ | ០ | ០ |
| ៩ | ក្រសួងរ៉ែ និងថាមពល | ៤ | ០ | ០ | ០ | ០ |
| ១០ | ក្រសួងអប់រំ យុវជន និងកីឡា | ៣ | ៣ | ២ | ១ | ១ |
| ១១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤ | ២ | ០ | ០ | ០ |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៣ | ៣ | ៣ | ៣ | ០ |
| ១៣ | ក្រសួងបរិស្ថាន | ១ | ១ | ១ | ១ | ០ |
| ១៤ | ក្រសួងធនធានទឹក និងឧតុនិយម | - | - | - | - | - |
| ១៥ | ក្រសួងព័ត៌មាន | ១ | ០ | ០ | ០ | ០ |
| ១៦ | ក្រសួងយុត្តិធម៌ | - | - | - | - | - |
| ១៧ | ក្រសួងអធិការកិច្ច | ៧ | ០ | ០ | ០ | ០ |
| ១៨ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤ | ១ | ០ | ០ | ០ |
| ១៩ | ក្រសួងសុខាភិបាល | ៣ | ៣ | ៣ | ០ | ០ |
| ២០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | ១ | ០ | ០ | ០ |
| ២១ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៦ | ៦ | ០ | ០ | ០ |
| ២២ | ក្រសួងទេសចរណ៍ | ៣ | ៣ | ០ | ០ | ០ |
| ២៣ | ក្រសួងធម្មការ និងសាសនា | - | - | - | - | - |
| ២៤ | ក្រសួងកិច្ចការនារី | ១ | ១ | ១ | ១ | ០ |
| ២៥ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣ | ៣ | ០ | ០ | ១ |
| ២៦ | ក្រសួងមុខងារសាធារណៈ | ០ | ០ | ០ | ០ | ០ |
| ២៧ | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | ៤ | ០ | ០ | ០ | ០ |
| ២៨ | ធនាគារជាតិនៃកម្ពុជា | ៤ | ០ | ០ | ០ | ០ |
| ២៩ | ក្រុមប្រឹក្សាសម្រាប់អភិវឌ្ឍន៍កម្ពុជា | ១ | ០ | ០ | ០ | ០ |
| ៣០ | ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល | ៦ | ០ | ០ | ០ | ០ |
| | **សរុប** | **៩៦** | **៥៤** | **២០** | **១៦** | **៣** |

# ៤.ស្ថិតិផ្លូវការដែលបានចាត់តាំងឆ្នាំ២០២២

## ៤.១ វិទ្យាស្ថានជាតិស្ថិតិ

### ៤.១.១ តួនាទី និងការទទួលខុសត្រូវ

វិទ្យាស្ថានជាតិស្ថិតិដែលជាផ្នែកមួយនៃក្រសួងផែនការ គឺមជ្ឈមណ្ឌលកណ្តាលសម្រាប់ការងារស្ថិតិក្នុងប្រទេសកម្ពុជា។ វិទ្យាស្ថានជាតិស្ថិតិបានធ្វើការចងក្រង និងរួមបញ្ចូលគ្នានូវស្ថិតិ ដែលផ្តល់ដោយការិយាល័យថ្នាក់ក្រោម និងការប្រមូលទិន្នន័យដើមតាមរយៈការអង្កេតគ្រួសារ និងសហគ្រាសនិងជំរឿនប្រជាពលរដ្ឋកសិកម្មនិងសេដ្ឋកិច្ច។ រាល់ទិន្នន័យដែលចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។

វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាលនិងមានភារកិច្ចទទួលខុសត្រូវដូចតទៅ៖

- ប្រមូលកែច្នៃចងក្រងវិភាគបោះពុម្ពនិងផ្សព្វផ្សាយស្ថិតិផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។
- ស្រាវជ្រាវចងក្រងវិធីសាស្ត្រផ្សេងៗអភិវឌ្ឍន៍ម៉ូឌែលស្ថិតិនិងបច្ចេកទេសស្ថិតិដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ។
- ធានាការសម្របសម្រួលប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំង។
- រៀបចំគោលនយោបាយ និងបទដ្ឋានស្ថិតិសម្រាប់ការអនុវត្តដោយអង្គភាពស្ថិតិ។
- ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំងទាក់ទងនឹងស្ថិតិផ្លូវការ។
- ទំនាក់ទំនងជាមួយបណ្តាប្រទេសនានា និងអង្គការអន្តរជាតិនានា។

### ៤.១.២ អង្កេតស្ថិតិ និងគោលដៅ

សូមគូសបញ្ជាក់ផងដែរថាសម្រាប់ការអង្កេតមួយចំនួនដែលមានចែងក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងមិនត្រូវបានដំណើរការជារៀងរាល់ឆ្នាំឡើយដូចជា៖ ជំរឿន អង្កេតប្រជាសាស្ត្រ និងចន្លោះជំរឿន ឬដោយសារកង្វះខាតធនធាន ។ ហើយស្ថិតិទាំងនោះសូមមិនធ្វើការរាយនាមទេផ្ទុយទៅវិញយើងសូមបង្ហាញជូនតែអង្កេតឬរបាយការណ៍ណា ដែលត្រូវបានធ្វើក្នុងឆ្នាំនេះក្នុងឆ្នាំ២០២២ ដែលមានរាយនាមដូចខាងក្រោម៖

#### សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែត្រីមាស និងប្រចាំឆ្នាំ

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ត្រូវបានប្រមូល និងចងក្រងសម្រាប់វាស់វែងអតិផរណាក្នុងប្រទេសកម្ពុជា និងធ្វើការប្រៀបធៀបសន្ទស្សន៍ពីខែមួយ ទៅខែមួយទៀត និងពីឆ្នាំមួយ ទៅឆ្នាំមួយទៀត។ ម្យ៉ាងវិញទៀត សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ត្រូវបានប្រើប្រាស់សម្រាប់ចងក្រងគណនេយ្យជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក៏ត្រូវបានប្រើប្រាស់សម្រាប់គណនាប្រាក់បៀវត្សរ៍របស់មន្ត្រីរដ្ឋាភិបាលនិងក្រុមហ៊ុនផងដែរ។

**ស្ថិតិគណនេយ្យជាតិប្រចាំត្រីមាសនិងប្រចាំឆ្នាំ**

ស្ថិតិត្រូវបានប្រមូល ដើម្បីចងក្រងព្រឹត្តិបត្រគណនេយ្យជាតិនិងគណនាប៉ាន់ស្មានផលិតផលក្នុងស្រុកសរុបតាមវិស័យ និងប៉ាន់ស្មានតម្លៃបន្ថែមសរុបដែលត្រូវបានប្រើប្រាស់សម្រាប់តាមដានកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍនៅប្រទេសកម្ពុជា។ ការធ្វើបច្ចុប្បន្នកម្មគណនេយ្យជាតិ ត្រូវបានធ្វើឡើងដើម្បីរក្សានូវស្ថេរភាពរបស់ស៊េរីទាំងមូល។

**ស្ថិតិក្រុមសង្កេតការណ៍ភពផែនដី**

គោលបំណងរបស់ស្ថិតិដែលបានប្រមូល គឺការប្រមូលស្ថិតិដែលទទួលបានពីផ្កាយរណបឬទិន្នន័យរាប់ពីចម្ងាយនិងការប្រមូលផ្ទាល់ទាក់ទងគ្រោះមហន្តរាយ បរិស្ថាននិងការបម្រែបម្រួលអាកាសធាតុ សម្រាប់ចូលរួមអនុវត្តន៍គោលដៅនិងអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**ស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជាប្រចាំឆ្នាំ**

-ត្រួតពិនិត្យទំនិញនាំចេញនិងនាំចូលនៅមាត់ច្រកព្រំដែន

-លើកសំណើគោលនយោបាយពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិរៀបចំបទបញ្ញាត្តិពាក់ព័ន្ធការប្រមូលពន្ធអាករនាំចេញនិងនាំចូលគ្រប់ប្រភេទ

-អនុវត្តន៍គោលនយោបាយសមាហរណកម្មសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធការងារគយ និងរដ្ឋាករ

-គ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តន៍ការប្រមូលពន្ធអាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ និងនាំចូលគ្រប់ប្រភេទ

**ស្ថិតិកសិកម្មកម្ពុជាប្រចាំឆ្នាំ**

គោលបំណងរបស់ស្ថិតិដែលបានប្រមូលគឺ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងគោលនយោបាយកសិកម្មការវិនិយោគកសិកម្មនិងទំនោរនៃទីផ្សារកសិកម្ម។ និយាយជារួមស្ថិតិដែលប្រមូលបាននេះគឺ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព នៃវិស័យកសិកម្មដោយផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនិងទុកចិត្តបានទៅកាន់ភាគីពាក់ព័ន្ធ។

**សៀវភៅស្ថិតិថ្នាក់ក្រោមជាតិ**

គោលបំណងសំខាន់នៃការប្រមូលទិន្នន័យថ្នាក់ក្រោមជាតិគឺជាការវិភាគទិន្នន័យរកឱ្យឃើញនៅបញ្ហាដែលអាចកើតមានឡើង នៅក្នុងមូលដ្ឋានដែលមានទិន្នន័យ ដែលទាក់ទងទៅនឹងពត៌មានប្រជាសាស្រ្តសេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំនិងកសិកម្មរបស់ខេត្តទាំងបួន។

### ៤.១.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិមានដូចជា៖ រាជរដ្ឋាភិបាលកម្ពុជា បណ្តាក្រសួង ស្ថាប័នអ្នកស្រាវជ្រាវផ្នែកឯកជន ដៃគូរអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិឧទាហរណ៍ ធនាគារជាតិនៃកម្ពុជា(NBC) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

## ៤.១.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិអង្កេតកសិកម្មកម្ពុជាប្រចាំឆ្នាំ | ២០២២ | ២០២៣ | របាយការណ៍អង្កេតកសិកម្មកម្ពុជា |
| សៀវភៅស្ថិតិថ្នាក់ក្រោមជាតិ | ២០២២ | ២០២២ | សៀវភៅរបាយការណ៍ស្ថិតិថ្នាក់ក្រោមជាតិ |
| ស្ថិតទំនិញពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា | ២០២២ | ២០២៣ | របាយការណ៍ទំនិញពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា |
| ប្រព័ន្ធទិន្នន័យស្ថិតិក្រុមសង្កេតការណ៍ភពផែនដី | ២០២២ | ២០២៣ | របាយការណ៍លទ្ធផលអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | ២០១៧ | ២០១៨ | ព្រឹត្តិបត្រសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ឆ្នាំ២០១៨ |
| ស្ថិតិគណនេយ្យជាតិ | ២០១៧ | ២០១៧ | ព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា |
| សន្ទស្សន៍ផលិតកម្មកសិកម្មនិងឧស្សាហកម្ម | ២០១៧ | ២០១៧ | បានដាក់បញ្ចូលក្នុងព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា |
| ស្ថិតិនិងសន្ទស្សន៍ពាណិជ្ជកម្មលក់រាយនិងលក់ដុំ | ២០១៧ | ២០១៧ | បានដាក់បញ្ចូលក្នុងព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា |
| សន្ទស្សន៍ថ្លៃនីហរ័ណនិងអាហរ័ណ | ២០១៧ | ២០១៧ | បានដាក់បញ្ចូលក្នុងព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា |

## ៤.២ ទីស្ដីការគណៈរដ្ឋមន្ត្រី

### ៤.២.១ ភារកិច្ចនិងការទទួលខុសត្រូវ

ទីស្ដីការគណៈមន្ត្រី ជាស្ថាប័នកំពូលរបស់រាជរដ្ឋាភិបាល មានបេសកកម្មដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។

### ៤.២.២ អង្កេតស្ថិតិ និងគោលដៅ

### ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ប្រចាំខែនិងប្រចាំឆ្នាំ

គឺដើម្បីផលិតព័ត៌មានវិភាគមានខ្លឹមសារពាក់ព័ន្ធនឹងគោលនយោបាយដើម្បីផ្ដល់ជូនអ្នកសម្រេចចិត្ត។

### ៤.២.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើស្ថិតិដែលបានប្រមូលគឺក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ក្នុងនាមជាអ្នកធ្វើប្រព្រឹត្តិកម្មស្ថិតិដើម្បីថ្នាក់ដឹកនាំដែលជាអ្នកសម្រេចចិត្ត។

### ៤.២.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ | ២០២២ | ២០២៣ | ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ |

## ៤.៣ ក្រសួងមហាផ្ទៃ

### ៤.៣.១ ភារកិច្ចនិងការទទួលខុសត្រូវ

ក្រសួងមហាផ្ទៃ មានភារកិច្ចចម្បងលើការងារគ្រប់គ្រងរដ្ឋបាលដែនដី ការងារសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ។

### ៤.៣.២ អង្កេតស្ថិតិនិងគោលដៅ

### ស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិអត្តសញ្ញាណប័ណ្ណប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិការចុះបញ្ជីអត្រានុកូលដ្ឋានប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិបទល្មើសព្រហ្មទណ្ឌនិងការបង្ក្រាបប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិជនជាប់ឃុំនិងការអប់រំកែប្រែប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិជនអន្តោប្រវេសន៍ប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិគណបក្សនយោបាយប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិអង្គការមិនមែនរដ្ឋាភិបាលប្រចាំឆ្នាំ

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

### ស្ថិតិការបង្កើតក្រុងស្រុកខណ្ឌសង្កាត់ឃុំនិងភូមិថ្មី

ជាឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ និងជាម៉ែត្រវាស់ស្ទង់ពីប្រសិទ្ធិភាពការងារ និងជាឧបករណ៍សម្រាប់លើកទិសដៅការងារបន្តទៅឆ្នាំក្រោយ។

## ៤.៣.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់សំខាន់ៗមាន អ្នកធ្វើផែនការ អ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្ត អ្នកស្រាវជ្រាវសម្រាប់ធ្វើការអភិវឌ្ឍនៃជារាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការសង្គមស៊ីវិល។

## ៤.៣.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិប្រជាពលរដ្ឋ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ |
| ស្ថិតិអត្តសញ្ញាណប័ណ្ណ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិការចុះបញ្ជីអត្រានុកូលដ្ឋាន | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិបទល្មើសព្រហ្មទណ្ឌនិងការបង្ក្រាប | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិជនជាប់ឃុំនិងការអប់រំកែប្រែ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិជនអន្តោប្រវេសន៍ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិគណបក្សនយោបាយ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិអង្គការមិនមែនរដ្ឋាភិបាល | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |
| ស្ថិតិការបង្កើតក្រុងស្រុកខណ្ឌសង្កាត់ឃុំនិងភូមិថ្មី | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ |

## ៤.៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ៤.៤.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារកិច្ចជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកតម្កើងកម្រិតជីវភាពរបស់ប្រជាជនដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរីនិងសមធម៌។

### ៤.៤.២ អត្ថុតស្ថិតិនិងគោលដៅ

**ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាលប្រចាំខែនិងប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

**ស្ថិតិការអនុវត្តថវិកា ប្រចាំខែ និងប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

**ស្ថិតិចំណូលសារពើពន្ធប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

**ស្ថិតិចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

**ស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

**ស្ថិតិបំណុលសាធារណៈប្រចាំត្រីនិងប្រចាំឆ្នាំ**

ចងក្រងស្ថិតិ ដើម្បីពង្រឹង និងពង្រីកវិសាលភាពក៏ដូចជាលុបបំបាត់ចន្លោះប្រហោងនិងស្វែងរកចំនុចប្រសព្វដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យមានសង្គតិភាព។

### ៤.៤.៣ ការប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ចម្បងនៃស្ថិតិគឺរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គភាពអ្នកស្រាវជ្រាវ និងនិស្សិត

### ៤.៤.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាលប្រចាំខែនិងប្រចាំឆ្នាំ | ២០២២ | ២០២៣ | ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាលប្រចាំខែនិងប្រចាំឆ្នាំ |
| ស្ថិតិការអនុវត្តថវិកា ប្រចាំខែ និងប្រចាំឆ្នាំ | ២០២២ | ២០២៣ | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ និងប្រចាំឆ្នាំ |
| ស្ថិតិចំណូលសារពើពន្ធប្រចាំឆ្នាំ | ២០២២ | ២០២៣ | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ និងប្រចាំឆ្នាំ |
| ស្ថិតិចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ | ២០២២ | ២០២៣ | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ និងប្រចាំឆ្នាំ |
| ស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ | ២០២២ | ២០២៣ | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ និងប្រចាំឆ្នាំ |
| ស្ថិតិបំណុលសាធារណៈប្រចាំត្រីមាសនិងប្រចាំឆ្នាំ | ២០២២ | ២០២៣ | ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា |

## ៤.៥ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

### ៤.៥.១ ភារកិច្ចនិងការទទួលខុសត្រូវ

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចទទួលខុសត្រូវដូចជាៈ រៀបចំវិធីសាស្ត្រ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផែនការ ដើម្បីជានាធ្វើឱ្យបានប្រព័ន្ធស្ថិតិ កសិកម្មជានា គុណភាព និងភាពរីកចម្រើន ដើម្បីឱ្យព័ត៌មាន និងទិន្នន័យស្ថិតិវិស័យកសិកម្ម ទទួលបានលទ្ធផលល្អគ្រប់ផ្នែកសម្រាប់បម្រើឱ្យតម្រូវការប្រើប្រាស់ ទាំងស្ថាប័នរដ្ឋ ឯកជន និងអន្តរជាតិ។ ទទួលបន្ទុករៀបចំគ្រប់គ្រងអនុវត្តធ្វើជំរឿន ធ្វើអង្កេត និងធ្វើការប្រមូលព័ត៌មាន ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាពជំនាញ មន្ទីរកសិកម្ម គ្រប់រាជធានី ខេត្ត និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ពិសេសវិភាគ វាយតម្លៃ ប៉ាន់ស្មាន និងព្យាករណ៍ទិន្នន័យស្ថិតិ ពិនិត្យលទ្ធផល ដែលទទួលបានពីការវិវត្តឡើងចុះក្នុងវិស័យកសិកម្ម។

### ៤.៥.២ អង្កេតស្ថិតិនិងគោលដៅ

#### ស្ថិតិថ្លៃទំនិញកសិកម្មប្រចាំខែប្រចាំត្រីមាសនិងប្រចាំឆ្នាំ

ដើម្បីជួយដល់កសិករអាជីវករ និងអ្នកដទៃទៀតសម្រាប់ធ្វើសេចក្តីសម្រេចចិត្តអំពីអ្វីនៅពេលណាទីកន្លែងណានិងផលិតផលប៉ុន្មានដែលពួកគេគួរលក់ជួយកសិករដើម្បីធ្វើផែនការផលិតកម្មដោយពឹងផ្អែកលើតម្រូវការទីផ្សារ និងការយល់ដឹងអំពីសេដ្ឋកិច្ចបង្កើនកម្រិតជីវភាពជាចម្បង និងកាត់បន្ថយភាពក្រីក្រផ្សព្វផ្សាយដល់កសិករនិងអតិថិជនអំពីតម្លៃទំនិញចូលរួមក្នុងការអភិវឌ្ឍដោយផ្តល់ចំណេះដឹងល្អៗនៃទីផ្សារនិងលើកស្ទួយមន្ត្រីកសិកម្ម។

#### ស្ថិតិអង្កេតផ្ទៃដី ទិន្នផលនិងបរិមាណផលដំណាំប្រចាំរដូវនិងប្រចាំឆ្នាំ

ដើម្បីអនុវត្តផែនការអភិវឌ្ឍយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗដើម្បីវាយតម្លៃតុល្យភាពស្មៀងរវាងតម្រូវការ និងការផ្គត់ផ្គង់ និងលទ្ធភាពការនាំចេញ ដើម្បីគិតពិចារណាអំពីផលិតក្នុងស្រុកសរុប ដើម្បីកាត់បន្ថយភាពក្រីក្រតាមតំបន់ជនបទ ដើម្បីបង្កើនការអប់រំ និងធ្វើការផ្សព្វផ្សាយបច្ចេកវិទ្យាដល់កសិករ។

**ស្ថិតិផលិតកម្មនិងបសុព្យាបាលប្រចាំឆ្នាំ**

ដើម្បីវិភាគផលិតកម្មបសុសត្វកំណើនការងារ និងរបៀបរកប្រាក់ចំណេញសម្រាប់កសិករដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ ដើម្បីផលិតនូវផលិតផលក្នុងស្រុកសរុប នៃផលិតផលបសុសត្វនិងបសុព្យាបាលដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីដោះស្រាយសន្តិសុខស្បៀងនិងជាចុងក្រោយដើម្បីរកប្រាក់ចំណេញសម្រាប់កសិករ និងសេដ្ឋកិច្ច។

**ស្ថិតិជលផលប្រចាំឆ្នាំ**

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រដោះស្រាយសន្តិសុខស្បៀងវិភាគផលិតផលក្នុងស្រុកសរុប នៃវិស័យជលផលវាយតម្លៃតុល្យភាពស្បៀងរវាងតម្រូវការនិងការផ្គត់ផ្គង់ជម្រុញវារីវប្បកម្មនេសាទសហគមន៍និងពង្រឹងការពារធនធានធម្មជាតិ។

**ស្ថិតិព្រៃឈើប្រចាំឆ្នាំ**

ដើម្បីបង្ហាញអំពីការអភិវឌ្ឍព្រៃឈើ តាមដាននិងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដើម្បីវិភាគផលិតផលក្នុងស្រុកសរុបនៃព្រៃឈើ ដើម្បីពិចារណាអំពីការនាំចេញនៃព្រៃឈើ និងដើម្បីឆ្លុះបញ្ចាំងអំពីចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីការការពារធនធានធម្មជាតិ។

**ស្ថិតិផលិតកម្មដំណាំកៅស៊ូប្រចាំឆ្នាំ**

ដើម្បីតាមដានការអនុវត្តផលិតកម្មដំណាំកៅស៊ូ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីបង្ហាញអំពីការកែលម្អដំណាំកៅស៊ូក្នុងផ្នែកដើម្បីវិភាគផលិតផលក្នុងស្រុកសរុបនៃវិស័យផលិតកម្មកៅស៊ូ និងដើម្បីវិភាគស្ថានភាពនាំចេញនិងរូបិយវត្ថុ។

**ស្ថិតិគ្រឿងយន្តកសិកម្មប្រចាំឆ្នាំ**

ដើម្បីតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បង្កើនផលិតកម្មកសិកម្មដើម្បីកាត់បន្ថយពលកម្មសត្វពាហនៈ សម្រាប់ការកាត់បន្ថយភាពក្រីក្រនៅតំបន់ទីជនបទនិងដើម្បីបង្កើនការប្រើប្រាស់គ្រឿងយន្តកសិកម្ម។

**ស្ថិតិថ្នាំកសិកម្ម និងសម្ភារៈកសិកម្មប្រចាំឆ្នាំ**

ដើម្បីផ្សព្វផ្សាយរាល់ទិន្នន័យស្ថិតិកសិកម្មមានភាពរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសភាពប្រកួតប្រជែង មានបរិយាប័ន្នផលិតផល មានគុណភាព មានសុវត្ថិភាព អាហាររូបត្ថម្ភ ព្រមទាំងធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព។

**៤.៥.៣ អ្នកប្រើប្រាស់ស្ថិតិ**

រាល់ទិន្នន័យកសិកម្មទាំងអស់នេះមានសារៈសំខាន់ដល់ អ្នករៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ អ្នកស្រាវជ្រាវជាតិ អន្តរជាតិព្រមទាំងអ្នកវិនិយោគទុន សិស្សានុសិស្សនិងនិស្សិត។

### ៤.៥.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិថ្លៃទំនិញកសិកម្ម | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិអង្កេតផ្ទៃដី ទិន្នផលនិងបរិមាណផលដំណាំ | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិផលិតកម្មនិងបសុព្យាបាល | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិជលផល | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិព្រៃឈើ | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិផលិតកម្មដំណាំកៅស៊ូ | ២០២២ | ២០២៣ | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |
| ស្ថិតិគ្រឿងយន្តកសិកម្ម | - | - | - |
| ស្ថិតិថ្នាំកសិកម្ម និងសម្ភារៈកសិកម្ម | ២០១៨ | - | ស្ថិតិកសិកម្ម ឆ្នាំ២០២២ |

## ៤.៦ ក្រសួងអភិវឌ្ឍន៍ជនបទ

### ៤.៦.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងអភិវឌ្ឍន៍ជនបទគឺជាការងារអន្តរវិស័យដ៏ធំមួយដែលគ្របដណ្តប់លើវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹក និងអនាម័យ និងវិស័យដទៃទៀត នៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច នៅតំបន់ជនបទ ។ការងារអន្តរវិស័យនេះ មានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយហេតុថា អត្រាភាពក្រីក្រមានកម្រិតខ្ពស់ នៅក្នុងចំណោមប្រជាជនដែលកំពុងរស់នៅតំបន់ជនបទ។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចយកវិធីសាស្ត្រពហុមុខ ដើម្បីជំរុញការអភិវឌ្ឍជនបទ និងការបង្កើនលទ្ធភាពនិងសមត្ថភាពដល់សហគមន៍មូលដ្ឋាន ជាពិសេស គណៈកម្មាធិការអភិវឌ្ឍន៍ភូមិក្នុងការរៀបចំផែនការ និងការគ្រប់គ្រងលើការអភិវឌ្ឍមូលដ្ឋានផ្ទាល់របស់ខ្លួន ។

ការធ្វើវិមជ្ឈការ និង វិសហមជ្ឈការលើការផ្តល់សេវាសាធារណៈ ការគាំទ្រដល់កម្មវិធីទាំងឡាយដែលមានការចូលរួមជាលក្ខណៈវិមជ្ឈការ និងដែលផ្តោតទៅតាមវិស័យ និងការផ្តល់ឥណទានដល់គ្រួសារ និងអាជីវកម្មធុនតូចៗ គឺជាឧទាហរណ៍មួយចំនួន ដែលបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យនេះ ។

ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័នក្នុងវិស័យអភិវឌ្ឍន៍ជនបទកំពុងដំណើរការទៅយ៉ាងល្អតាមរយៈការរៀបចំក្របខណ្ឌគតិយុត្ត និងគោលនយោបាយដែលចាំបាច់សម្រាប់អនុវត្តសកម្មភាពនានាក្នុងវិស័យនេះ រួមមានគោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ និងបទដ្ឋានគតិយុត្តផ្សេងៗទៀត ៖

-គោលនយោបាយទី១ ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋជនបទឱ្យមានគម្លាតខិតជិតទីប្រជុំជននៅឆ្នាំ ២០២៥ ។

-គោលនយោបាយទី២ ជំរុញកំណើនសេដ្ឋកិច្ចជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះ ដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ ។

### ៤.៦.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិផ្លូវជនបទប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាលដំណើរការទិន្នន័យធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

**ស្ថិតិទឹកស្អាតជនបទប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាល ការធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវ ប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ស្ថិតិបង្គន់អនាម័យជនបទប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាលការធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវ ប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ស្ថិតិក្រុមជនជាតិភាគតិចប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាលការធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវ ប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ស្ថិតិផ្នែកប្រព័ន្ធធារាសាស្ត្រខ្នាតតូចប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាលដំណើរការទិន្នន័យធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

**ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ**

ការប្រមូលទិន្នន័យរដ្ឋបាលដំណើរការទិន្នន័យធានាគុណភាពការវិភាគទិន្នន័យការផ្សព្វផ្សាយការកែលម្អឡើងវិញនូវប្រព័ន្ធព័ត៌មានមូលដ្ឋានទិន្នន័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

### ៤.៦.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងអង្គការដៃគូក្រៅរាជរដ្ឋាភិបាល។

### ៤.៦.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិផ្លូវជនបទ | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិផ្លូវជនបទ ឆ្នាំ ២០២២ |
| ស្ថិតិទឹកស្អាតជនបទ | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិទឹកស្អាតតាមជនបទឆ្នាំ ២០២២ |
| ស្ថិតិបង្គន់អនាម័យជនបទ | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិបង្គន់អនាម័យតាមជនបទ២០២២ |
| ស្ថិតិក្រុមជនជាតិភាគតិច | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិក្រុមជនជាតិភាគតិច ឆ្នាំ ២០២២ |
| ស្ថិតិផ្នែកប្រព័ន្ធធារាសាស្ត្រខ្នាតតូច | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិប្រព័ន្ធធារាសាស្ត្រខ្នាតតូច ឆ្នាំ ២០២២ |
| ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទ | ២០២២ | ២០២៣ | របាយការណ៍ ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០២២ |

## ៤.៧ ក្រសួងពាណិជ្ជកម្ម

### ៤.៧.១ ភារកិច្ចនិងការទទួលខុសត្រូវ

ក្រសួងពាណិជ្ជកម្ម មានការងារទទួលខុសត្រូវលើការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពក្នុងវិស័យពាណិជ្ជកម្ម ធានានូវគុណភាព ប្រសិទ្ធភាពការងារទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គភាព

ក្រៅប្រទេស សហគ្រាសសាធារណៈ ក្នុងការលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជនលើគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរីដោយគ្របដណ្តប់លើគ្រប់វិស័យពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

## ៤.៧.២ អង្កេតស្ថិតិ និងគោលដៅ

### ស្ថិតិការចុះបញ្ជីពាណិជ្ជកម្មប្រចាំឆ្នាំ

តាមដានចំនួនក្រុមហ៊ុន និងសហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម និងសកម្មភាពពាក់ព័ន្ធដែលអាចប្រើសម្រាប់វិភាគលើស្ថានភាពពាណិជ្ជកម្ម ផលិតកម្ម និងសកម្មភាពពាក់ព័ន្ធរបស់វិស័យឯកជន។

### ស្ថិតិការចុះបញ្ជីម៉ាកប្រចាំឆ្នាំ

តាមដានចំនួនក្រុមហ៊ុន និងសហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម និងសកម្មភាពពាក់ព័ន្ធដែលអាចប្រើសម្រាប់វិភាគលើស្ថានភាពពាណិជ្ជកម្ម ផលិតកម្ម និងសកម្មភាពពាក់ព័ន្ធរបស់វិស័យឯកជន។

### ស្ថិតិចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រចាំឆ្នាំ

វិភាគទៅលើទិន្នន័យសម្រាប់ការងារពាណិជ្ជកម្ម។

### ស្ថិតិក្រុមហ៊ុន រោងចក្រ ចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ

វិភាគទៅលើទិន្នន័យសម្រាប់ការងារពាណិជ្ជកម្ម។

### ស្ថិតិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ

វិភាគទៅលើទិន្នន័យសម្រាប់ការងារពាណិជ្ជកម្ម។

## ៤.៧.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានៈសិស្ស និសិត្ស អង្គការជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នាយកដ្ឋាននាំចេញនាំចូល និងអ្នកវិនិយោគជាតិ និងអន្តរជាតិ។

## ៤.៧.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិការចុះបញ្ជីពាណិជ្ជកម្មប្រចាំឆ្នាំ | ២០២២ | ២០២២ | របាយការណ៍លទ្ធផលការងារចុះបញ្ជីពាណិជ្ជកម្មឆ្នាំ ២០២២ |
| ស្ថិតិចុះបញ្ជីម៉ាកប្រចាំឆ្នាំ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារកម្មសិទ្ធិបញ្ញាឆ្នាំ ២០២២ |
| ស្ថិតិចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រចាំឆ្នាំ | ២០២១-២២ | ២០២២ | ស្ថិតិចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រចាំឆ្នាំ |
| ស្ថិតិក្រុមហ៊ុន រោងចក្រ ចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ | ២០២២ | ២០២២ | របាយការណ៍បូកសរុប១២ខែ ឆ្នាំ២០២២ |
| ស្ថិតិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ | ២០២២ | ២០២២ | Cambodai Export under FTA and GSP/MFN Scheme 2022 |

## ៤.៨ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### ៤.៨.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានការងារទទួលខុសត្រូវ រៀបចំប្រកាសបង្កើត និងវិញ្ញាបនបត្រដំណើរការរោងចក្រគ្រប់គ្រងការងារស្ថិតិឧស្សាហកម្ម ដោយប្រមូលទិន្នន័យ និងវិភាគវាយតម្លៃលទ្ធផលអនុវត្តឧស្សាហកម្ម រៀបចំគោលនយោបាយយុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍន៍ឧស្សាហកម្មស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរាជរដ្ឋាភិបាល និងអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

### ៤.៨.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិរោងចក្រឧស្សាហកម្មប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ**

គ្រប់គ្រងចំនួនរោងចក្រឧស្សាហកម្ម កម្លាំងពលកម្ម បរិមាណផលិតផល តម្លៃបរិមាណផលិតផល និងទិន្នន័យមួយចំនួនទៀតដែលបម្រើក្នុងខ្សែច្រវាក់ផលិតកម្ម។

**ស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម**

គ្រប់គ្រងចំនួនរោងចក្រ សហគ្រាស និងបណ្តុះបណ្តាល

**ស្ថិតិការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម**

គ្រប់គ្រងចំនួនស្ថិតិរោងចក្រទូទាំងប្រទេស ដែលបានចុះបញ្ជីក្រសួង រួមមានរោងចក្របង្កើតថ្មី ការប្តូរទីតាំងរោងចក្រ ការពង្រីកផលិតកម្ម ការបង្កើតសាខាថ្មី និងការប្តូរនាមករណ៍ជាដើម។ល។ ដែលជួយដល់ការព្យាករណ៍កំណើនសេដ្ឋកិច្ច និងដាក់ផែនការយុទ្ធសាស្ត្រ ក្នុងការទាក់ទាញវិនិយោគបង្កើតរោងចក្រលើវិស័យថ្មីៗដែលមិនទាន់មានដូចជា ផ្នែកអេឡិចត្រូនិច និងយានយន្ត។

**ស្ថិតិទឹកស្អាតប្រចាំឆ្នាំ**

ពិនិត្យ និងតាមដានវឌ្ឍនភាពនៃសេវាគ្របដណ្តប់ទឹកស្អាត

### ៤.៨.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បង ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ព្រមទាំងស្ថាប័នពាក់ព័ន្ធ។

### ៤.៨.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិរោងចក្រឧស្សាហកម្មប្រចាំខែ ត្រីមាសនិងឆ្នាំ | ២០២១ | ២០២២ | សៀវភៅកម្រងស្ថិតិរោងចក្រឆ្នាំ២០២២ |
| ស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម | - | - | ព្រឹត្តិបត្រលេខ០២ស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មផ្នែកកម្មន្តសាល២០១៧ |
| ស្ថិតិការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម | ២០២២ | ២០២៣ | សៀវភៅកម្រងស្ថិតិរោងចក្រឆ្នាំ២០២២ |
| ស្ថិតិទឹកស្អាតប្រចាំឆ្នាំ | ២០២២ | ២០២៣ | ទិន្នន័យទឹកស្អាតតាមបំពង់សម្រាប់ទីប្រជុំជន |

## ៤.៩ ក្រសួងរ៉ែ និងថាមពល

### ៤.៩.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងរ៉ែ និងថាមពល មានបេសកកម្មដឹកនាំគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

### ៤.៩.២ អង្កេតស្ថិតិនិងគោលដៅ

**ស្ថិតិផលិតកម្មថាមពលអគ្គិសនីប្រចាំឆ្នាំ**

ធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ស្ថិតិនាំចូលថាមពលអគ្គិសនីប្រចាំឆ្នាំ**

ធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ស្ថិតិអានុភាពថាមពលអគ្គិសនីប្រចាំឆ្នាំ**

ធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។

**ស្ថិតិអាជ្ញាបណ្ណធនធានរ៉ែប្រចាំឆ្នាំ**

ធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។

### ៤.៩.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមាន ក្រសួងរ៉ែ និងថាមពល ក្រសួងពាក់ព័ន្ធ និងរាជរដ្ឋាភិបាល។

### ៤.៩.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រោងឆ្នាំ | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិផលិតកម្មថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | - | របាយការណ៍សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបានរយៈពេល៥ឆ្នាំ(២០១៨ដល់ខែកញ្ញា ២០២៣) |
| ស្ថិតិនាំចូលថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | - | របាយការណ៍សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបានរយៈពេល៥ឆ្នាំ(២០១៨ដល់ខែកញ្ញា ២០២៣) |
| ស្ថិតិអានុភាពថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | - | របាយការណ៍សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបានរយៈពេល៥ឆ្នាំ(២០១៨ដល់ខែកញ្ញា ២០២៣) |
| ស្ថិតិអាជ្ញាបណ្ណធនធានរ៉ែប្រចាំឆ្នាំ | ២០២២ | - | របាយការណ៍សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបានរយៈពេល៥ឆ្នាំ(២០១៨ដល់ខែកញ្ញា ២០២៣) |

## ៤.១០ ក្រសួងអប់រំយុវជន និងកីឡា

### ៤.១០.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងអប់រំយុវជន និងកីឡាមានភារកិច្ចដើម្បីជួយគាំទ្រអ្នកធ្វើគោលនយោបាយដោយផ្តល់ស្ថិតិ និងសូចនាករអប់រំ សម្រាប់រៀបចំគោលនយោបាយ កម្មវិធីត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តសកម្មភាព និងលើកទិសដៅដោយផ្តោតលើកិច្ចអភិវឌ្ឍន៍ធនធានមនុស្សស្របទៅនឹងទីផ្សារសេរី។ ដើម្បីលើកកម្ពស់គុណភាពអប់រំឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗ នៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពទាំងចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅ និងចេះរស់នៅជាមួយ

គ្នា។ ជាប្រភពផ្តល់ព័ត៌មានអប់រំដ៏ប្រសើរបំផុត ក្នុងការងារកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់អ្នកធ្វើគោលនយោបាយក្នុងការធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវ។

### ៤.១០.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំ**

គោលបំណងនៃការប្រមូលស្ថិតិនេះគឺសម្រាប់ធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអប់រំនៅក្នុងប្រទេសកម្ពុជា ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន។

**ស្ថិតិឧត្តមសិក្សាប្រចាំឆ្នាំ**

រៀបចំចងក្រងសម្រាប់សន្និបាតអប់រំប្រចាំឆ្នាំនីមួយៗ។

**ស្ថិតិអប់រំក្រៅប្រព័ន្ធប្រចាំឆ្នាំ**

ស្ថិតិត្រូវបានចងក្រងដើម្បីជារបាយការណ៍ឆ្លុះបញ្ចាំងការអនុវត្តការងារអនុវិស័យអប់រំក្រៅប្រព័ន្ធ និងរៀបចំគោលនយោបាយ។

### ៤.១០.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមាន ក្រសួងអប់រំយុវជននិងកីឡាផ្ទាល់ដែលមាននាយកដ្ឋានជំនាញ មន្ទីរអប់រំថ្នាក់រាជធានីខេត្ត ក្រុង ខណ្ឌ ស្រុក និងសាលារៀន ក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិនិងអន្តរជាតិ ដៃគូរអភិវឌ្ឍន៍ រួមទាំងអ្នកស្រាវជ្រាវផងដែរ។

### ៤.១០.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំ | ២០២២-២៣ | ២០២៣ | ស្ថិតិនិងសូចនាករអប់រំសាធារណៈថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងអប់រំឯកជន ឆ្នាំសិក្សា២០២២-២០២៣ |
| ស្ថិតិឧត្តមសិក្សា | ២០២២-២៣ | ២០២៣ | កម្រងស្ថិតិឧត្តមសិក្សាឆ្នាំសិក្សា២០២២-២៣ |
| ស្ថិតិអប់រំក្រៅប្រព័ន្ធ | ២០២១-២២ | ២០២៣ | ស្ថិតិនិងសូចនាករអប់រំក្រៅប្រព័ន្ធឆ្នាំ២០២២ |

## ៤.១១ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

### ៤.១១.១ ភារកិច្ចនិងការទទួលខុសត្រូវ

ភារកិច្ចរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាគឺដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទាទូទាំងព្រះរាជាណាចក្រកម្ពុជា។

### ៤.១១.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

រៀបចំនិងគ្រប់គ្រងទិន្នន័យ ផែនការ តាមដាន និងត្រួតពិនិត្យ។

### ស្ថិតិបេឡាជាតិ អតីតយុទ្ធជនប្រចាំឆ្នាំ

រៀបចំនិងគ្រប់គ្រងទិន្នន័យ ផែនការ តាមដាន និងត្រួតពិនិត្យ។

### ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ

រៀបចំនិងគ្រប់គ្រងទិន្នន័យ ផែនការ តាមដាន និងត្រួតពិនិត្យ។

## ៤.១១.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា រាជរដ្ឋាភិបាលកម្ពុជាអ្នកស្រាវជ្រាវនិងអង្គការមិនមែនរដ្ឋាភិបាល។

## ៤.១១.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ២០២២ | ២០២២ | របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២២ |
| ស្ថិតិបេឡាជាតិ អតីតយុទ្ធជនប្រចាំឆ្នាំ | ២០២២ | ២០២២ | របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២២ |
| ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ | ២០២២ | ២០២២ | របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២២ |

# ៤.១២ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

## ៤.១២.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់មានភារកិច្ចនិងទទួលខុសត្រូវលើការរៀបចំដែនដី នគរូបនីយកម្ម ការងារសំណង់ ការងាររដ្ឋបាលដីធ្លី ការងារលើលំនៅដ្ឋាន ការងារបែងចែងចែកដីសម្បទានសង្គមកិច្ច ការងារដោះស្រាយវិវាទដីធ្លី ការងារគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា និងការងារផ្សេងៗទៀតដែលរដ្ឋាភិបាលប្រគល់ជូន។

## ៤.១២.២ អង្កេតស្ថិតិ និងគោលដៅ

### ស្ថិតិវិស័យសំណង់ប្រចាំឆ្នាំ

ជាឧបករណ៍មានប្រយោជន៍សម្រាប់ការត្រួតពិនិត្យវាយតម្លៃប្រសិទ្ធភាព និងជាម៉ែត្រវាស់ស្ទង់អំពីការផ្តល់សេវាសាធារណៈ លើវិស័យសំណង់និងជាកញ្ចក់ឆ្លុះបញ្ចាំងពីការអនុវត្តផែនការសកម្មភាពរបស់ក្រសួង។

### ស្ថិតិវិស័យដីធ្លីប្រចាំឆ្នាំ

ជាឧបករណ៍មានប្រយោជន៍សម្រាប់ការត្រួតពិនិត្យវាយតម្លៃប្រសិទ្ធិភាព និងជាម៉ែត្រវាស់ស្ទង់អំពីការផ្តល់សេវាសាធារណៈ លើការចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់(រដ្ឋ និងឯកជន)និងជាកញ្ចក់ឆ្លុះបញ្ចាំងពីការអនុវត្តផែនការសកម្មភាពរបស់ក្រសួង។

### ស្ថិតិវិស័យរៀបចំដែនដីនគរូបនីយកម្មប្រចាំឆ្នាំ

ជាឧបករណ៍មានប្រយោជន៍សម្រាប់ការត្រួតពិនិត្យវាយតម្លៃប្រសិទ្ធភាព និងជាម៉ែត្រវាស់ស្ទង់អំពីការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌នៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដីនិងជាកញ្ចក់ឆ្លុះបញ្ចាំងពីការអនុវត្តផែនការសកម្មភាពរបស់ក្រសួង។

### ៤.១២.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងៗមានដូចជា អ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្ត អ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិជាពិសេសការអភិវឌ្ឍលើវិស័យអចលនទ្រព្យនៅកម្ពុជា។

### ៤.១២.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិវិស័យសំណង់ប្រចាំឆ្នាំ | ២០២១ | ២០២២ | សៀវភៅស្ថិតិប្រចាំឆ្នាំ២០២១លើវិស័យដីធ្លីសំណង់ និងរៀបចំដែនដីនគរូបនីយកម្ម |
| ស្ថិតិវិស័យដីធ្លីប្រចាំឆ្នាំ | ២០២១ | ២០២២ | សៀវភៅស្ថិតិប្រចាំឆ្នាំ២០២១លើវិស័យដីធ្លីសំណង់ និងរៀបចំដែនដីនគរូបនីយកម្ម |
| ស្ថិតិវិស័យរៀបចំដែនដីនគរូបនីយកម្មប្រចាំឆ្នាំ | ២០២១ | ២០២២ | សៀវភៅស្ថិតិប្រចាំឆ្នាំ២០២១លើវិស័យដីធ្លីសំណង់ និងរៀបចំដែនដីនគរូបនីយកម្ម |

## ៤.១៣ ក្រសួងបរិស្ថាន

### ៤.១៣.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងបរិស្ថានបានកំណត់គោលដៅជាយុទ្ធសាស្ត្រចំនួនបួនគឺៈ ការធ្វើទំនើបកម្មស្ថាប័នកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព មកធ្វើជាមូលដ្ឋានគ្រឹះសម្រាប់តម្រង់ទិសដល់ការរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំដៅធានាឱ្យបាននូវតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ។

### ៤.១៣.២ អង្កេតស្ថិតិ និងគោលដៅ

#### ស្ថិតិការវាយតម្លៃការបំពុលសំណល់រឹង សំណល់រាវ និងការបំពុលខ្យល់

គោលដៅគឺបរិមាណសំណល់រឹង និងសំណល់សម្រាប់កែច្នៃតាមដានគុណភាពទឹកសាធារណៈនៅតាមទន្លេ ស្ទឹង បឹង សំណល់ទឹកលូ និងត្រួតពិនិត្យគុណភាពខ្យល់សាធារណៈការវាយតម្លៃការប៉ះពាល់បរិស្ថាន។

#### ស្ថិតិការវាយតម្លៃលើការប្រែប្រួលធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ

ភាពច្បាស់លាស់លើចំនួននិងទំហំផ្ទៃដីតំបន់ការពារធម្មជាតិសុវត្ថិភាពក្នុងការគ្រប់គ្រងនិងជៀសវាងទំនាស់ផ្សេងៗ។

#### ស្ថិតិចំនួនសហគមន៍តំបន់ការពារធម្មជាតិ

គោលដៅគឺលើកកម្ពស់ជីវភាពសហគមន៍តាមរយៈបង្កើតជម្រើសមុខរបរនិងទេសចរណ៍ធម្មជាតិ។

### ស្ថិតិការវាយតម្លៃលើការប្រែប្រួលអាកាសធាតុ

គោលដៅគឺកាត់បន្ថយភាពងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសេដ្ឋកិច្ច និងសង្គម។ លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជនក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ៤.១៣.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានដូចជារាជរដ្ឋាភិបាលមន្ត្រីគ្រប់ជាន់ថ្នាក់របស់ក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ។

## ៤.១៣.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិការវាយតម្លៃការបំពុលសំណល់រឹង សំណល់រាវ និងការបំពុលខ្យល់ | ២០២២ | ២០២៣ | របាយការណ៍បូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ ២០២២ និងទិសដៅការងារ២០២៣ |
| ស្ថិតិវាយតម្លៃលើការប្រែប្រួលធម្មជាតិក្នុងតំបន់ការពារធម្មជាតិ | - | - | - |
| ស្ថិតិចំនួនសហគមន៍តំបន់ការពារធម្មជាតិ | - | - | - |
| ស្ថិតិវាយតម្លៃលើការប្រែប្រួលអាកាសធាតុ | - | - | - |

## ៤.១៤ ក្រសួងធនធានទឹក និងឧតុនិយម

## ៤.១៤.១ ភារកិច្ច និងការទទួលខុសត្រូវ

ភារកិច្ចរបស់ក្រសួងធនធានទឹកនិងឧតុនិយមគឺកំណត់ និងបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រការប្រើប្រាស់ការអភិវឌ្ឍ និងអភិរក្សប្រកបដោយនិរន្តរភាពនៃធនធានទឹកតាមថ្នាក់ជាតិ និងអន្តរជាតិស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីសិក្សា និងការស្រាវជ្រាវសក្តានុពលធនធានទឹករួមទាំងលើដីក្រោមដី និងអាកាស ដើម្បីបង្កើតនូវបច្ចេកទេសវិទ្យាសាស្ត្រមូលដ្ឋាន ដើម្បីកសាងផែនការរយៈពេលខ្លីមធ្យម និងវែងសម្រាប់ធ្វើអាជីវកម្មការអភិវឌ្ឍ និងថែរក្សាការពារធនធានទឹក។

## ៤.១៤.២ អង្កេតស្ថិតិ និងគោលដៅ

### ស្ថិតិឧតុនិយមប្រចាំថ្ងៃ ប្រចាំខែប្រចាំត្រីមាសនិងប្រចាំឆ្នាំ

ប្រមូលទិន្នន័យសម្រាប់ប្រើប្រាស់ព្យាករណ៍អាកាសធាតុរយៈពេលខ្លី និងវែង។

### ស្ថិតិជលសាស្ត្រប្រចាំថ្ងៃប្រចាំខែនិងប្រចាំឆ្នាំ

ដើម្បីវិភាគសម្រាប់ការព្យាករណ៍ទឹកជំនន់ សាងសង់រចនាសម្ព័ន្ធ និងការដាំដុះ។

### ស្ថិតិប្រព័ន្ធស្រោចស្រពប្រចាំឆ្នាំ

ដើម្បីជាទិន្នន័យ ព័ត៌មានប្រព័ន្ធ គំនូសបំព្រួញទីតាំង។

## ៤.១៤.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានក្រសួងសាមី MRC និងស្ថាប័នស្រាវជ្រាវកសិកម្ម សំណង់ និងឧស្សាហកម្ម។

### ៤.១៤.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិឧតុនិយម | - | - | - |
| ស្ថិតិជលសាស្ត្រ | - | - | - |
| ស្ថិតិប្រព័ន្ធស្រោចស្រព | - | - | - |

## ៤.១៥ ក្រសួងព័ត៌មាន

### ៤.១៥.១ ការងារនិងការទទួលខុសត្រូវ

ក្រសួងព័ត៌មានត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ ដឹកនាំ និងគ្រប់គ្រងលើវិស័យព័ត៌មាន និងសោតទស្សន៍នៃព្រះរាជាណាចក្រកម្ពុជា ដោយទទួលខុសត្រូវលើការផ្តល់និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជន តាមមធ្យោបាយដូចជា វិទ្យុ ទូរទស្សន៍ ព្រឹត្តិបត្រសារព័ត៌មានទស្សនាវដ្ដីរូបថតនិងប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ ផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការអាជីវកម្ម និងត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍បញ្ជូនសារ(លើកលែងប្រព័ន្ធAMនិងSW)។ ការសហប្រតិបត្តិការជាមួយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីបែងចែកហ្វ្រេកង់ស្ថានីយវិទ្យុ និងទូរទស្សន៍ការត្រួតពិនិត្យខ្លឹមសារសារព័ត៌មានព្រឹត្តិបត្រទស្សនាវដ្តីនិងការបោះពុម្ពផ្សេងៗទៀត។ ការត្រួតពិនិត្យព័ត៌មានដែលផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការត្រួតពិនិត្យរោងពុម្ព និងសេវាកម្មដទៃទៀតដែលទាក់ទងនឹងការផ្សព្វផ្សាយផលិតផលសោត-ចក្ខុ។ ការផ្តល់អាជ្ញាបណ្ណសម្រាប់ការនាំចូល និងនាំចេញទស្សនាវដ្តីសារព័ត៌មានព្រឹត្តិបត្រនិងផលិតផលសោត-ចក្ខុ។ ធ្វើការសម្របសម្រួលការងារដល់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា។

### ៤.១៥.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយវិទ្យុទូរទស្សន៍សារព័ត៌មានប្រចាំឆ្នាំ**

ដើម្បីចងក្រងនិងផលិតស្ថិតិប្រចាំខែប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

### ៤.១៥.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បង រួមមានដូចជាទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងព័ត៌មាន អ្នកស្រាវជ្រាវនិងនិស្សិត។

### ៤.១៥.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយវិទ្យុទូរទស្សន៍សារព័ត៌មាន | ២០២២ | - | ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍និងសារព័ត៌មាន |

## ៤.១៦ ក្រសួងយុត្តិធម៌

### ៤.១៦.១ ភារកិច្ច និងការទទួលខុសត្រូវ

មុខងារ និងភារៈកិច្ចសំខាន់ៗរបស់ក្រសួងយុត្តិធម៌ គឺជានាយុត្តិធម៌សម្រាប់មនុស្សគ្រប់រូបដែលស្ថិតនៅក្រោមច្បាប់ដើម្បីជានាការបំពេញមុខងារនៃគ្រប់ផ្នែក និងកម្រិតនៃស្ថាប័នតុលាការ និងការកាត់ទោសដើម្បីតាមដានការប្រតិបត្តិច្បាប់ការកាត់ក្ដីនិងគ្រប់កម្រិតនៃតុលាការនិងស្ថាប័នព្រះរាជអាជ្ញា ដើម្បីពង្រាងច្បាប់ក្នុងការងារយុត្តិធម៌ ដើម្បីគ្រប់គ្រង និងរៀបចំសារាចរសម្រាប់គោលបំណងនៃការអនុវត្តច្បាប់ក្នុងការងារយុត្តិធម៌ ដើម្បីស្រាវជ្រាវអប់រំនិងធ្វើការផ្សព្វផ្សាយច្បាប់ទាក់ទងនឹងការងារយុត្តិធម៌ ដើម្បីរៀបចំ និងតាមដានគ្រប់កម្រិតនៃដំណើរការរដ្ឋបាលនៃស្ថាប័នតុលាការ និងការកាត់ទោសដើម្បីធ្វើអធិការកិច្ចក្នុងករណីមានពាក្យបណ្ដឹងពីនរណាម្នាក់ ឬពីអង្គភាពច្បាប់ដែលកើតឡើងនៅគ្រប់កម្រិតនៃស្ថាប័នតុលាការ និងការកាត់ទោស ដើម្បីគ្រប់គ្រងមណ្ឌលឃុំឃាំង និងពន្ធនាគារសម្រាប់គោលដៅនៃការអនុវត្តច្បាប់ ដើម្បីពិនិត្យឡើងវិញ និងផ្តល់គំនិតអំពីពង្រាងច្បាប់របស់ក្រសួងនិងស្ថាប័ននានា។

### ៤.១៦.២ អង្កេតស្ថិតិ និងគោលដៅ

#### ស្ថិតិករណីវិវាទបទរដ្ឋប្បវេណីគ្រប់សាលាដំបូងខេត្តនិងរាជធានីប្រចាំឆ្នាំ

ដើម្បីតាមដានការងារអនុវត្តន៍កន្លងមក និងចងក្រងស្ថិតិរឿងក្ដីរដ្ឋប្បវេណី ។

#### ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌគ្រប់សាលាដំបូងខេត្តនិងរាជធានីប្រចាំឆ្នាំ

គ្មានព័ត៌មាន។

#### ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌទៅលើអនីតិជនគ្រប់សាលាដំបូងខេត្តនិងរាជធានីប្រចាំឆ្នាំ

សម្រាប់ធ្វើការបូកសរុបចំនួនជនល្មើស ជនរងគ្រោះជាអនីតិជន និងចំនួនប្រភេទបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តិទៅលើអនីតិជន។

#### ស្ថិតិកិច្ចការកសាងច្បាប់ប្រចាំឆ្នាំ

គ្មានព័ត៌មាន។

#### ស្ថិតិកិច្ចការផ្សព្វផ្សាយច្បាប់ប្រចាំឆ្នាំ

ដើម្បីវាស់វែងសូចនាករផែនការសកម្មភាព។

#### ស្ថិតិដោះស្រាយពាក្យបណ្ដឹងប្រចាំឆ្នាំ

គ្មានព័ត៌មាន។

### ៤.១៦.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងគឺទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

## ៤.១៦.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិករណីវិវាទបទរដ្ឋប្បវេណីគ្រប់សាលាដំបូង | - | - | - |
| ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌគ្រប់សាលាដំបូង | - | - | - |
| ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌទៅលើអនីតិជន | - | - | - |
| ស្ថិតិកិច្ចការកសាងច្បាប់ | - | - | - |
| ស្ថិតិកិច្ចការផ្សព្វផ្សាយច្បាប់ | - | - | - |
| ស្ថិតិដោះស្រាយពាក្យបណ្តឹង | - | - | - |

# ៤.១៧ ក្រសួងអធិការកិច្ច

## ៤.១៧.១ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងអធិការកិច្ច ត្រូវរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងរាល់កិច្ចការងារអធិការកិច្ចលើគ្រប់វិស័យ តាមដានអនុវត្តច្បាប់ ផ្សព្វផ្សាយច្បាប់ ទទួលនិងដោះស្រាយពាក្យបណ្តឹងសំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា។

## ៤.១៧.២ អង្កេតស្ថិតិ និងគោលដៅ

### ស្ថិតិការចុះផ្សព្វផ្សាយច្បាប់ប្រចាំឆ្នាំ

ដើម្បីផ្សព្វផ្សាយដល់សាធារណជនទទួលបានការយល់ដឹងទូលំទូលាយពាក់ព័ន្ធនឹងច្បាប់និងប្រតិបត្តិតាមសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងចងក្រងជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្តក្នុងការអនុវត្តបន្ត។

### ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួងស្ថាប័នប្រចាំឆ្នាំ

ដើម្បីតាមដានការអនុវត្តលើការចុះធ្វើអធិការកិច្ចលើវិស័យសំខាន់ៗរួមមាន វិស័យសេដ្ឋកិច្ច វិស័យរដ្ឋបាលទូទៅ និងវិស័យសង្គមកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យស្របតាមនីតិវិធី និងកាលៈទេសៈជាក់ស្តែង និងធានាឱ្យបាននូវភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងពង្រឹងអភិបាលកិច្ចល្អ ព្រមទាំងចងក្រងជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្តក្នុងការអនុវត្តបន្ត។

### ស្ថិតិទទួលនិងដោះស្រាយពាក្យបណ្តឹងប្រចាំឆ្នាំ

ដើម្បីចងក្រងជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្តក្នុងការអនុវត្តបន្ត។

### ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួងស្ថាប័នប្រចាំឆ្នាំ

ដើម្បីចងក្រងជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្តក្នុងការអនុវត្តបន្ត។

### ស្ថិតិទទួលនិងដោះស្រាយពាក្យបណ្តឹងប្រចាំឆ្នាំ

ដើម្បីពិនិត្យនិងដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋនិងមជ្ឈដ្ឋាននានា បញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងចងក្រងជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្តក្នុងការអនុវត្តបន្ត។

### ៤.១៧.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានក្រសួងអធិការកិច្ច ក្រសួងស្ថាប័ននានា រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។

### ៤.១៧.៤ ឈ្មោះរបាយការណ៍និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិការចុះផ្សព្វផ្សាយច្បាប់ | ២០២២ | ២០២៣ | ស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ក្រសួងអធិការកិច្ចឆ្នាំ២០២៣ |
| ស្ថិតិការអនុម័តច្បាប់ | - | - | - |
| ស្ថិតិសមាជិករដ្ឋសភាព្រឹទ្ធសភា | - | - | - |
| ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួងស្ថាប័ន | ២០២២ | ២០២៣ | ស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ក្រសួងអធិការកិច្ចឆ្នាំ២០២៣ |
| ស្ថិតិទទួលនិងដោះស្រាយពាក្យបណ្តឹង | ២០២២ | ២០២៣ | ស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ក្រសួងអធិការកិច្ចឆ្នាំ២០២៣ |

## ៤.១៨ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ៤.១៨.១ ភារកិច្ច និងការទទួលខុសត្រូវ

ដឹកនាំនិងគ្រប់គ្រងលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ រៀបចំគោលនយោបាយសម្របសម្រួលនិងជំរុញការប្រកួតប្រជែងក្នុងការផ្តល់សេវាប្រៃសណីយ៍និងទូរគមនាគមន៍។

### ៤.១៨.២ អង្កេតស្ថិតិ និងគោលដៅ

**ស្ថិតិអាជីវកម្មសេវាកម្មប្រៃសណីយ៍ប្រចាំឆ្នាំ**

របាយការណ៍ជូននិងតាមដានការអនុវត្តធៀបនឹងលទ្ធផលការងារសម្រាប់ឆ្នាំមុនៗ

**ស្ថិតិអាជីវកម្មសេវាកម្មទូរគមនាគមន៍ប្រចាំឆ្នាំ**

របាយការណ៍ជូននិងតាមដានការអនុវត្តធៀបនឹងលទ្ធផលការងារសម្រាប់ឆ្នាំមុនៗ

**ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**

របាយការណ៍ជូននិងតាមដានការអនុវត្តធៀបនឹងលទ្ធផលការងារសម្រាប់ឆ្នាំមុនៗ

**ស្ថិតិបណ្តុះបណ្តាលធនធានមនុស្សលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យានិងព័ត៌មាន**

របាយការណ៍ជូននិងតាមដានការអនុវត្តធៀបនឹងលទ្ធផលការងារសម្រាប់ឆ្នាំមុនៗ

### ៤.១៨.៣ អ្នកប្រើប្រាស់ស្ថិតិ

អ្នកប្រើប្រាស់ស្ថិតិសំខាន់ៗរួមមាន ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អង្គភាពនានា ក្រោមក្រសួងគ្រប់ប្រតិបត្តិករទូរស័ព្ទទាំងអស់ ក្រុមហ៊ុនអ៊ីនធឺណិតក្រុមហ៊ុនរបស់ រដ្ឋាភិបាល អ្នកស្រាវជ្រាវ និងនិស្សិតចុះកម្មសិក្សានៅក្រសួង។

## ៤.១៨.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិអាជីវកម្មសេវាកម្មប្រៃសណីយ៍ | ២០២២ | ២០២៣ | របាយការណ៍លទ្ធផលការងារឆ្នាំ២០២២និងទិសដៅការងារឆ្នាំ២០២៣ |
| ស្ថិតិអាជីវកម្មសេវាកម្មទូរគមនាគមន៍ | ២០២២ | ២០២៣ | របាយការណ៍លទ្ធផលការងារឆ្នាំ២០២២និងទិសដៅការងារឆ្នាំ២០២៣ |
| ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ២០២២ | ២០២៣ | របាយការណ៍លទ្ធផលការងារឆ្នាំ២០២២និងទិសដៅការងារឆ្នាំ២០២៣ |
| ស្ថិតិបណ្តុះបណ្តាលធនធានមនុស្សលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យានិងព័ត៌មាន | ២០២២ | ២០២៣ | របាយការណ៍លទ្ធផលការងារឆ្នាំ២០២២និងទិសដៅការងារឆ្នាំ២០២៣ |

## ៤.១៩ ក្រសួងសុខាភិបាល

### ៤.១៩.១ ភារកិច្ច និងការទទួលខុសត្រូវ

ក្រសួងសុខាភិបាលទទួលខុសត្រូវលើ ការកំណត់គោលនយោបាយសុខាភិបាល អភិវឌ្ឍន៍ផែនការ និងយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល អភិវឌ្ឍន៍វិធាន បទបញ្ញា និយ័តកម្ម និងគោលការណ៍ណែនាំ ដើម្បីបង្កើនគុណភាពសេវាសុខភាពជាអតិបរមាទាំងនៅផ្នែកសាធារណៈនិងឯកជនពិនិត្យតាមដានត្រួតពិនិត្យនិងវាយតម្លៃការងាររដ្ឋបាលនិងបច្ចេកទេសរបស់អង្គភាពក្រោមឱវាទស្រាវជ្រាវដើម្បីអភិវឌ្ឍន៍វិស័យសុខាភិបាល គ្រប់គ្រងធនធាន(មនុស្ស សម្ភារៈហិរញ្ញវត្ថុ និងព័ត៌មាន) នៅថ្នាក់កណ្តាល រាជធានីខេត្ត ស្រុក ខណ្ឌ និងឃុំសង្កាត់រៀបចំកម្មវិធីបង្ការនិងការថែទាំបឋមដើម្បីបន្ថយមូលហេតុនៃជំងឺសម្របសម្រួលធនធាន សង្កេតតាមដានការផលិតពាណិជ្ជកម្ម និងចែកចាយឱសថឧបករណ៍ពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ នៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន និងត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ។

### ៤.១៩.២ អង្កេតស្ថិតិ និងគោលដៅ

#### ស្ថិតិជំងឺឆ្លងប្រចាំខែនិងប្រចាំឆ្នាំ

ដើម្បីតាមដានជំងឺឆ្លងនិងដើម្បីធ្វើការស៊ើបអង្កេតនិងការវិភាគស្ថានភាពជំងឺឆ្លងនៅប្រទេសកម្ពុជានិងដើម្បីរៀបចំផែនការសម្រាប់ឆ្នាំបន្ទាប់និងការសិក្សាពីមេរោគឆ្លង។

#### ស្ថិតិសុខាភិបាលប្រចាំឆ្នាំ

ដើម្បីតាមដានស្ថានភាពសុខភាពប្រជាជន និងលទ្ធផលសមិទ្ធផលនៃវិនិយោគផ្នែកសុខភាពការធ្វើផែនការអំពីសុខភាពប្រចាំឆ្នាំការរៀបចំផែនការអភិវឌ្ឍន៍ គោលនយោបាយយុទ្ធសាស្ត្រអំពីសុខភាព និងការចែករំលែកព័ត៌មានសុខភាពដល់អ្នកប្រើប្រាស់។

#### ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនមានច្បាប់ប្រចាំឆ្នាំ

ដើម្បីយល់ដឹងអំពីចំនួនមណ្ឌលសុខភាពសាធារណៈ ដើម្បីរៀបចំផែនការសម្រាប់សេវាកម្មសុខភាព និងចំនួនសេវាកម្មសុខភាពឯកជន និងដើម្បីគ្រប់គ្រងនិងលុបបំបាត់សេវាកម្មសុខភាពខុសច្បាប់។ ស្ថិតិខាងលើនេះមិនត្រូវបានផ្តល់ឱ្យនៅក្នុងឆ្នាំនេះ។

អ្នកប្រើប្រាស់ស្ថិតិចម្បងរួមមានក្រសួងសុខាភិបាលក្រសួងពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍។

### ៤.១៩.៤ ឈ្មោះរបាយការណ៍ និងឆ្នាំផ្សព្វផ្សាយ

| ឈ្មោះស្ថិតិ | គ្រាយោង | ទិន្នន័យបានបោះពុម្ព | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិជម្ងឺឆ្លង | ២០២២ | ២០២៣ | របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨-២០២២និងទិសដៅការងារឆ្នាំ២០២៣ និងឆ្នាំបន្ត |
| ស្ថិតិចំណូលមិនមែនសារពើពន្ធ | ២០២២ | កំណត់ត្រារដ្ឋបាលនិងដ៏ទៃទៀត | - | កម្ពុជា | ប្រចាំខែ ត្រីមាស ឆ្នាំ |
| ស្ថិតិពាណិជ្ជកម្មក្រៅប្រទេស | ២០២២ | កំណត់ត្រារដ្ឋបាលនិងដ៏ទៃទៀត | - | កម្ពុជា | ប្រចាំខែ ត្រីមាស ឆ្នាំ |

## ៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិថ្លៃទំនិញកសិកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល អង្កេតនិងជំរឿន | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិអង្កេតផ្ទៃដី ទិន្នផលនិងបរិមាណផលដំណាំ | ២០២២ | កំណត់ត្រារដ្ឋបាល | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិផលិតកម្មនិងបសុព្យាបាល | ២០២២ | អង្កេតនិងជំរឿន | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិជលផល | ២០២២ | កំណត់ត្រារដ្ឋបាល | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិព្រៃឈើ | ២០២២ | អង្កេតនិងជំរឿន | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិផលិតកម្មដំណាំកៅស៊ូ | ២០២២ | កំណត់ត្រារដ្ឋបាល | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិគ្រឿងយន្តកសិកម្ម | ២០២២ | អង្កេតនិងជំរឿន | បុគ្គល គ្រួសារ សហគ្រាស និងរដ្ឋាភិបាល | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិថ្នាំកសិកម្ម និងសម្ភារៈកសិកម្ម | - | - | - | - | - |

## ៦. ក្រសួងអភិវឌ្ឍន៍ជនបទ

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិផ្លូវជនបទប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | ដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិទឹកស្អាតជនបទប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិបង្គន់អនាម័យជនបទប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | អង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិក្រុមជនជាតិភាគតិចប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | អង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិផ្នែកប្រព័ន្ធធារាសាស្ត្រខ្នាតតូចប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | អង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |
| ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទប្រចាំ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | អង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាសឆ្នាំ |

## ៧. ក្រសួងពាណិជ្ជកម្ម

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការចុះបញ្ជីពាណិជ្ជកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល | ក្រុមហ៊ុន/សហគ្រាស | កម្ពុជា | ប្រចាំខែ |
| ស្ថិតិចុះបញ្ជីម៉ាក | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែត្រីមាស ឆ្នាំ |
| ស្ថិតិចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាលនិងដ៏ទៃទៀត | ច្បាប់ | - | ប្រចាំខែត្រីមាស ឆ្នាំ |
| ស្ថិតិក្រុមហ៊ុន រោងចក្រ ចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាលនិងដ៏ទៃទៀត | សហគ្រាស | - | ប្រចាំខែ ឆ្នាំ |
| ស្ថិតិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាលនិងដ៏ទៃទៀត | ទឹកប្រាក់ជាUSD | - | ប្រចាំខែត្រីមាស ឆ្នាំ |

## ៨. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិរោងចក្រឧស្សាហកម្មសិប្បកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ |
| ស្ថិតិទឹកស្អាត | ២០២២ | កំណត់ត្រារដ្ឋបាល | - | ខេត្ត | ប្រចាំខែត្រីមាស |
| ស្ថិតិការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ |
| ស្ថិតិសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល | ដំរទៃទៀត | កម្ពុជា | ប្រចាំខែ |

## ៩. ក្រសួងរ៉ែ និងថាមពល

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិផលិតកម្មថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |
| ស្ថិតិអានុភាពថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |
| ស្ថិតិអាជ្ញាបណ្ណធនធានរ៉ែប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |
| ស្ថិតិនាំចូលថាមពលអគ្គិសនីប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |

## ១០. ក្រសួងអប់រំយុវជន និងកីឡា

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិមត្តេយ្យសិក្សានិងបឋមសិក្សា | ២០២២ | ដំណើរ | សាលារដ្ឋ និង សាលាឯកជន | កម្ពុជា ខេត្ត ស្រុក | ប្រចាំឆ្នាំ |
| ស្ថិតិឧត្តមសិក្សា | ២០២២ | ដំណើរ អង្កេត | ស្ថាប័នរដ្ឋរួមបញ្ចូលទាំងមេកូមិ និងគ្រឹះស្ថានក្រោមឱវាទក្រសួងអប់រំ យុវជននិងកីឡា | កម្ពុជា ខេត្ត និងដំរទៃទៀត | ប្រចាំឆ្នាំ |
| ស្ថិតិអប់រំក្រៅប្រព័ន្ធ | ២០២២ | បំពេញកម្រងសំណួរពីអ្នកអនុវត្តកម្មវិធី | ស្ថាប័នរដ្ឋរួមបញ្ចូលទាំងមេកូមិ និងអង្គការក្រៅរដ្ឋាភិបាល | កម្ពុជា ខេត្ត ស្រុក ឃុំ ភូមិ | ប្រចាំ ឆមាស ឆ្នាំ |

## ១១. ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| កុមារកំព្រានិងកុមាររងាយរងគ្រោះដែលនៅក្នុងមណ្ឌលថែទាំកុមារ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយម្សទា | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |

## ១២. ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិវិស័យសំណង់ប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត ស្រុក ឃុំ | ប្រចាំឆ្នាំ |
| ស្ថិតិវិស័យដីធ្លីប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត ស្រុក ឃុំ | ប្រចាំឆ្នាំ |
| ស្ថិតិវិស័យរៀបចំដែនដីនគរូបនីយកម្មប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត ស្រុក ឃុំ | ប្រចាំឆ្នាំ |

## ១៣. ក្រសួងបរិស្ថាន

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការវាយតម្លៃលើគុណភាពខ្យល់ គុណភាពទឹក សំណល់រឹង សំរាម ការបំពុល និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត ស្រុក ឃុំ | ប្រចាំខែ ឆមាស ឆ្នាំ |
| ស្ថិតិចំនួនតំបន់ធម្មជាតិ ទំហំផ្ទៃដីតំបន់ធម្មជាតិ បោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ ចំនួនឧទ្យានុរក្ស | - | - | - | - | - |
| ស្ថិតិចំនួនសហគមន៍តំបន់ការពារធម្មជាតិ | - | - | - | - | - |
| ស្ថិតិលើការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងជីវៈចម្រុះ | - | - | - | - | - |
| ទិន្នន័យផែនទីតំបន់ការពារធម្មជាតិ និងរបៀបអភិរក្សជីវៈចម្រុះ | - | - | - | - | - |

## ១៤. ក្រសួងធនធានទឹក និងឧតុនិយម

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិឧតុនិយម | - | - | - | - | - |
| ស្ថិតិជលសាស្ត្រ | - | - | - | - | - |
| ស្ថិតិប្រព័ន្ធស្រោចស្រព | - | - | - | - | - |

## ១៥. ក្រសួងព័ត៌មាន

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយវិទ្យុទូរទស្សន៍សារព័ត៌មាន | ២០២២ | កំណត់ត្រារដ្ឋបាល | ស្ថាប័នរដ្ឋរួមទាំងមេភូមិ | កម្ពុជា | ប្រចាំឆ្នាំ |

## ១៦. ក្រសួងយុត្តិធម៌

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិករណីវិវាទបទរដ្ឋប្បវេណីគ្រប់សាលាដំបូង | - | - | - | - | - |
| ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌទៅលើអនីតិជនគ្រប់សាលាដំបូង | - | - | - | - | - |
| ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌគ្រប់សាលាដំបូង | - | - | - | - | - |
| ស្ថិតិកិច្ចការកសាងច្បាប់ | - | - | - | - | - |
| ស្ថិតិកិច្ចការផ្សព្វផ្សាយច្បាប់ | - | - | - | - | - |
| ស្ថិតិដោះស្រាយពាក្យបណ្តឹង | - | - | - | - | - |

## ១៧. ក្រសួងអធិការកិច្ច

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការចុះផ្សព្វផ្សាយច្បាប់ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិការអនុម័តច្បាប់ | - | - | - | - | - |
| ស្ថិតិសមាជិករដ្ឋសភាព្រឹទ្ធសភា | - | - | - | - | - |
| ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួងស្ថាប័ន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិទទួលនិងដោះស្រាយពាក្យបណ្ដឹង | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |

## ១៨. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិអាជីកម្មសេវាកម្មប្រៃសណីយ៍ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត ស្រុក | ប្រចាំឆ្នាំ |
| ស្ថិតិអាជីវកម្មសេវាកម្មទូរគមនាគមន៍ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិបណ្តុះបណ្តាលធនធានមនុស្សលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យានិងព័ត៌មាន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |

## ១៩. ក្រសួងសុខាភិបាល

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិជំងឺឆ្លង | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត ស្រុក | ប្រចាំឆ្នាំ |
| ស្ថិតិសុខាភិបាល | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត ស្រុក | ប្រចាំឆ្នាំ |
| ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនមានច្បាប់ | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត ស្រុក | ប្រចាំឆ្នាំ |

## ២០. ក្រសួងសាធារណការ និងដឹកជញ្ជូន

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតារាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការចុះបញ្ជីយានយន្តនិងនាវា | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិសាធារណការនិងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិគ្រោះថ្នាក់ចរាចរណ៍ផ្លូវថ្នល់ផ្លូវដែកនិងផ្លូវទឹក | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា | ប្រចាំឆ្នាំ |

## ២១. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការចុះបញ្ជីកម្មសិទ្ធិបញ្ញានិងសិទ្ធិអ្នកនិពន្ធ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិភ្ញៀវចូលទស្សនាទីតាំងវប្បធម៌សំខាន់ៗប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិទាក់ទងនឹងវិស័យភាពយន្តប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិអង្គការ សហគម ក្រុមហ៊ុននិងស្ថាប័នដែលធ្វើការលើវិស័យវប្បធម៌ប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិត្រួតពិនិត្យវត្ថុសិល្បៈថ្មីនិងវត្ថុសិល្បៈចម្លងដូចសម្រាប់នាំចេញប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិបេតិកភណ្ឌវប្បធម៌រូបីនិង អរូបីប្រចាំឆ្នាំ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |

## ២២. ក្រសួងទេសចរណ៍

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិទេសចរណ៍ជាតិ | - | | - | - | - |
| ស្ថិតិទេសចរណ៍អន្តរជាតិ | - | | - | - | - |
| ស្ថិតិមូលដ្ឋានអាជីវកម្មទេសចរណ៍ | - | | - | - | - |
| ស្ថិតិសេវាកម្មស្នាក់នៅ | ២០២២ | កំណត់ត្រារដ្ឋបាល | បុគ្គល សហគ្រាស | កម្ពុជា ខេត្ត | ប្រចាំខែ ត្រីមាស ឆ្នាំ |
| ស្ថិតិចំណូលទេសចរណ៍អន្តរជាតិ | - | | - | - | - |
| ស្ថិតិទេសចរណ៍ជាតិចេញក្រៅ | ២០២២ | កំណត់ត្រារដ្ឋបាល | បុគ្គល សហគ្រាស | កម្ពុជា ខេត្ត | ប្រចាំខែត្រីមាស ឆ្នាំ |
| មុខរបរនិងការងារទេសចរណ៍ | ២០២២ | អង្កេត និងដ៏ទៃទៀត | បុគ្គល សហគ្រាស | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |

## ២៣. ក្រសួងធម្មការ និងសាសនា

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិសាសនា និងគ្រឹះស្ថានសាសនា | - | - | - | - | - |

## ២៤. ក្រសួងកិច្ចការនារី

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិយេនឌ័រ | ២០២២ | កំណត់ត្រារដ្ឋបាល ជំរឿន អង្កេត ដ៏ទៃទៀត | ដ៏ទៃទៀត | កម្ពុជា ខេត្ត ស្រុក ឃុំ | ប្រចាំឆ្នាំ |

## ២៥. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការងារ | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា ខេត្ត | ប្រចាំ ឆ្នាំ |
| ស្ថិតិការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ | ២០២២ | ដ៏ទៃទៀត | ដ៏ទៃទៀត | កម្ពុជា ខេត្តដ៏ទៃទៀត | ប្រចាំ ឆ្នាំ ដ៏ទៃទៀត |
| ស្ថិតិបេឡាជាតិរបបសន្តិសុខសង្គម | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា ខេត្ត | ប្រចាំឆ្នាំ |
| ស្ថិតិបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់បុគ្គលិកដែលស្ថិតនៅក្នុងវិស័យសាធារណៈប្រចាំឆ្នាំ | - | - | - | - | - |

## ២៦. ក្រសួងមុខងារសាធារណៈ

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិមន្ត្រីរាជការស៊ីវិលនិងសេវាសាធារណៈ | - | - | - | - | - |

## ២៧. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិក្រុមហ៊ុនអាកាសចរណ៍ | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិអាកាសយានដ្ឋាន | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិអ្នកផ្តល់សេវានាំផ្លូវអាកាស | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |
| ស្ថិតិអាកាសយានស៊ីវិលដែលចុះបញ្ជី | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំឆ្នាំ |

## ២៨. ធនាគារជាតិនៃកម្ពុជា

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិប្រព័ន្ធទូទាត់ | ២០២២ | កំណត់ត្រារដ្ឋបាល និងដ៏ទៃទៀត | ដ៏ទៃទៀត | កម្ពុជា | ប្រចាំត្រីមាស |
| ស្ថិតិវិស័យក្រៅប្រទេស | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំត្រីមាស ឆ្នាំ |
| ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា | ប្រចាំខែ |
| ស្ថិតិគ្រឹះស្ថានធនាគារជាតិនិងហិរញ្ញវត្ថុ | ២០២២ | កំណត់ត្រារដ្ឋបាល | ដ៏ទៃទៀត | កម្ពុជា | ប្រចាំខែ |

## ២៩. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ស្ថិតិការប្រើប្រាស់ហិរញ្ញប្រទានសហប្រតិបត្តិការអភិវឌ្ឍន៍ | - | - | - | - | - |
| ស្ថិតិការអនុម័តគម្រោងវិនិយោគសាធារណៈរបស់ក្រសួងស្ថាប័ន | - | - | - | - | - |
| ស្ថិតិការអនុម័តគម្រោងវិនិយោគឯកជនរួមទាំងគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស | - | - | - | - | - |

## ៣០. ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

| ឈ្មោះស្ថិតិ | រយៈពេល | ប្រភពទិន្នន័យ | ឯកតាវាយការណ៍ | កម្រិតតំបន់ | ពេលចេញផ្សាយ |
|---|---|---|---|---|---|
| ព័ត៌មានពីមុខរបរក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មាន | ២០២២ | អង្កេត | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |
| ស្ថិតិអ្នកស្វែងរកការងារធ្វើ និងតម្រូវការការជ្រើសរើសកម្លាំងពលកម្ម | ២០២២ | កំណត់ត្រារដ្ឋបាល | - | កម្ពុជា | ប្រចាំខែ ឆ្នាំ |

**ឧបសម្ព័ន្ធ៣ ៖**



# ច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិ

# ច្បាប់

# ស្ដីពីស្ថិតិ

នស/រកម/១២១៥/ ០១៨

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីស្ថិតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពីស្ថិតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/១២

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងការងារទាំងឡាយ ដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ។

**មាត្រា ២.–**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

-គាំទ្រសេចក្តីត្រូវការទិន្នន័យស្ថិតិរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ វាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដែលផ្តោតលើកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិ ក៏ដូចជាសេចក្តីត្រូវការសម្រាប់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិនិងអន្តរជាតិដ៏ទូលំទូលាយ

-សម្រួលកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិឲ្យមានសមត្ថភាព និងប្រសិទ្ធភាព

-បង្កើនការយល់ដឹងជាសាធារណៈនូវសារៈសំខាន់នៃមុខងារ និងតួនាទីរបស់ស្ថិតិនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ

-លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍវិធីសាស្ត្រនិងបច្ចេកវិទ្យានៅក្នុងសកម្មភាពស្ថិតិ ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពស្ថិតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.–**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានន័យដូចខាងក្រោម ៖

១-**ស្ថិតិ** សំដៅដល់ទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យរដ្ឋបាល ។

២-**ប្រព័ន្ធស្ថិតិជាតិ** សំដៅដល់សមាហរណកម្មនៃស្ថិតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

៣-**ស្ថិតិគ្រឹះ** សំដៅដល់ស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ កម្មវិធី និងការវាយតម្លៃក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិ និងអន្តរជាតិ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤-**ស្ថិតិតាមវិស័យ** សំដៅដល់ស្ថិតិដែលប្រមូលដោយបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍ ។

៥-**ជំរឿន** សំដៅដល់ការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍ ។

៦-**អង្កេត** សំដៅដល់ការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារសហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍ ។

៧-**មន្ត្រីស្ថិតិ** សំដៅដល់មន្ត្រីរាជរដ្ឋាភិបាលដែលមានសិទ្ធិអំណាចក្នុងការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

៨-**អ្នកឆ្លើយ** សំដៅដល់បុគ្គល គ្រួសារ ក្រុមហ៊ុន សហគ្រាស អង្គភាពសេដ្ឋកិច្ច អាជីវកម្ម សេវាកម្ម ស្ថាប័នរាជរដ្ឋាភិបាលឬសង្គមស៊ីវិល ឬអង្គការផ្សេងទៀត ដែលត្រូវបានជ្រើសរើសក្នុងការជំរឿន និងអង្កេត ។

៩-**ទិន្នន័យ** សំដៅដល់ទិន្នន័យបរិមាណ និងជាទិន្នន័យគុណភាព ។

១០-**ទិន្នន័យបរិមាណ** សំដៅដល់ព័ត៌មានដែលមានរូបភាពជាតួលេខ ។

១១-**ទិន្នន័យគុណភាព** សំដៅដល់ព័ត៌មានដែលមានរូបភាពជាអត្ថបទ ។

១២-**ទិន្នន័យរដ្ឋបាល** សំដៅដល់ទិន្នន័យដែលប្រមូលចងក្រងតាមរយៈកំណត់ត្រាដោយបណ្តាក្រសួងស្ថាប័នសម្រាប់តម្រូវការប្រើប្រាស់របស់ខ្លួន ។

១៣-**ទិន្នន័យផ្តុំ** សំដៅដល់ទិន្នន័យដែលពាក់ព័ន្ធនឹងក្រុមបុគ្គល គ្រួសារសហគ្រាស ឬស្ថាប័នផ្សេងៗ ត្រូវបានប្រមូលផ្តុំក្នុងកម្រិតមួយដែលមិនអនុញ្ញាតឲ្យស្គាល់ទិន្នន័យបុគ្គល ។

១៤-**ទិន្នន័យស្ថិតិជាតិ** សំដៅដល់ទិន្នន័យដែលត្រូវបានផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិផ្សេងទៀត នៃប្រព័ន្ធស្ថិតិជាតិ ។

១៥-**ស្ថិតិផ្លូវការដែលបានចាត់តាំង** សំដៅដល់ស្ថិតិដែលបានផលិតដោយក្រសួងស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាលដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។

១៦-**គោលបំណងស្ថិតិ** សំដៅដល់គោលបំណងដែលទាក់ទងទៅនឹងការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ពការបញ្ចូលព័ត៌មានទិន្នន័យស្ថិតិតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយស្ថិតិផ្លូវការ ។

១៧-**ម៉េតាទិន្នន័យ** សំដៅដល់ការពិពណ៌នាអំពីទិន្នន័យ ពោលគឺការរៀបរាប់អំពីប្រភពដំណើរការចងក្រង វិធីសាស្ត្រចងក្រង ពេលវេលាផ្សព្វផ្សាយ ស្ថាប័ន និងអ្នកទទួលខុសត្រូវក្នុងការចងក្រង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ដើម្បីឲ្យអ្នកប្រើប្រាស់យល់ដឹងពីទិន្នន័យកាន់តែស៊ីជម្រៅ ។

១៨-**មីក្រូទិន្នន័យ** សំដៅដល់ទិន្នន័យកម្រិតបុគ្គលដែលប្រមូលបានពីការអង្កេត ជំរឿន ឬពីប្រភពរដ្ឋបាល ។

## ជំពូកទី ២
## គោលការណ៍

### មាត្រា ៥._

ការអភិវឌ្ឍស្ថិតិត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា ស្របតាមគោលការណ៍នៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ និងប្រព័ន្ធស្ថិតិរបស់សហគមន៍អាស៊ាន ។

## ជំពូកទី ៣
## ការប្រមូលទិន្នន័យស្ថិតិ

### មាត្រា ៦._

ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ ៖

ក-ការធ្វើជំរឿន ។

ខ-ការធ្វើអង្កេត ។

គ-ការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។

### មាត្រា ៧._

ជំរឿនដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ក ខាងលើនេះត្រូវដំណើរការយ៉ាងតិចមួយដងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

ជំរឿនមាន ៣ ប្រភេទ ៖

ក-ជំរឿនប្រជាជន ។

ខ-ជំរឿនកសិកម្ម ។

គ-ជំរឿនសេដ្ឋកិច្ច ។

ជំរឿនទាំងនេះត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៨.-**

រាជរដ្ឋាភិបាលត្រូវកំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទាំង ៣ ដោយអនុក្រឹត្យក្នុងរយៈពេល ១០ (ដប់) ឆ្នាំម្តង ។ កាលបរិច្ឆេទនេះអាចធ្វើការផ្លាស់ប្តូរបាន ក្នុងករណីចាំបាច់ ។

**មាត្រា ៩.-**

អង្កេតចន្លោះជំរឿនទាំងឡាយ អាចត្រូវបានដំណើរការ ក្នុងចន្លោះជំរឿនពីរសម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោល ដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវគួរទុកចិត្តបាន ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា ។

**មាត្រា ១០.-**

អង្កេតដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវដំណើរការតាមពេលកំណត់ ដើម្បីផលិតស្ថិតិជាតិជាគ្រឹះដ៏ត្រឹមត្រូវ គួរទុកចិត្តបាន និងជាពិសេសដើម្បីបម្រើឲ្យសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល ។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ចវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបង្កើតបញ្ជីពាណិជ្ជកម្ម ឬគ្រោងសំណាកគំរូសម្រាប់អង្កេតដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១១.-**

ស្ថិតិដែលផលិតចេញពីប្រភពទិន្នន័យរដ្ឋបាលដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ គ នៃច្បាប់នេះត្រូវចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាក្នុងឯកសារ តារាង និងកំណត់ត្រាផ្សេងៗទៀតដែលមានប្រភពពីរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។ ក្នុងគោលដៅចងក្រងស្ថិតិពីប្រភពរដ្ឋបាល វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវធ្វើសៀវភៅរាយឈ្មោះ និងទីតាំងរបស់ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែលត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១២.-**

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

-ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល

-ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ។

**មាត្រា ១៣.-**

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ត្រូវប្រមូលទិន្នន័យតាមផ្នែកដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមរយៈ ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-ការធ្វើអង្កេត

-ការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល ។

## ជំពូកទី ៤
## ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

**មាត្រា ១៤.-**

វិទ្យាស្ថានជាតិស្ថិតិ ស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន ។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

ក្នុងភារកិច្ចនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវ ៖

ក-ដំណើរការយន្តការសម្របសម្រួលសម្រាប់ធានាការគ្រប់គ្រងដែលមានសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិ ។

ខ-ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍស្ថិតិរួម និងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្នែកឯកជន ។

គ-ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិ ជាមួយអង្គការអន្តរជាតិ អង្គភាព ស្ថិតិជាតិនៃប្រទេសនានា និងផ្នែកឯកជននានាទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

ឃ-កំណត់ស្តង់ដាស្ថិតិជាតិដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនាទាននិយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បីចៀសវាងការភាន់ច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និងការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ ។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ។

សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង

ផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨.-**

បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលត្រូវផលិតស្ថិតិផ្លូវការក្នុងច្បាប់នេះ ត្រូវបង្កើតអង្គភាពស្ថិតិនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បម្រើឲ្យគោលដៅស្ថិតិ ហើយត្រូវផ្ញើទិន្នន័យស្ថិតិដែលផលិតបានមកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។

**មាត្រា ១៩.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវទទួលខុសត្រូវក្នុងការធានាថាស្ថិតិត្រូវបានផលិត អភិវឌ្ឍ និងផ្សព្វផ្សាយដោយឯករាជ្យ ប្រកបដោយវិជ្ជាជីវៈនិងទាន់ពេលវេលា ។

## ជំពូកទី ៥
## ប្រភពធនធានហិរញ្ញវត្ថុ

**មាត្រា ២០.-**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរៀបចំថវិកាចំណាយប្រចាំឆ្នាំសម្រាប់ដំណើរការផលិតនិងផ្សព្វផ្សាយទិន្នន័យស្ថិតិ ដោយដាក់សុំការសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សាស្ថិតិមុននឹងបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួងផែនការ ។

**មាត្រា ២១.-**

អង្គភាពស្ថិតិនៃបណ្តាក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល ត្រូវរៀបចំផែនការសកម្មភាពអំពីការងារស្ថិតិរបស់ខ្លួន ទៅតាមអាទិភាពនិងភាពចាំបាច់នៃតម្រូវការស្ថិតិ រួចត្រូវរៀបចំផែនការថវិកាចំណាយប្រចាំឆ្នាំបញ្ចូលទៅក្នុងគម្រោងថវិកាក្រសួងសាមី ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈជាធរមាន ដើម្បីទទួលបានថវិកាគាំទ្រគ្រប់គ្រាន់ សម្រាប់ដំណើរការការងារប្រចាំឆ្នាំរបស់អង្គភាពនិងធានាបាននូវនិរន្តរភាពស្ថិតិ ។

**មាត្រា ២២.-**

ធនធានហិរញ្ញវត្ថុនៃវិទ្យាស្ថានជាតិស្ថិតិបានមកពី ៖

ក-កញ្ចប់ថវិការបស់ក្រសួងផែនការ ។

ខ-ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ។

គ-អំណោយពីសប្បុរសជននានា ។

ឃ-ប្រភពធនធានស្របច្បាប់ផ្សេងៗ ។

## ជំពូកទី ៦
## ការបោះពុម្ព និងផ្សព្វផ្សាយ

### មាត្រា ២៣.-

ដើម្បីបម្រើឲ្យសំណូមពរស្ថិតិរបស់អ្នកប្រើប្រាស់ ៖

ក-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិនៃក្រសួងស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលត្រូវបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូនអ្នកប្រើប្រាស់ទាំងអស់ ។

ខ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវបោះពុម្ពព្រឹត្តិបត្រស្ថិតិប្រចាំឆ្នាំដែលគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗនៃលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ។

គ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរក្សាឃ្លាំងទិន្នន័យទាំងឡាយដែលមានទិន្នន័យផ្ទុំអាចឲ្យសាធារណជនទូទៅរកបានតាមប្រព័ន្ធអ៊ិនធឺណិត ។

### មាត្រា ២៤.-

រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង ដោយរាជរដ្ឋាភិបាល ។

### មាត្រា ២៥.-

ទិន្នន័យផ្ទុំដែលមានត្រូវតែជាទិន្នន័យសំខាន់ ត្រឹមត្រូវ គួរជឿទុកចិត្តបាន ទាន់ពេលវេលា ស៊ីចង្វាក់គ្នាអាចប្រៀបធៀបបានហើយងាយស្រួលរកបានដោយអ្នកប្រើប្រាស់ ។

### មាត្រា ២៦.-

គ្រប់ទិន្នន័យស្ថិតិត្រូវតែបង្ហាញក្នុងទម្រង់ច្បាស់លាស់ ងាយយល់ ផ្សព្វផ្សាយតាមរបៀបសមស្របទាន់ពេល ងាយស្រួលរកយកមកប្រើប្រាស់បាន ដោយផ្អែកលើគោលការណ៍មិនលំអៀងជាមួយនឹងការគាំទ្រម៉េតាទិន្នន័យ និងការណែនាំ ។

ប្រតិទិនផ្សព្វផ្សាយនូវសូចនាករសំខាន់ៗត្រូវធ្វើជាសាធារណៈ។

### មាត្រា ២៧.-

ភាពទទួលបានមីក្រូទិន្នន័យត្រូវអនុញ្ញាតឲ្យផ្តល់សម្រាប់តែគោលបំណងស្រាវជ្រាវ ក្រោមលក្ខខណ្ឌដោយមិនឲ្យដឹងពីអត្តសញ្ញាណនៃព័ត៌មានបុគ្គល ក្រុមហ៊ុន សហគ្រាស និងស្ថាប័ន ។

ភាពទទួលបានមីក្រូទិន្នន័យ សម្រាប់តម្រូវការប្រើប្រាស់ក្នុងករណីពិសេស ត្រូវកំណត់តាមវិធានបែបបទដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

### មាត្រា ២៨.-

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិត្រូវបានប្រគល់សិទ្ធិក្នុងការធ្វើអត្ថាធិប្បាយ ពន្យល់កែតម្រូវលើ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ការបកស្រាយមិនត្រឹមត្រូវ និងការប្រើប្រាស់ស្ថិតិខុស ទោះជាជននោះ ឬស្ថាប័ននោះជាម្ចាស់ដើមនៃស្ថិតិនោះក៏ដោយ ។

## ជំពូកទី ៧
## សិទ្ធិ និងភារកិច្ច

**មាត្រា ២៩.-**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិ តាមបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឲ្យដំណើរការសកម្មភាពស្ថិតិនានា ដើម្បីទទួលបាននូវព័ត៌មានស្ថិតិពីអ្នកឆ្លើយ សម្រាប់ផលិតស្ថិតិផ្លូវការ ដោយយោងតាមមាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ៣០.-**

មន្ត្រីរាជការ បុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយអង្គការទាំងនោះនៅពេលបម្រើការងារ ឬបំពេញភារកិច្ចក្រោមច្បាប់នេះ ត្រូវជានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយ ដែលបានមកពីអ្នកឆ្លើយ ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ ។

**មាត្រា ៣១.-**

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលមានសិទ្ធិចេញចូលក្នុងទីកន្លែងដោយមានវត្តមានអ្នកកាន់កាប់ទីកន្លែងក្នុងគោលដៅប្រមូលទិន្នន័យស្ថិតិ ។

ទីកន្លែងរួមមាន ផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅជាច់ដោយឡែក និងទីកន្លែងផ្សេងទៀត ។

**មាត្រា ៣២.-**

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន និងអត្តសញ្ញាណបណ្ណផ្លូវការជូនអ្នកឆ្លើយ ហើយត្រូវប្រកាន់អាកប្បកិរិយាសុភាពរាបសា និងវិជ្ជាជីវៈ ក្នុងការសាកសួរព័ត៌មានឲ្យបានសមស្របទៅតាមទំនៀមទម្លាប់មូលដ្ឋាន និងសណ្តាប់ធ្នាប់សាធារណៈ ។

មុខសញ្ញាទីកន្លែង ពេលវេលាចេញចូលទីកន្លែង ត្រូវតែសមស្របទៅនឹងបេសកកម្មដែលបានកំណត់ ។

**មាត្រា ៣៣.-**

អ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលាជូនមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការនិងបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤.-**

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ មាត្រា ៣១ ឬមាត្រា ៣២ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣៥.-**

បុគ្គលឬមេគ្រួសារដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយវិទ្យាស្ថានជាតិស្ថិតិ ។

ក្នុងករណីដែលបានទទួលរងនូវការព្រមានដូចមានចែងក្នុងកថាខណ្ឌខាងលើហើយ ហើយនៅតែប្រព្រឹត្តល្មើសម្តងទៀតត្រូវពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ៥០ ០០០ (ប្រាំម៉ឺន) រៀល ។

និយោជក ឬអ្នកទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬសហគ្រាស ឬអង្គការផ្សេងទៀតដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០( ដប់លាន) រៀល ។

**មាត្រា ៣៦.-**

បុគ្គលរារាំងដោយចេតនានូវដំណើរការប្រមូលទិន្នន័យស្ថិតិ ដោយមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឬមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ១០០ ០០០ (មួយសែន) រៀល ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

# ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧.-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវនៅមានអានុភាពអនុវត្តតទៅទៀតរហូតមានអត្ថបទថ្មីមកកែប្រែឬលុបចោល លើកលែងតែបទប្បញ្ញត្តិ ដែលផ្ទុយនឹងស្មារតីនៃច្បាប់នេះ ។

# ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

ច្បាប់ស្តីពីស្ថិតិដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ ____ ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧. ១៥១៤. ១១៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ហត្ថលេខា**

**ឆាយ ថន**

លេខ:១១២០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ____ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

១២/១២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើត ក្រសួងផែនការ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីកាតព្វកិច្ចធ្វើស្ថិតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៦

## ស ម្រេ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅគ្រប់គ្រងរាល់ការងាររៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ កាតព្វកិច្ចស្ថិតិ និងការងារទាំងឡាយដែលពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

វាក្យស័ព្ទសំខាន់ទាំងឡាយក្នុងអនុក្រឹត្យនេះ មានន័យដូចខាងក្រោម៖

- ស្ថិតិផ្លូវការដែលបានចាត់តាំង សំដៅដល់ស្ថិតិដែលបានផលិតដោយក្រសួង ស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ ក្នុងការរៀបចំវាយតម្លៃ គោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មាន របស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវ ក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។
- មន្ត្រីស្ថិតិដែលបានចាត់តាំង សំដៅដល់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានប្រគល់សិទ្ធិសម្រាប់អនុវត្តសកម្មភាពស្ថិតិ តាមគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។
- អង្គភាពស្ថិតិដែលបានចាត់តាំង សំដៅដល់អង្គភាពស្ថិតិកណ្តាលនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលបានកំណត់ ដោយរាជរដ្ឋាភិបាល ឱ្យទទួលខុសត្រូវក្នុងការផលិតស្ថិតិផ្លូវការ ដែលបានចាត់តាំង ស្របតាម មាត្រា ១១ និង ១២ នៃច្បាប់ស្តីពីស្ថិតិ ។
- អគ្គនាយក សំដៅដល់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ។
- ទម្រង់ ឬកម្រងសំណួរ សំដៅដល់ឧបករណ៍មួយសម្រាប់ប្រមូលទិន្នន័យ ដែលរៀបចំដោយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត ។
- ប្រពន្ធ័ស្ថិតិជាតិ សំដៅដល់សមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និង

២

អង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

-មន្ត្រី សំដៅដល់មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ឬជាមន្ត្រីស្ថិតិដែលបានចាត់តាំង ដោយអនុលោមទៅតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ដើម្បីជួយក្នុងការអនុវត្តនូវមុខងារ របស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិរាជរដ្ឋាភិបាលដទៃទៀត ។

-ទីបរិវេណ សំដៅដល់ទីកន្លែង ដែលមិនមែនជាលំនៅដ្ឋាន ឬជាផ្នែកមួយនៃទីណាមួយក្នុងបរិវេណដែលត្រូវបានកាន់កាប់ដោយឡែក ឬប្រើប្រាស់សម្រាប់គោលបំណងនៃការរស់នៅ ឬស្នាក់នៅរបស់មនុស្ស ។

-គោលបំណងស្ថិតិ សំដៅដល់គោលបំណងដែលទាក់ទងទៅនឹងការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព ការបញ្ចូលព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច និងការផ្សព្វផ្សាយស្ថិតិផ្លូវការ ។

-កាតព្វកិច្ចស្ថិតិ សំដៅដល់ភារកិច្ច ដែលអ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មាន ស្មោះត្រង់ត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា តាមគ្រប់សំណួរនៃការ ប្រមូល ទិន្នន័យ យោងតាមមាត្រា ១១ និង ១២ នៃច្បាប់ស្តីពីស្ថិតិ ។

## ជំពូកទី២
## ការរៀបចំ និងកិច្ចដំណើរការស្ថិតិ

### មាត្រា៣.-

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់ ។

វិទ្យាស្ថានជាតិស្ថិតិ មាននាយកដ្ឋានមួយចំនួន សម្រាប់ទទួលខុសត្រូវលើសកម្មភាពស្ថិតិជំនាញ និងការគាំទ្រសកម្មភាពទាំងនោះ ។

វិទ្យាស្ថានជាតិស្ថិតិ មានអង្គភាពស្ថិតិនៅខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់ ។

### មាត្រា៤.-

ប្រព័ន្ធស្ថិតិជាតិ ត្រូវបានបង្កើតឡើងជាប្រព័ន្ធស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

ប្រព័ន្ធស្ថិតិជាតិ មានវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត និងមន្ត្រីដែលបម្រើការងារនៅតាមអង្គភាពស្ថិតិទាំងនោះ ។

អង្គភាពស្ថិតិនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការជាក់ស្តែង ។

**មាត្រា៥.-**

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវដូចតទៅ៖

ក.ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

ខ.ស្រាវជ្រាវ ចងក្រងវិធីសាស្ត្រផ្សេងៗ អភិវឌ្ឍម៉ូដែល និងបច្ចេកទេសស្ថិតិ ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ ។

គ.ធានាការសម្របសម្រួល ប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព ផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់ភារកិច្ចគ្នា ក្នុងការប្រមូលព័ត៌មានសម្រាប់គោលបំណងស្ថិតិផ្លូវការដោយ អង្គភាពស្ថិតិដែលបានចាត់តាំង
- ទទួលបាននូវភាពត្រូវគ្នា និងរួមបញ្ចូលគ្នារវាងស្ថិតិផ្លូវការទាំងឡាយ ដែលចងក្រងដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ធ្វើឱ្យមានប្រសិទ្ធភាពដល់កិច្ចអភិវឌ្ឍន៍ ការរៀបចំជាឯកសារ និងការផ្សព្វផ្សាយ អំពីទស្សនៈ ប្រភព និងវិធីសាស្ត្រស្ថិតិ
- អនុវត្តគោលនយោបាយស្ថិតិ ដែលមានរួមបញ្ចូលនូវគោលនយោបាយទាក់ទងនឹង ការផ្សព្វផ្សាយស្ថិតិផ្លូវការ និងប្រតិទិនប្រកាសផ្សាយជាមុន នូវការផ្សព្វផ្សាយស្ថិតិផ្លូវការ
- បង្កើនលទ្ធភាពប្រើប្រាស់ជាអតិបរមានូវព័ត៌មាន និងមធ្យោបាយនៃការប្រមូល និងផ្សព្វផ្សាយព័ត៌មាន ដែលមាននៅតាមអង្គភាពស្ថិតិដែលបានចាត់តាំង ។

ឃ.រៀបចំគោលនយោបាយ និងបទដ្ឋានស្ថិតិសម្រាប់ការអនុវត្តឯកភាពគ្នា របស់អង្គភាពស្ថិតិដែលបានចាត់តាំង ។

ង.ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំង ទាក់ទងនឹងស្ថិតិផ្លូវការ ។

ច.ទំនាក់ទំនងជាមួយបណ្ដាប្រទេសនានា និងអង្គការអន្តរជាតិនានា ដែលទាក់ទងនឹងការងារស្ថិតិ ។

វិទ្យាស្ថានជាតិស្ថិតិ ត្រូវសហការជាមួយអង្គភាពស្ថិតិផ្លូវការ ដែលបានចាត់តាំងរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិ រួមទាំងស្ថិតិដែលទទួលបានពីកំណត់ត្រារដ្ឋបាល ក្នុងគោលបំណងសម្របសម្រួលសកម្មភាពស្ថិតិ និងធានាការប្រតិបត្តិបទដ្ឋានស្ថិតិ ។

## មាត្រា៦.-

អង្គភាពស្ថិតិដែលបានចាត់តាំង ជាអង្គភាពស្ថិតិកណ្ដាលរបស់ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវ ដូចតទៅ៖

ក.ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

ខ.បញ្ជូនស្ថិតិដែលបានផលិត និងផ្ដល់ឯកសារ វិធីសាស្ត្រដែលទាក់ទងដល់វិទ្យាស្ថានជាតិស្ថិតិជាទម្រង់អេឡិចត្រូនិច និងឯកសារជាក្រដាស ។

គ.សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគបោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់គ្នា ក្នុងសកម្មភាពស្ថិតិ និងស្ថិតិផ្លូវការ
- បន្ថយមកត្រឹមកម្រិតអប្បបរមានូវបន្ទុកអ្នកឆ្លើយ
- ទទួលបាននូវការឯកភាពគ្នា និងការរួមបញ្ចូលគ្នា រវាងស្ថិតិផ្លូវការទាំងឡាយ
- អនុវត្តគោលនយោបាយ និងបទដ្ឋានស្ថិតិ ដែលប្រកាសឱ្យប្រើដោយវិទ្យាស្ថានជាតិស្ថិតិ ។

## មាត្រា៧.-

អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ អគ្គនាយកត្រូវបំពេញតួនាទី ភារកិច្ច តាមបទប្បញ្ញត្តិ នៃច្បាប់ស្ដីពីស្ថិតិ និងអនុក្រឹត្យនេះ ហើយមិនត្រូវបំពេញការងារផ្សេងលើកលែងតែមាន ការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងផែនការ ។

អគ្គនាយកត្រូវដឹកនាំវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ ។

អគ្គនាយកត្រូវដឹកនាំ ត្រួតពិនិត្យការរៀបចំ និងកិច្ចដំណើរការរបស់ វិទ្យាស្ថានជាតិស្ថិតិ

ប្រព័ន្ធស្ថិតិជាតិ ហើយនិងមានមុខងារ សិទ្ធិអំណាច និងភារកិច្ចដទៃទៀតៈ

ក. ផ្តល់យោបល់ អំពីការងារស្ថិតិ ។

ខ. សម្រេចអំពីរបៀបប្រមូល កែច្នៃ ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យទាំងឡាយសម្រាប់គោលដៅស្ថិតិ ។

គ. ផ្តល់ព័ត៌មានទាក់ទងនឹងបទប្បញ្ញត្តិ គោលនយោបាយស្ថិតិ ស្ថិតិផ្លូវការ និងការងារស្ថិតិដទៃទៀត ។

ឃ.តំណាងឱ្យប្រពន្ធ័ស្ថិតិជាតិ ក្នុងវេទិកាអន្តរជាតិដែលទាក់ទងទៅនឹងការងារស្ថិតិ ។

## មាត្រា៨.-

អគ្គនាយកត្រូវចាត់តាំងមន្ត្រី ជាលាយលក្ខណ៍អក្សរទៅតាមប្រភេទ និងកម្រិតការងារ ដើម្បីឱ្យទៅជាមន្ត្រីស្ថិតិដែលបានចាត់តាំង សម្រាប់តែគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

ប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវពិគ្រោះយោបល់ជាមួយអគ្គនាយក មុននឹងដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាត់តាំងមន្ត្រី ជាលាយលក្ខណ៍អក្សរទៅតាមប្រភេទ និងកម្រិតការងារ ឱ្យទៅជាមន្ត្រីស្ថិតិដែលបានចាត់តាំង សម្រាប់តែគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

## មាត្រា៩.-

អគ្គនាយកអាចចុះហត្ថលេខាផ្ទេរប្រតិភូកម្មដល់មន្ត្រីណាម្នាក់ នូវសិទ្ធិអំណាច សម្រាប់ចុះបំពេញការងារប្រមូលទិន្នន័យ ឬសម្របសម្រួលដើម្បីប្រមូលទិន្នន័យ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

សិទ្ធិអំណាចរបស់មន្ត្រី ដែលត្រូវបានទទួលប្រតិភូកម្មនៅពេលអនុវត្ត តាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ នេះត្រូវបានចាត់ទុកថាអនុវត្តដោយអគ្គនាយក ។

## មាត្រា១០.-

អគ្គនាយកត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលទាក់ទងនឹងសកម្មភាព នៃកិច្ចប្រតិបត្តិការស្ថិតិ ហើយនិងការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិផ្លូវការ របស់ប្រព័ន្ធស្ថិតិជាតិសម្រាប់ឆ្នាំកន្លងមក ហើយផ្ញើជូនរដ្ឋមន្ត្រីក្រសួងផែនការ ។

រដ្ឋមន្ត្រី ក្រសួងផែនការ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនគណៈរដ្ឋមន្ត្រី ។

**មាត្រា១១.-**

មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ រួមមានបុគ្គលិកអចិន្ត្រៃយ៍ ដែលជាមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ហើយបំពេញមុខងារ ដូចមានចែងក្នុងមាត្រា ១១ និង ១៩ នៃច្បាប់ស្តីពីស្ថិតិ ។

អគ្គនាយក អាចប្រើប្រាស់បុគ្គលិកបន្ថែមដែលមិនមែនជាបុគ្គលិកអចិន្ត្រៃយ៍ នៅពេល៖

ក. ធ្វើជំរឿន និងអង្កេត ។

ខ. ប្រមូលស្ថិតិផ្សេងៗ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

គ. ផ្តល់នូវប្រឹក្សាបច្ចេកទេស និងការគាំទ្រ ។

កិច្ចសន្យាអំពីរយៈពេល និងល័ក្ខខ័ណ្ឌនៃការងារ របស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ ត្រូវកំណត់ដោយអគ្គនាយក ។

**មាត្រា១២.-**

មន្ត្រីរបស់អង្គភាពស្ថិតិដែលបានចាត់តាំងមាន បុគ្គលិកអចិន្ត្រៃយ៍ ដែលជាមន្ត្រីរបស់អង្គភាពនោះ ហើយបំពេញមុខងារ ដែលមានចែងក្នុងមាត្រា ១២ និង ១៩ (ក) នៃច្បាប់ស្តីពីស្ថិតិ ។

អង្គភាពស្ថិតិដែលបានចាត់តាំង អាចប្រើប្រាស់បុគ្គលិកបន្ថែមដែលមិនមែនជាបុគ្គលិកអចិន្ត្រៃយ៍ ដោយពិគ្រោះយោបល់ជាមួយ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៅពេល៖

ក. ធ្វើអង្កេត ។

ខ. ប្រមូលស្ថិតិផ្សេងៗ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

គ. ផ្តល់នូវប្រឹក្សាបច្ចេកទេស និងការគាំទ្រ ។

កិច្ចសន្យា អំពីរយៈពេល និងល័ក្ខខ័ណ្ឌនៃការងារ របស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ ត្រូវកំណត់ដោយក្រសួង ឬស្ថាប័ន ដោយពិគ្រោះយោបល់ជាមួយអគ្គនាយក ។

## ជំពូកទី៣

## ក្រុមប្រឹក្សាស្ថិតិ

**មាត្រា១៣.-**

ក្រុមប្រឹក្សាស្ថិតិ ដែលបានបង្កើតដោយអនុលោមតាមមាត្រា ១៥ នៃច្បាប់ស្តីពីស្ថិតិ មាន

សមាសភាព ដូចតទៅ៖

| | |
|---|---|
| រដ្ឋមន្ត្រី ក្រសួងផែនការ | ជាប្រធាន |
| រដ្ឋលេខាធិការ ក្រសួងផែនការ ទទួលបន្ទុកស្ថិតិ | ជាអនុប្រធាន |
| រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង ពាណិជ្ជកម្ម | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង អប់រំ យុវជន និងកីឡា | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង សុខាភិបាល | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង សាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង ទេសចរណ៍ | ជាសមាជិក |
| រដ្ឋលេខាធិការ ក្រសួង កិច្ចការនារី | ជាសមាជិក |
| ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា | ជាសមាជិក |
| តំណាង មជ្ឈដ្ឋានឧត្តមសិក្សាមួយនាក់ដែល ជ្រើសរើសដោយរដ្ឋមន្ត្រី ក្រសួងផែនការ | ជាសមាជិក |
| អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ | ជាសមាជិកអចិន្ត្រៃយ៍ ។ |

ប្រធានក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍អាជីវកម្ម ចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់ ។

## មាត្រា១៥.-

ក្រុមប្រឹក្សាស្ថិតិ ត្រូវប្រជុំការងារ យ៉ាងតិចពីរដង ក្នុងមួយឆ្នាំ។ សមាជិកក្រុមប្រឹក្សាស្ថិតិ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្តាល នៃសមាជិកទាំងអស់សម្រាប់បើកអង្គប្រជុំ ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ត្រូវមានសមាជិកចូលរួមយ៉ាងតិចមួយភាគបី នៃសមាជិកទាំងអស់ ។

សេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សាស្ថិតិ ត្រូវអនុម័តដោយយកមតិភាគច្រើន របស់សមាជិកចូលរួមទាំងអស់ ។

រដ្ឋមន្ត្រីក្រសួងផែនការ ដែលជាប្រធានក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិអនុម័តសម្រេច ក្នុងករណីដែលមានមតិស្មើគ្នា ។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវមានកំណត់ហេតុ ។

## មាត្រា១៥.-

ក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងផែនការ ។ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ត្រូវផ្តល់លេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្ថិតិ ។

## មាត្រា១៦.-

ក្រុមប្រឹក្សាស្ថិតិ មានតួនាទីផ្តល់យោបល់ជូន រដ្ឋមន្ត្រី ក្រសួងផែនការ ដែលទាក់ទងទៅនឹង៖

- ការកំណត់គោលនយោបាយស្ថិតិផ្លូវការ
- តម្រូវការស្ថិតិផ្លូវការ និងការផ្តល់អាទិភាពដល់គម្រោងការងារស្ថិតិ ដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង
- ការធ្វើឱ្យប្រសើរឡើង ការពង្រីក និងការសម្របសម្រួលនូវប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង សម្រាប់គោលបំណងសាធារណៈ
- ការធ្វើវិសោធនកម្មណាមួយទៅលើច្បាប់ស្តីពីស្ថិតិ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធការងារស្ថិតិ
- កម្មវិធីការងារស្ថិតិអាទិភាពរយៈពេល ១ ឆ្នាំ រយៈពេលមធ្យម រយៈពេលវែង របស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដែលទាក់ទងក្នុងការផលិតស្ថិតិផ្លូវការ
- ផែនការមេស្ថិតិ
- ការកំណត់កាលបរិច្ឆេទ នៃការធ្វើជំរឿនប្រជារាស្ត្រ កសិកម្ម និងសហគ្រាស
- ការងារផ្សេងៗ ដែលទាក់ទងជាទូទៅនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

-ការស្វែងរកជំនួយ និងការគាំទ្រ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលត្រូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីធ្វើជំរឿន អង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលបំណងសាធារណៈ ។

## ជំពូកទី៤
## គណៈកម្មាធិការសម្របសម្រួលស្ថិតិ

**មាត្រា១៧.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ដោយអនុលោមតាមមាត្រា ១៦ នៃច្បាប់ស្តីពីស្ថិតិ មាន សមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ | ជាប្រធាន |
| អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | ជាអនុប្រធាន |
| ប្រធាន នាយកដ្ឋានស្ថិតិទូទៅ នៃវិទ្យាស្ថានជាតិស្ថិតិ | ជាលេខាធិការ |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង មហាផ្ទៃ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការពារជាតិ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង អភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ពាណិជ្ជកម្ម | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង បរិស្ថាន | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង អប់រំ យុវជន និងកីឡា | ជាសមាជិក |
| ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួងធម្មការ និងសាសនា | ជាសមាជិក |

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង កសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ធនធានទឹក និងឧតុនិយម ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ព័ត៌មាន ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង យុត្តិធម៌ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ប្រៃសណីយ៍
និងទូរគមនាគមន៍ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សុខាភិបាល ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ទេសចរណ៍ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង កិច្ចការនារី ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ធនាគារជាតិ នៃកម្ពុជា ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ទីចាត់ការគយ និងរដ្ឋាករ ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ នាយកដ្ឋានពន្ធដារ ជាសមាជិក ។

**មាត្រា១៨.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវប្រជុំការងារយ៉ាងតិចរាល់ ៣ ខែម្តង ។ សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្ដាល នៃសមាជិកទាំងអស់ សម្រាប់បើកអង្គប្រជុំ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ មិនគិតចំនួនសមាជិកចូលរួមឡើយ។

សេចក្ដីសម្រេចរបស់ អង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវអនុម័តដោយយកមតិភាគច្រើនរបស់សមាជិកចូលរួមទាំងអស់ ។

អគ្គនាយក ដែលជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិអនុម័តសម្រេចក្នុងករណីដែលមានមតិស្មើគ្នា ។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវមានកំណត់ហេតុ ។

## មាត្រា១៩.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិប្រើប្រាស់ត្រាវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ។

នាយកដ្ឋានស្ថិតិទូទៅ នៃវិទ្យាស្ថានជាតិស្ថិតិ ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ។

## មាត្រា២០.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការងារពាក់ព័ន្ធទៅនឹង៖

-ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និង ស្ថិតិផ្លូវការ

-ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពលើសកម្មភាព និងការអភិវឌ្ឍស្ថិតិ រវាងអង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវ ក្នុងការផលិតនិងការផ្សព្វផ្សាយស្ថិតិផ្លូវការ

-ការធ្វើឱ្យប្រសើរឡើង និងការពង្រីកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលផ្ដល់សម្រាប់គោលដៅសាធារណៈ

-ការលើកអាទិភាព នៃកម្មវិធីការងារ ប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែងដែលគួរ

ត្រូវបានជ្រើសរើស ទាក់ទងនឹងទិដ្ឋភាពសំខាន់ៗ នៃការផ្តល់ស្ថិតិផ្លូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង

-ការរៀបចំ និងធ្វើបច្ចុប្បន្នកម្ម ផែនការមេស្ថិតិ

-ការរៀបចំផែនការ ធ្វើជំរឿនប្រជារាស្ត្រ កសិកម្ម និងសហគ្រាស

-ការបង្កើតនូវបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសរុប បញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាព និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ

-កិច្ចព្រមព្រៀងសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល រវាងបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរទិន្នន័យ និងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឱ្យបានទៀងទាត់ និងគួរជឿទុកចិត្តបាន

-ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ សម្រាប់ស្ថិតិណាមួយ ឬការងារស្ថិតិផ្សេងទៀត ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

-ការប្រកាសឱ្យប្រើ និងការអនុវត្តនូវចំណាត់ថ្នាក់ និងបទដ្ឋានស្ថិតិ ដែលទាក់ទងនឹងស្ថិតិផ្លូវការ

-ការលើកផែនការថវិកា និងធនធានមនុស្ស សម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និងអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលដៅសាធារណៈ ។

## មាត្រា២១.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ ដើម្បីដោះស្រាយការងារបច្ចេកទេសស្ថិតិណាមួយ ដែលទាមទារការពិនិត្យ សិក្សា និងពិភាក្សាលម្អិត ។

គណៈកម្មាធិការសម្របសម្រួលស្ថិតិ នឹងកំណត់ល័ក្ខខ័ណ្ឌយោង ដែលមានចែងពីភារកិច្ច និងបែបបទធ្វើរបាយការណ៍ ស្តីពីលទ្ធផលរបស់ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗ ។

ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗ ត្រូវរៀបចំសមាសភាពដូចខាងក្រោម៖

- សមាជិក ១ រូប របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ប្រធាន
- ប្រធាន ឬអនុប្រធាននាយកដ្ឋាន ១ រូប នៃវិទ្យាស្ថានជាតិស្ថិតិ អនុប្រធាន
- សមាជិកដទៃទៀតមកពីបណ្តាក្រសួង ស្ថាប័ន ឬអង្គភាព

រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ រួមទាំងវិទ្យាស្ថានជាតិស្ថិតិ
ដែលមានចំនួនមិនលើសពី ៥ រូបទៅតាមការកំណត់របស់
គណៈកម្មាធិការសម្របសម្រួលស្ថិតិ សមាជិក ។

## ជំពូកទី៥
## សិទ្ធិ និងភារកិច្ច

**មាត្រា២២.-**

វិទ្យាស្ថានជាតិស្ថិតិ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងការងារស្ថិតិត្រូវប្រមូល៖

-ព័ត៌មានស្ថិតិជាចាំបាច់សម្រាប់គោលបំណង នៃការចងក្រង និងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង

-ព័ត៌មានស្ថិតិបន្ថែម ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលសម្រាប់គោលដៅធ្វើផែនការ និងគោលនយោបាយ

-ព័ត៌មានស្ថិតិពាក់ព័ន្ធទៅនឹងបញ្ហា ដែលបានកំណត់ជាលាយលក្ខណ៍អក្សរ ដោយរដ្ឋមន្ត្រីក្រសួងផែនការ ឱ្យប្រមូលព័ត៌មាន ។

អង្គភាពស្ថិតិដែលបានចាត់តាំង ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះត្រូវប្រមូលព័ត៌មានស្ថិតិជាចាំបាច់ សម្រាប់គោលបំណងនៃការចងក្រង និងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង ដែលអង្គភាពស្ថិតិនោះទទួលខុសត្រូវ ។

**មាត្រា២៣.-**

អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវចងក្រង និងវិភាគព័ត៌មានស្ថិតិដែលបានប្រមូល ក្រោមសិទ្ធិអំណាចនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ហើយត្រូវបោះពុម្ព និងផ្សព្វផ្សាយនូវលទ្ធផលដែលបានចងក្រង និងវិភាគ ឬសម្រង់សង្ខេប នៃលទ្ធផលទាំងនោះ ។ លទ្ធផល ឬសម្រង់សង្ខេបនោះ នឹងមិនត្រូវបានបោះពុម្ព ឬផ្សព្វផ្សាយតាមរបៀប ដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពណាមួយឡើយ ។

## មាត្រា២៤.-

មន្ត្រីស្ថិតិទាំងឡាយ ដែលត្រូវបានប្រគល់សិទ្ធិ ឱ្យចុះប្រតិបត្តិការការងារស្ថិតិ យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធ ត្រូវចុះកិច្ចសន្យាដោយមានសាក្សីទទួលដឹងឮ ដើម្បីធានា៖

- ភាពស្មោះត្រង់
- រក្សាការសម្ងាត់ នូវរាល់ព័ត៌មានបុគ្គលដែលទទួលបានពីអ្នកឆ្លើយ
- ព័ត៌មានដែលប្រមូលបានត្រូវប្រើប្រាស់សម្រាប់តែគោលដៅស្ថិតិប៉ុណ្ណោះ ។

## មាត្រា២៥.-

ក្នុងករណីពិសេស រដ្ឋមន្ត្រីក្រសួងផែនការអាចសម្រេចជាលាយលក្ខណ៍អក្សរ ផ្តល់ឱ្យនូវកម្រិតព័ត៌មានបុគ្គលណាមួយ តាមការស្នើសុំពីអត្តនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ជាលាយលក្ខណ៍អក្សរ ។

ការសម្រេចផ្តល់ឱ្យអាចពាក់ព័ន្ធទៅនឹង៖

ក. បុគ្គលដែលស្នើសុំព័ត៌មាន ។

ខ. តម្រូវការយល់ព្រមពីអ្នកឆ្លើយដែលបានផ្តល់ព័ត៌មាន ។

គ. ការបញ្ជាក់រយៈពេល និងល័ក្ខខ័ណ្ឌប្រើប្រាស់ព័ត៌មានដែលបានផ្តល់ឱ្យ ដូចជាមិនបញ្ចេញព័ត៌មានដល់បុគ្គលណាមួយទៀតឡើយ ។

ព័ត៌មានដែលមានចរិតបុគ្គល ឬផ្ទាល់ខ្លួនទាក់ទងនឹងអ្នកឆ្លើយ មិនត្រូវបានបញ្ចេញដោយរបៀបដែលអាចឱ្យសម្គាល់អត្តសញ្ញាណរបស់បុគ្គលនោះ ។

ព័ត៌មានអំពីលេខ នៃការចុះបញ្ជីអាជីវកម្ម ឈ្មោះ អាសយដ្ឋាន ទីតាំង ប្រភេទ នៃការចាត់តាំងផ្លូវច្បាប់ ផ្នែកផលិតកម្ម ចំនួនអ្នកធ្វើការ ឬកម្រិតថ្នាក់អថេរដទៃទៀត នៃអង្គភាពកសិកម្ម និងសហគ្រាស ហើយនិងអង្គភាពផ្សេងទៀត ដែលជាតម្រូវការរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីបង្កើតក្របខ័ណ្ឌជំរឿន និងអង្កេត សម្រាប់គោលបំណងនៃការដឹកនាំសកម្មភាពប្រមូលទិន្នន័យ និងចងក្រងស្ថិតិផ្លូវការៈថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន មិនតម្រូវឱ្យមានការយល់ព្រមពីអ្នកឆ្លើយឡើយ ។

## មាត្រា២៦.-

មន្ត្រីស្ថិតិ នៃក្រសួងផែនការ ឬមន្ត្រីស្ថិតិដែលបានចាត់តាំង យោងតាមមាត្រា ២៣ និងមាត្រា ២៤ នៃច្បាប់ស្តីពីស្ថិតិ ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន អត្តសញ្ញាណប័ណ្ណផ្លូវការ និងដោយមាន

ការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬអ្នកស្នាក់នៅ អាចចូលក្នុងលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅរួមមាន ផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅដោយឡែក និងទីកន្លែងផ្សេងៗទៀត តាមវេលាដ៏សមស្រប សម្រាប់គោលបំណង៖

ក. ផ្តល់កម្រងសំណួរ ឬទម្រង់ស្ថិតិ ឱ្យបុគ្គលបំពេញ ។

ខ. ប្រមូលកម្រងសំណួរ ឬទម្រង់ស្ថិតិ ដែលបុគ្គលបានបំពេញហើយ ។

គ. ធ្វើការសម្ភាសន៍ និងបំពេញការងារផ្សេងៗទៀត សម្រាប់គោលបំណងស្ថិតិ ។

**មាត្រា២៧.-**

ក.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

-រៀបចំកម្រងសំណួរ ឬទម្រង់ស្ថិតិទាក់ទងនឹងការប្រមូលព័ត៌មានស្ថិតិពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ

-អាចធ្វើលិខិតតម្រូវឱ្យបុគ្គលដែលមានជំនាញ និងការទទួលខុសត្រូវជាក់លាក់ ដើម្បីបំពេញកម្រងសំណួរ ឬទម្រង់ស្ថិតិ តាមការណែនាំសម្រាប់បំពេញ ។

ខ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាច៖

- ឱ្យបុគ្គលបំពេញ និងផ្តល់ព័ត៌មានស្ថិតិ តាមការណែនាំជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់

-មានវិធានការចាំបាច់ ដើម្បីជំរុញឱ្យបុគ្គលបំពេញកម្រងសំណួរ ឬទម្រង់ស្ថិតិឱ្យបានត្រឹមត្រូវសព្វគ្រប់ តាមការណែនាំ ។

គ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង អាចចេញលិខិតជូនដំណឹងដោយភ្ជាប់ជាមួយនឹងកម្រងសំណួរ ឬទម្រង់ស្ថិតិផ្ញើទៅបុគ្គលតាមរយៈប្រៃសណីយ៍ ឬមន្ត្រីស្ថិតិជាតំណាងជូនដល់ផ្ទាល់ដៃ ។ បុគ្គលដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ត្រូវបំពេញដោយទទួលខុសត្រូវ នូវចម្លើយឱ្យបានសព្វគ្រប់តាមការណែនាំ ហើយផ្ញើកម្រងសំណួរ ឬទម្រង់ស្ថិតិដែលបានបំពេញហើយនោះ មកអគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងរយៈពេលមិនឱ្យលើសពី ១៤ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ។

ឃ. លិខិតជូនដំណឹងរបស់អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិ ដែលមានចែងក្នុងមាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់ស្តីពីស្ថិតិ ។

**មាត្រា២៨.-**

ក.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាចឱ្យបុគ្គលឆ្លើយ នូវសំណួរណាមួយដែលចាំបាច់ ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

ខ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ដោយលិខិតជាលាយលក្ខណ៍អក្សរ ឬដោយខ្លួនផ្ទាល់ ឬដោយចាត់មន្ត្រីស្ថិតិជាតំណាង អាចណែនាំឱ្យបុគ្គលផ្តល់ចម្លើយនូវសំណួរណាមួយដែលចាំបាច់ក្នុងរយៈពេលមិនឱ្យលើសពី ១៤ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលសំណួរ ។

គ.សំណួររបស់អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ២៨ និងមាត្រា២៩ នៃច្បាប់ស្តីពីស្ថិតិ ។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**មាត្រា២៩.-**

បុគ្គលណា ដែលរំលោភបញ្ញត្តិ នៃមាត្រា២៥ មាត្រា២៧ និងមាត្រា២៨ នៃអនុក្រឹត្យនេះត្រូវមានទោសព្រហ្មទណ្ឌ តាមច្បាប់ជាធរមាន ។

**មាត្រា៣០.-**

បុគ្គលដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ដែលតម្រូវឱ្យបំពេញក្នុងរយៈពេលកំណត់ដូចមានចែងក្នុង មាត្រា ២៧ ចំណុច គ ឬមាត្រា ២៨ ចំណុច ខ នៃអនុក្រឹត្យនេះ នៅតែមានកាតព្វកិច្ចបំពេញការងារនេះឱ្យបានសម្រេច ជាស្ថាពរ ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងប្រធានស្ថាប័ន រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ២០០៧




**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧០ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ស្ថិតិផ្លូវការដែលបានចាត់តាំង

១២២២១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីកាតព្វកិច្ចធ្វើស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ឲ្យក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ប្រមូល ចងក្រងស្ថិតិផ្លូវការដែលបានចាត់តាំង ទៅតាមវិស័យរបស់ខ្លួន។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងបម្រើសំណូមពរព័ត៌មានស្ថិតិ របស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃលើគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្រប់គ្រងរាល់ស្ថិតិផ្លូវការដែលបានចាត់តាំង និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

- អង្គភាពស្ថិតិដែលបានចាត់តាំង សំដៅដល់អង្គភាពស្ថិតិកណ្តាលនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលឲ្យទទួលខុសត្រូវក្នុងការផលិតស្ថិតិផ្លូវការដែលបានចាត់តាំង ស្របតាមមាត្រា១១ និងមាត្រា១២ នៃច្បាប់ស្តីពីស្ថិតិ
- ទិន្នន័យរដ្ឋបាល សំដៅដល់ទិន្នន័យ ព័ត៌មាន ដែលប្រមូលបានមកពីផ្នែករដ្ឋបាលនៃក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល
- ស្ថិតិគ្រឹះ សំដៅដល់ស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ដែលជាស្ថិតិមានចរិត ទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ គោលនយោបាយ កម្មវិធី និងការវាយតម្លៃ ក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិ និងអន្តរជាតិ
- ស្ថិតិតាមវិស័យ សំដៅដល់ស្ថិតិដែលប្រមូលដោយបណ្តាក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល សម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍
- ជំរឿន សំដៅដល់ការប្រមូលព័ត៌មានស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាព ចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍

- អង្កេត សំដៅដល់ការប្រមូលព័ត៌មានស្ថិតិ តាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍
- មេតាទិន្នន័យ សំដៅដល់ការពិពណ៌នាអំពីទិន្នន័យ ពោលគឺការរៀបរាប់អំពីប្រភពដំណើរការចងក្រង វិធីសាស្ត្រចងក្រង ពេលវេលាផ្សព្វផ្សាយ ស្ថាប័ន និងអ្នកទទួលខុសត្រូវក្នុងការចងក្រងដើម្បីឲ្យអ្នកប្រើប្រាស់យល់ទិន្នន័យកាន់តែស៊ីជម្រៅ។

## ជំពូកទី២
## ស្ថិតិផ្លូវការដែលបានចាត់តាំង របស់វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា៥.-**

អនុលោមតាមស្មារតី នៃច្បាប់ស្តីពីស្ថិតិ គ្រប់ទិន្នន័យស្ថិតិទាំងអស់ដែលបានប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិត្រូវប្រកាសផ្សាយដល់សាធារណជននូវស្ថិតិគ្រឹះ និងស្ថិតិតាមវិស័យ ទោះផលិតដោយខ្លួនឯង ឬដោយសហការជាមួយអង្គភាពស្ថិតិផ្សេងទៀតរបស់រាជរដ្ឋាភិបាល ៖

១. ស្ថិតិជំរឿន
- ស្ថិតិជំរឿនប្រជាពលរដ្ឋ រៀងរាល់១០ (ដប់) ឆ្នាំម្តង
- ស្ថិតិជំរឿនកសិកម្ម រៀងរាល់១០ (ដប់) ឆ្នាំម្តង
- ស្ថិតិជំរឿនសហគ្រាស រៀងរាល់១០ (ដប់) ឆ្នាំម្តង។

២. ស្ថិតិអង្កេត
- ស្ថិតិអង្កេតប្រជាពលរដ្ឋ ចន្លោះជំរឿន រៀងរាល់១០ (ដប់) ឆ្នាំម្តង
- ស្ថិតិអង្កេតការអប់រំ និងអក្ខរភាព រៀងរាល់៥ (ប្រាំ) ឆ្នាំម្តង
- ស្ថិតិអង្កេតប្រជាសាស្ត្រ និងសុខភាព រៀងរាល់៥ (ប្រាំ) ឆ្នាំម្តង
- ស្ថិតិអង្កេតផ្នែកមិនរៀបរយ និងសេដ្ឋកិច្ចមិនបានពិនិត្យ រៀងរាល់៥ (ប្រាំ) ឆ្នាំម្តង
- ស្ថិតិអង្កេតឧក្រិដ្ឋកម្ម និងយុត្តិធម៌ រៀងរាល់៥ (ប្រាំ) ឆ្នាំម្តង
- ស្ថិតិអង្កេតសហគ្រាស ប្រចាំឆ្នាំ
- ស្ថិតិអង្កេតកម្លាំងពលកម្ម ប្រចាំឆ្នាំ
- ស្ថិតិអង្កេតហិរញ្ញវត្ថុវិស័យកសិកម្ម ប្រចាំឆ្នាំ
- ស្ថិតិអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ប្រចាំឆ្នាំ
- ស្ថិតិអង្កេតប្រជាសាស្ត្រ
- ស្ថិតិអង្កេតពលកម្មកុមារ។

៣. ស្ថិតិសេដ្ឋកិច្ច

- ស្ថិតិចុះបញ្ជីអាជីវកម្មសមាហរណកម្ម ប្រចាំឆ្នាំ
- ស្ថិតិគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ផលិតកម្មកសិកម្ម និងឧស្សាហកម្ម ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិ និងសន្ទស្សន៍ពាណិជ្ជកម្មលក់រាយ និងលក់ដុំ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ថ្លៃនីហរណ៍ និងអាហរណ៍ ប្រចាំខែ និងប្រចាំត្រីមាស
- គណនីវណបតាមផ្នែក
- សន្ទស្សន៍ចំណាយពលកម្ម និងថ្លៃឈ្នួល
- សន្ទស្សន៍ថ្លៃអ្នកផលិត និងសេវាកម្ម។

៤. ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ

- ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ
- គណនីវណបបរិស្ថាន និងធនធានធម្មជាតិ។

៥. ស្ថិតិសង្គមកិច្ច ប្រជាសាស្ត្រ

- ស្ថិតិប្រជាសាស្ត្រ និងប្រជារាស្ត្រ ប្រចាំឆ្នាំ
- ស្ថិតិចំណូល និងចំណាយគ្រួសារ ប្រចាំឆ្នាំ
- ស្ថិតិសង្គមកិច្ចផ្សេងទៀត ប្រចាំឆ្នាំ។

៦. កម្រងស្ថិតិ

- សៀវភៅស្ថិតិថ្នាក់ជាតិ រាជធានី ខេត្ត ប្រចាំឆ្នាំ
- សៀវភៅស្ថិតិថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រចាំឆ្នាំ
- សូចនាករសេដ្ឋកិច្ច និងបរិស្ថាន ប្រចាំឆ្នាំ និង
- សូចនាករសង្គមកិច្ច ប្រជាសាស្ត្រ ប្រចាំឆ្នាំ។

កាលបរិច្ឆេទដែលមានចែងក្នុងចំណុចទី១ ចំណុចទី២ ចំណុចទី៣ ចំណុចទី៤ ចំណុចទី៥ និងចំណុចទី៦នេះ អាចធ្វើការផ្លាស់ប្តូរបានក្នុងករណីចាំបាច់។

វិទ្យាស្ថានជាតិស្ថិតិ ត្រូវរៀបចំធ្វើអង្កេត និងប្រមូលចងក្រងស្ថិតិផ្លូវការដទៃទៀត តាមការចាំបាច់សម្រាប់តម្រូវការប្រើប្រាស់។

# ជំពូកទី៣
## ស្ថិតិផ្លូវការដែលបានចាត់តាំង របស់អង្គភាពស្ថិតិផ្សេងទៀត

**មាត្រា៦.–**

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវទទួលខុសត្រូវក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិដល់សាធារណជននូវស្ថិតិផ្លូវការដែលបានចាត់តាំងដូចតទៅ ៖

១. ទីស្តីការគណៈរដ្ឋមន្ត្រី
- ស្ថិតិវិភាគ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ និងប្រចាំឆ្នាំ។

២. ក្រសួង មហាផ្ទៃ
- ស្ថិតិប្រជាពលរដ្ឋ ប្រចាំឆ្នាំ
- ស្ថិតិអត្តសញ្ញាណប័ណ្ណ ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីអត្រានុកូលដ្ឋាន ប្រចាំឆ្នាំ
- ស្ថិតិបទល្មើសព្រហ្មទណ្ឌ និងការបង្ក្រាប ប្រចាំឆ្នាំ
- ស្ថិតិជនជាប់ឃុំ និងការអប់រំកែប្រែ ប្រចាំឆ្នាំ
- ស្ថិតិជនអន្តោប្រវេសន៍ ប្រចាំឆ្នាំ
- ស្ថិតិគណបក្សនយោបាយ ប្រចាំឆ្នាំ
- ស្ថិតិអង្គការមិនមែនរដ្ឋាភិបាល ប្រចាំឆ្នាំ
- ស្ថិតិការបង្កើតក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ និងភូមិថ្មី។

៣. ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិបំណុលសាធារណៈ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិការអនុវត្តថវិការាជរដ្ឋាភិបាល ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិពន្ធដារ ប្រចាំឆ្នាំ
- ស្ថិតិទំនិញដឹកជញ្ជូន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិចំណូលមិនមែនសារពើពន្ធ ប្រចាំឆ្នាំ
- ស្ថិតិពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

៤. ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ស្ថិតិថ្លៃទំនិញកសិកម្ម ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិអង្កេតផ្ទៃដី ទិន្នផល និងបរិមាណផលដំណាំ ប្រចាំរដូវ និងប្រចាំឆ្នាំ
- ស្ថិតិផលិតកម្ម និងបសុព្យាបាល ប្រចាំឆ្នាំ
- ស្ថិតិជលផល ប្រចាំឆ្នាំ
- ស្ថិតិព្រៃឈើ ប្រចាំឆ្នាំ
- ស្ថិតិផលិតកម្មដំណាំកៅស៊ូ ប្រចាំឆ្នាំ
- ស្ថិតិគ្រឿងយន្តកសិកម្ម ប្រចាំឆ្នាំ
- ស្ថិតិថ្នាំកសិកម្ម និងសម្ភារៈកសិកម្ម ប្រចាំឆ្នាំ។

៥. ក្រសួង អភិវឌ្ឍន៍ជនបទ

- ស្ថិតិផ្លូវជនបទ ប្រចាំឆ្នាំ
- ស្ថិតិទឹកស្អាតជនបទ ប្រចាំឆ្នាំ
- ស្ថិតិបង្គន់អនាម័យជនបទ ប្រចាំឆ្នាំ
- ស្ថិតិក្រុមជនជាតិភាគតិច ប្រចាំឆ្នាំ
- ស្ថិតិផ្នែកប្រព័ន្ធធារាសាស្ត្រខ្នាតតូច ប្រចាំឆ្នាំ
- ស្ថិតិផ្សារជនបទ ប្រចាំឆ្នាំ
- ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទ ប្រចាំឆ្នាំ
- ស្ថិតិការសាងសង់សាលារៀនជនបទ ប្រចាំឆ្នាំ។

៦. ក្រសួង ពាណិជ្ជកម្ម

- ស្ថិតិការចុះបញ្ជីពាណិជ្ជកម្ម ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីម៉ាក ប្រចាំឆ្នាំ។

៧. ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

- ស្ថិតិឧស្សាហកម្ម សិប្បកម្ម ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិថាមពល ប្រចាំឆ្នាំ
- ស្ថិតិធនធានរ៉ែ ប្រចាំឆ្នាំ
- ស្ថិតិទឹកស្អាត ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម។

៨. ក្រសួង អប់រំ យុវជន និងកីឡា

- ស្ថិតិមត្តេយ្យសិក្សា និងបឋមសិក្សា ប្រចាំឆ្នាំ

- ស្ថិតិមធ្យមសិក្សា បឋមភូមិ ទុតិយភូមិ ប្រចាំឆ្នាំ
- ស្ថិតិឧត្តមសិក្សា ប្រចាំឆ្នាំ
- ស្ថិតិអប់រំក្រៅប្រព័ន្ធ ប្រចាំឆ្នាំ។

៩. ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ស្ថិតិសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ស្ថិតិចំនួនអង្គការដៃគូដែលបានចុះអនុស្សរណៈលើការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិ សន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិ សន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ ប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិ សន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ប្រចាំឆ្នាំ។

១០. ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ស្ថិតិវិស័យសំណង់ ប្រចាំឆ្នាំ
- ស្ថិតិវិស័យដីធ្លី ប្រចាំឆ្នាំ
- ស្ថិតិវិស័យរៀបចំដែនដី នគរូបនីយកម្ម ប្រចាំឆ្នាំ។

១១. ក្រសួង បរិស្ថាន
- ស្ថិតិការវាយតម្លៃលើការប្រែប្រួលធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ប្រចាំឆ្នាំ
- ស្ថិតិការវាយតម្លៃលើការប្រែប្រួលអាកាសធាតុ ប្រចាំឆ្នាំ
- ស្ថិតិការវាយតម្លៃលើការបំពុលសំណល់រឹង សំណល់រាវ និងការបំពុលខ្យល់ ប្រចាំឆ្នាំ។

១២. ក្រសួង ធនធានទឹក និងឧតុនិយម
- ស្ថិតិឧតុនិយម ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិជលសាស្ត្រ ប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិប្រព័ន្ធស្រោចស្រព ប្រចាំឆ្នាំ។

១៣. ក្រសួង ព័ត៌មាន
- ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ប្រចាំឆ្នាំ។

១៤. ក្រសួង យុត្តិធម៌
- ស្ថិតិករណីវិវាទបទរដ្ឋប្បវេណីគ្រប់សាលាដំបូង ខេត្ត និងរាជធានី ប្រចាំឆ្នាំ
- ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌគ្រប់សាលាដំបូង ខេត្ត និងរាជធានី ប្រចាំឆ្នាំ

- ស្ថិតិករណីវិវាទបទល្មើសព្រហ្មទណ្ឌទៅលើអនីតិជន គ្រប់សាលាដំបូង ខេត្ត និងរាជធានី ប្រចាំឆ្នាំ
- ស្ថិតិកិច្ចការកសាងច្បាប់ ប្រចាំឆ្នាំ
- ស្ថិតិកិច្ចការផ្សព្វផ្សាយច្បាប់ ប្រចាំឆ្នាំ
- ស្ថិតិដោះស្រាយពាក្យបណ្តឹង ប្រចាំឆ្នាំ។

១៥. ក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- ស្ថិតិការចុះផ្សព្វផ្សាយច្បាប់ ប្រចាំឆ្នាំ
- ស្ថិតិការអនុម័តច្បាប់ ប្រចាំឆ្នាំ
- ស្ថិតិសមាជិករដ្ឋសភា ព្រឹទ្ធសភា ប្រចាំឆ្នាំ
- ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន ប្រចាំឆ្នាំ
- ស្ថិតិទទួល និងដោះស្រាយពាក្យបណ្តឹង ប្រចាំឆ្នាំ។

១៦. ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍
- ស្ថិតិសេវាកម្មប្រៃសណីយ៍ ប្រចាំឆ្នាំ
- ស្ថិតិអាជីវកម្មសេវាកម្មទូរគមនាគមន៍ ប្រចាំឆ្នាំ។

១៧. ក្រសួង សុខាភិបាល
- ស្ថិតិជំងឺឆ្លង ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិសុខាភិបាល ប្រចាំឆ្នាំ
- ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនមានច្បាប់ ប្រចាំឆ្នាំ។

១៨. ក្រសួង សាធារណការ និងដឹកជញ្ជូន
- ស្ថិតិការចុះបញ្ជីយានយន្ត និងនាវា ប្រចាំឆ្នាំ
- ស្ថិតិសាធារណការ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រចាំឆ្នាំ
- ស្ថិតិគ្រោះថ្នាក់ចរាចរតាមផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក ប្រចាំឆ្នាំ។

១៩.ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ
- ស្ថិតិការចុះបញ្ជីកម្មសិទ្ធិបញ្ញា និងសិទ្ធិអ្នកនិពន្ធ ប្រចាំឆ្នាំ
- ស្ថិតិបេតិកភណ្ឌវប្បធម៌រូបី ប្រចាំឆ្នាំ
- ស្ថិតិបេតិកភណ្ឌវប្បធម៌អរូបី ប្រចាំឆ្នាំ។

២០. ក្រសួង ទេសចរណ៍

- ស្ថិតិទេសចរជាតិ និងអន្តរជាតិ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិឧស្សាហកម្មទេសចរណ៍ ប្រចាំឆមាស និងប្រចាំឆ្នាំ
- ស្ថិតិកម្លាំងពលកម្មបម្រើឲ្យវិស័យទេសចរណ៍ ប្រចាំឆ្នាំ
- ស្ថិតិទេសចរវិលល្ងាច ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

២១. ក្រសួង ធម្មការ និងសាសនា

- ស្ថិតិសាសនា និងគ្រឹះស្ថានសាសនា ប្រចាំឆ្នាំ។

២២. ក្រសួង កិច្ចការនារី

- ស្ថិតិយេនឌ័រ ប្រចាំឆ្នាំ។

២៣. ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ស្ថិតិការងារ ប្រចាំឆ្នាំ
- ស្ថិតិការអប់រំ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិ របបសន្តិសុខសង្គម ប្រចាំឆ្នាំ។

២៤. រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល

- ស្ថិតិក្រុមហ៊ុនអាកាសចរណ៍ ប្រចាំឆ្នាំ
- ស្ថិតិអាកាសយានដ្ឋាន ប្រចាំឆ្នាំ
- ស្ថិតិអ្នកផ្តល់សេវានាំផ្លូវអាកាស ប្រចាំឆ្នាំ
- ស្ថិតិអាកាសយានស៊ីវិលដែលចុះបញ្ជី ប្រចាំឆ្នាំ។

២៥. រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

- ស្ថិតិមន្ត្រីរាជការស៊ីវិល និងសេវាកម្ម ប្រចាំឆ្នាំ។

២៦. ធនាគារជាតិនៃកម្ពុជា

- ស្ថិតិជញ្ជីងទូទាត់ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិបំណុលក្រៅប្រទេស ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុប្រចាំខែ
- ស្ថិតិពាណិជ្ជកម្មអន្តរជាតិ ផ្នែកទំនិញ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិពាណិជ្ជកម្មអន្តរជាតិ ផ្នែកសេវាកម្ម ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិស្ថានភាពវិនិយោគអន្តរជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

២៧. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- ស្ថិតិការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ អភិវឌ្ឍន៍ ប្រចាំឆ្នាំ
- ស្ថិតិការអនុម័តគម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន ប្រចាំឆមាស និងប្រចាំឆ្នាំ
- ស្ថិតិការអនុម័តគម្រោងវិនិយោគឯកជនរួមទាំងគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ។

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវទទួលខុសត្រូវក្នុងការ ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិដល់សាធារណជននូវស្ថិតិផ្លូវការដទៃទៀតតាមការចាំបាច់សម្រាប់តម្រូវការទិន្នន័យប្រើប្រាស់។

## ជំពូកទី៤
## ការគ្រប់គ្រងទិន្នន័យ និងប្រភពប្រមូលទិន្នន័យ

**មាត្រា៧._**

រាល់ការធ្វើជំរឿន និងអង្កេត ត្រូវដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ។ ចំពោះការអង្កេតតាមវិស័យត្រូវដឹកនាំដោយអង្គភាពស្ថិតិដែលបានចាត់តាំងដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ។ វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវប្រកាសផ្សាយទិន្នន័យជំរឿន និងអង្កេត តាមកម្រិតលម្អិតបំផុតដែលអាចធ្វើទៅបាន ហើយធានាការសម្ងាត់ទិន្នន័យដែលបានកត់ត្រាពីបុគ្គលម្នាក់ៗ និងគុណភាពទិន្នន័យស្ថិតិ។

អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវប្រមូល និងចងក្រងស្ថិតិ ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះអំពី ៖

- ទិន្នន័យរដ្ឋបាល ឬការអង្កេតតាមវិស័យដែលប្រមូលដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាគម និងសង្គមស៊ីវិល
- ទិន្នន័យថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ទិន្នន័យប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ។

**មាត្រា៨._**

រាល់ទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់ ដែលបានដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ត្រូវចុះបញ្ជីឈ្មោះស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

រាល់ការប្រមូល ទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតថ្មីដែលបានត្រៀមទុក ត្រូវផ្ញើទៅវិទ្យាស្ថានជាតិស្ថិតិ មុននឹងចាប់ផ្តើមអនុវត្តការងារ។

ក្រសួងផែនការត្រូវផ្សព្វផ្សាយដល់អង្គភាពស្ថិតិផ្លូវការដែលបានចាត់តាំងនូវទម្រង់បែបបទសម្រាប់បំពេញ និងកាលបរិច្ឆេទដែលត្រូវអនុវត្ត។

**មាត្រា៩.–**

ដោយផ្អែកលើយន្តការសម្របសម្រួលពីរ ដូចមានចែងក្នុងមាត្រា១៥ និងមាត្រា១៦ នៃច្បាប់ស្តីពីស្ថិតិគឺក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវអនុម័ត និងធ្វើបច្ចុប្បន្នកម្មផែនការមេស្ថិតិស្តីពីការប្រមូលទិន្នន័យរដ្ឋបាល ការធ្វើជំរឿន និងអង្កេត ឬការផ្តល់ទិសដៅរួមបញ្ចូលគ្នា ការកែប្រែ ឬការបញ្ឈប់នូវការប្រមូលទិន្នន័យរដ្ឋបាល ការធ្វើជំរឿន និងអង្កេត ដើម្បីបំបាត់នូវភាពជាន់គ្នា និងបង្កើនជាអតិបរមានូវការប្រើប្រាស់សមត្ថភាពសម្ភាសន៍តាមមូលដ្ឋាន និងការកែច្នៃទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ។

**មាត្រា១០.–**

រដ្ឋមន្ត្រីក្រសួងផែនការត្រូវបញ្ជូនបញ្ជីនៃរាល់ការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់ ការចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យនីមួយៗ ទៅទីស្តីការគណៈរដ្ឋមន្ត្រីក្នុងរយៈពេល ១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។ ជារៀងរាល់ឆ្នាំ រដ្ឋមន្ត្រីក្រសួងផែនការត្រូវបញ្ជូនបញ្ជីប្រមូល ទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតថ្មីៗទៅទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា១១.–**

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបញ្ជូននូវរាល់ព័ត៌មាន និងទិន្នន័យស្ថិតិដែលផលិតបានជាទម្រង់អេឡិចត្រូនិច និងជាសៀវភៅទៅវិទ្យាស្ថានជាតិស្ថិតិ និងទៅទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានទៀងទាត់ និងទាន់ពេលវេលា។

**មាត្រា១២.–**

វិទ្យាស្ថានជាតិស្ថិតិត្រូវបង្កើត និងថែរក្សាទុកនូវបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដោយផ្អែកលើការប្រមូលព័ត៌មានម៉េតាទិន្នន័យតាមរយៈដំណើរការចុះបញ្ជី។ បញ្ជីឈ្មោះម៉េតាទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ និងប្រកាស ផ្សាយតាមវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ។

# ឧបសម្ព័ន្ធ៤ ៖បញ្ជីសំណួរ

**ផ្នែក១**

## វិទ្យាស្ថានជាតិស្ថិតិ
## ក្រសួងផែនការ

# មេតាទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំង

**Metadata Designated Official Statistics**

ឆ្នាំ
Year

| 2 | 0 | 1 | 8 |
|---|---|---|---|

**I.រដ្ឋបាលនិងធនធាន** (Administration and Resource)

1.1. ឈ្មោះក្រសួង ឬស្ថាប័ន
Name of the Ministry or Government Institution

___

1.2. ភារកិច្ចចម្បងរបស់ក្រសួង ឬស្ថាប័ន
Main task of the ministry or Government Institution

___

___

___

___

___

1.3. ឈ្មោះអង្គភាពស្ថិតិដែលបានចាត់តាំង សម្រាប់ផលិតស្ថិតិផ្លូវការដែលបានចាត់តាំង នៅក្នុងក្រសួង ឬស្ថាប័នរបស់អ្នក
What is the name of the designated statistical unit for producing designated official statistics in your ministry or government institution

___

1.4. ឈ្មោះនាយកដ្ឋានដែលអង្គភាពស្ថិតិដែលបានចាត់តាំង នៅក្រោមឱវាទ
Name of Department this designated statistical unit belongs to

___

1.5. ឈ្មោះអគ្គនាយកដ្ឋានដែលអង្គភាពស្ថិតិដែលបានចាត់តាំង នៅក្រោមឱវាទ
Name of Directorate Department this designated statistical unit belongs to

___

1.6. ឈ្មោះអ្នកទទួលខុសត្រូវសម្រាប់សម្របសម្រួលជាមួយវិទ្យាស្ថានជាតិស្ថិតិ អំពីស្ថិតិ
Contact person responsible for coordination with the NIS on statistical issues

1. ឈ្មោះ Name:____________________
2. ឋានៈ/តំណែង Designation/title:____________________
3. លេខទូរស័ព្ទ Telephone/Mobile No. ____________________
4. អ៊ីមែល E-mail:____________________

1.7. តើអ្នកបានទទួលម្ចាស់ជំនួយបច្ចេកទេសសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងឆ្នាំនេះឬទេ? (គូសចម្លើយ ✓) Have you received any technical assistance for the designated statistical unit in this year? (tick ✓ an answer)

បាទ Yes ☐ ទេ No ☐

បើ **ទេ** សូមបំពេញ សំនួរ ១.៨។ if **No**, please go to 1.8

បើ **បាទ** សូមគូសចម្លើយ ✓ ខាងក្រោម។ អាចផ្តល់ចម្លើយច្រើនបើមាន។
if **Yes**, please tick ✓ the answers below. Give multiple answers if possible.

1. ជំនួយការទីប្រឹក្សាសម្រាប់ការប្រមូលទិន្នន័យវិភាគទិន្នន័យនិងការបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗ
Advisor assistance for data collection, data analysis and training or other activities ☐

2. ជំនួយខាងហិរញ្ញវត្ថុសំរាប់គ្រឿងបរិក្ខារ (កុំព្យូទ័រ ម៉ាស៊ីនថតចម្លង រថយន្ត)
Financial assistance for equipment (computer, photo copy machines, cars) ☐

3. ជំនួយខាងហិរញ្ញវត្ថុសម្រាប់សម្ភារៈប្រើប្រាស់ក្នុងការិយាល័យ
Financial assistance for office supplies(paper, envelop ,etc.) ☐

4. ជំនួយខាងហិរញ្ញវត្ថុសម្រាប់ការប្រមូលទិន្នន័យ
Financial assistance for data collection ☐

5. ផ្សេងទៀត (សូមបញ្ជាក់) Other (specify) ☐

---

1.8. ចំនួនមន្ត្រីសរុបក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងឆ្នាំនេះ
Total number of staff in designated statistical unit in this year ☐☐☐

1. ស្ត្រី Women ☐☐ 2. បុរស Men ☐☐

1.9. ចំនួនមន្ត្រីក្នុងអង្គភាពស្ថិតិដែលបានចាត់តាំងទទួលប្រាក់លើកទឹកចិត្ត និង/ឬប្រាក់ចំណាយប្រតិបត្តិអាទិភាព ក្នុងឆ្នាំនេះ
Number of staff in designated statistical unit receiving incentive payment and/or POC payment (priority operating costs) in this year ☐☐☐

ផ្នែកខ២

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

# ម៉េតាទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំង

**Metadata Designated Official Statistics**

ឆ្នាំ Year | 2 | 0 | 1 | 8 |

## II.ព័ត៌មានអំពីស្ថិតិផ្លូវការដែលបានចាត់តាំងក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង

(Information on Designated Official Statistics in Designated Statistical Unit)

(សូមមើលអនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំងជំពូកទី ៣)
(Please, see the Sub-Decree on Designated Official Statistics, Chapter 3)

2.1. ឈ្មោះស្ថិតិផ្លូវការដែលបានចាត់តាំង Name of designated official statistics

______________________________

2.2. ឈ្មោះអ្នកទំនាក់ទំនង Contact person ______________________________

លេខទូរស័ព្ទ និងអ៊ីមែល Telephone/Mobile No. and E-mail ______________________________

2.3. តើអ្នកបានប្រមូលទិន្នន័យ ក្នុងឆ្នាំនេះដែរឬទេ? (គូសចម្លើយ ✓) បាទ Yes ☐ ទេ No ☐
Did you collect data in this year? (tick ✓ an answer)

បើ ***បាទ*** សូមបន្តទៅសំណួរ 2.4 If ***Yes***, continue question 2.4

បើ ***ទេ*** តើមូលហេតុអ្វី ដែលអ្នកមិនបានផលិតស្ថិតិ ក្នុងឆ្នាំនេះ។ (សូមបន្តទៅសំណួរ 2.4 រួចបញ្ចប់ការសម្ភាសន៍)
If **No**, What are the reasons for not producing the statistics in this year. (continue question 2.4 and Finish)

1. មិនមានថវិកា No budget ☐
2. ថវិកាមិនគ្រប់គ្រាន់ Not enough budget ☐
3. មិនទាន់ដល់ពេលផលិត Not supposed to be produced this year ☐
4. ផ្សេងទៀត(សូមបញ្ជាក់) Other (Specify) ☐

______________________________

2.4. ឈ្មោះរបាយការណ៍ស្ថិតិ និងឆ្នាំដែលបានបោះពុម្ពចុងក្រោយ? Name of the report and year of the latest published statistics:

______________________________

2.5. ទិន្នន័យដែលអ្នកបានប្រមូលក្នុងឆ្នាំនេះ តើសម្រាប់ឆ្នាំ/រយៈពេលណា?
For what period/year did you collect data in this year?

1. ប្រចាំខែ Monthly ☐
2. ប្រចាំត្រីមាស Quarterly ☐
3. ប្រចាំឆ្នាំ Annually ☐
4. ផ្សេងទៀត (សូមបញ្ជាក់) Other (specify) ☐

______________________

2.6. តើមានប្រភពទិន្នន័យអ្វី ដែលអ្នកប្រើសម្រាប់ស្ថិតិរបស់អ្នក ? សូមគូសចម្លើយ ✓ ខាងក្រោម ។ អាចផ្តល់ចម្លើយច្រើនបើមាន (បើជាកំណត់ត្រា រដ្ឋបាល សូមរំលងទៅសំនួរ ២.៨) ។
What data sources do you use for your statistics? Please tick ✓ an answer below. Give multiple answers if possible.( If tick ✓Administrative record please go to 2.8)

1. កំណត់ត្រារដ្ឋបាល Administrative record ☐
2. អង្កេត Survey ☐
3. ជំរឿន Census ☐
4. ផ្សេងទៀត (សូមបញ្ជាក់) Other (specify) ☐

______________________

2.7.បើប្រភពជាអង្កេត ឬជំរឿន តើអ្នកប្រមូលស្ថិតិពីអ្នកណាខ្លះ? សូមគូសចម្លើយ ✓ ខាងក្រោម ។ អាចផ្តល់ចម្លើយច្រើនបើមាន ។
If survey or census who do you collect statistics from? (What is the reporting unit?) Please tick ✓ the answers below. Give multiple answers if possible.

1. បុគ្គល Individual ☐
2. គ្រួសារ Household ☐
3.សហគ្រាស Enterprise/Company ☐
4.ស្ថាប័នរដ្ឋ រួមបញ្ចូលទាំងមេភូមិ Government organizations and institutions including village chief ☐
5. អង្គការមិនមែនរដ្ឋាភិបាល Non-Government Organization ☐
6.ផ្សេងទៀត (សូមបញ្ជាក់) Other (specify) ☐

______________________

2.8.តើស្ថិតិអាចបង្ហាញតាមកម្រិតតំបន់ណាខ្លះ? សូមគូសចម្លើយ ✓ ខាងក្រោម ។ អាចផ្តល់ចម្លើយច្រើនបើមាន ។
For what regional level can the statistics be presented? Please tick ✓ the answers below. Give multiple answers if possible.

1.ប្រទេសកម្ពុជា Cambodia ☐
2.ថ្នាក់ខេត្ត Province ☐
3.ថ្នាក់ស្រុក District ☐
4.ថ្នាក់ឃុំ Commune ☐
5.ថ្នាក់ភូមិ Village ☐
6.ផ្សេងទៀត (សូមបញ្ជាក់) Other (specify) ☐

______________________

2.9. តើជាធម្មតាអ្នកប្រមូលស្ថិតិរៀងរាល់ពេលណា? សូមគូសចម្លើយ ✓ ខាងក្រោម ។ អាចផ្តល់ចម្លើយច្រើនបើមាន ។
How often is the statistics presented? Please tick ✓ the answers below. Give multiple answers if possible.

1. ប្រចាំខែ Monthly ☐
2. ប្រចាំត្រីមាស Quarterly ☐
3. ប្រចាំឆ្នាំ Annually ☐
4. ផ្សេងទៀត(សូមបញ្ជាក់) Other (specify) ☐

______________________

2.10. តើអ្នកមានគម្រោងបោះផ្សាយទិន្នន័យដែលបានប្រមូលនៅឆ្នាំនេះ នៅពេលណា? When do you plan to publish the data collected in this year?

______________________

2.11. ឈ្មោះរបាយការណ៍ស្ថិតិដែលបានប្រមូលនៅឆ្នាំនេះ? Name of the report of the data collection in this year?

___

2.12. តើអ្នកណាជាអ្នកប្រើប្រាស់ដ៏សំខាន់ សម្រាប់ស្ថិតិដែលបានប្រមូល? Who are the main users of the collected statistics?

___

___

___

2.13. តើគោលបំណងរបស់ស្ថិតិដែលបានប្រមូលគឺជាអ្វី? What are the main objectives sections /question of the collected statistics?

___

___

___

2.14. តើអ្នកបានផ្ញើសូចនាករ/តារាង/មីក្រូទិន្នន័យ ពីស្ថិតិដែលបានប្រមូលទៅឱ្យ :

សូមគូស ✓ ចម្លើយខាងក្រោម ។ អាចផ្តល់ចម្លើយច្រើនបើមាន ។

Did you deliver indicators/tables/micro data from the collected statistics to: Please tick ✓ the answers below. Give multiple answers if possible.

| | | | |
|---|---|---|---|
| 1. វិទ្យាស្ថានជាតិស្ថិតិ National Institute of Statistics | ☐ | 3. អង្គការអន្តរជាតិ International Organizations | ☐ |
| 2. ទីស្តីការគណៈរដ្ឋមន្ត្រី Council of Ministers | ☐ | 4. ទេ No | ☐ |

2.15. ថវិកាសម្រាប់ស្ថិតិ Budget for the Statistics

បំពេញតែមួយ សម្រាប់ថវិកាប៉ាន់ស្មាន ឬថវិកាជាក់ស្តែង ។ (ឯកតាគិតជាដុល្លារអាមេរិក)

Only fill in estimated or actual budget. (Unit in US$).

| **ថវិកា**<br>Budget Items | **ថវិកាប៉ាន់ស្មាន**<br>Estimated Budget | **ថវិកាជាក់ស្តែង**<br>Actual Budget |
|---|---|---|
| បៀវត្សរ៍មន្ត្រីរាជការ<br>Government salary staff | | |
| ប្រាក់លើកទឹកចិត្តមន្ត្រីរាជការ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Incentive staff (Government/Donor) | | |
| ចំណាយលើបរិក្ខារ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Equipment expenses (Government/Donor) | | |
| ចំណាយលើការបណ្តុះបណ្តាលសម្រាប់ការប្រមូលទិន្នន័យ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Training for data collection expenses (Government/Donor) | | |
| ចំណាយលើការប្រមូលទិន្នន័យ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Data collection expenses (Government/Donor) | | |
| ចំណាយលើការវិភាគសរសេររបាយការណ៍ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Analysis, report writing expenses (Government/Donor) | | |
| ចំណាយលើការផ្សព្វផ្សាយ (បោះពុម្ព ថតចម្លងរបាយការណ៍ ការដាក់បញ្ចូលក្នុងវេបសាយ ។ ល ។) (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Dissemination expenses (publishing, printing reports, website etc.) (Government/Donor) | | |
| ចំណាយដទៃទៀត រួមទាំងសម្ភារៈការិយាល័យ (រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍)<br>Other costs including office supplies (Government/Donor) | | |
| **សរុប**<br>Total | | |

***សូមអរគុណដែលបានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ!***

*Thanks for your cooperation with the National Institute of Statistics!*